ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Mar-2016, 15:11
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦**

**ម៉ោង ០៩:១១នាទី**

**សវនាការលើកទី៣៧៩**

ចៅក្រមសាលាដំបូង៖

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា ជា ស៊ីវហ៊ាង

លោក នីកូឡូ ប៉ុងស៍ *(Mr. Niccolo PONS)*

ការិយាល័យសហព្រះរាជអាជ្ញា៖

កញ្ញា សុង ឆវ័ន្ត

លោក ត្រាវីស ហ្វារ*(Mr. Travis FARR)*

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផនៈ**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីៈ**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការៈ**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ាន់ ម៉ាត់ (2-TCW-893) | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី៖ លោក វ៉ាន់ ម៉ាត់ (2-TCW-893)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ២
សួរដោយលោក ត្រាវីស ហ្វារ ផ្ដើមពី ........ ទំព័រ ៨
សួរដោយលោកស្រី ជេត វណ្ណលី ផ្ដើមពី ........ ទំព័រ ៣៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៤៣
សួរដោយលោក វិុចទ័រ កូប៉េ ផ្ដើមពី ........ ទំព័រ ៤៥
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ........ ទំព័រ ៦៦
សួរដោយលោក គង់ សំអុន ផ្ដើមពី ........ ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះកំណត់ត្រូវធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-893 ពាក់ព័ន្ធនឹងអង្គហេតុការប្រព្រឹត្តចំពោះក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម។

ក្រឡាបញ្ជីសវនាការក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នេះរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះមានរហស្សនាម 2-TCW-893 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬក៏ភាគីដើមបណ្តឹងរដ្ឋប្បវេណីណា ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះមុនពេលផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់

មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភ័ស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ អង្គុយយូរមិនបាន អង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:១៤:២៤]

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ខ្ញុំបាទឈ្មោះ វ៉ាន់ ម៉ាត់ លោកប្រធាន។

[០៩:១៧:០៨]

**ស៖** ចុះឈ្មោះ សឡេះ អះម៉ាត់ ហ្នឹងឈ្មោះអ្នកណាគេ?

**ឆ៖** ឈ្មោះ សឡេះ អះម៉ាត់ ហ្នឹងឈ្មោះដើមកំណើតមក ដល់ក្រោយឈ្មោះ វ៉ាន់ ម៉ាត់ ប្ដូរ។

**ស៖** សព្វថ្ងៃនេះ លោកប្រើប្រាស់ឈ្មោះជាផ្លូវការសម្រាប់ធ្វើអត្តសញ្ញាណប័ណ្ណ ឬក៏ឯកសារផ្សេងៗពាក់ព័ន្ធនឹងលោកហ្នឹង តើលោកប្រើឈ្មោះផ្លូវការឈ្មោះអី?

**ឆ៖** បាទ គោរពលោកប្រធាន។ ឈ្មោះ វ៉ាន់ ម៉ាត់ ជាផ្លូវការរាល់ថ្ងៃ។

**ស៖** ក្រៅពីឈ្មោះទាំងពីរហ្នឹង តើលោកមានឈ្មោះហៅក្រៅអីផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ អត់មានទេ លោកប្រធាន។

**ស៖** ឃើញនូវរបាយការណ៍របស់ខាងក្រសួងមហាផ្ទៃ ថាលោកមានឈ្មោះ ម៉ាត់ តូច មួយទៀត តើមានទេ?

**ឆ៖** អាហ្នឹង ឈ្មោះគេហៅក្រៅ លោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយលោកកើតនៅថ្ងៃ ខែ ឆ្នាំណា លោក វ៉ាន់ ម៉ាត់ លោកចាំទេ?

**ឆ៖** កើតថ្ងៃ០៩ ខែ១១ ១៩៥៣។

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** ទីកំណើតនៅភូមិជំនីក ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ បច្ចុប្បន្ននៅទីរួមខេត្តក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ។

**ស៖** លោកប្រកបមុខរបរអីដែរសព្វថ្ងៃនេះ?

**ឆ៖** មុខរបរជាមន្ត្រីយោធា និងអង្គរក្សរបស់សម្ដេច ហ៊ុន សែន។

[០៩:១៩:២៩]

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ សាំង សឡេះ។ ម្ដាយឈ្មោះ សឡេះ ទី -- អ៉ំ! ស្លេះ ទី បាទ។

**ស៖** ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយាឈ្មោះ តែល វ៉ាមី។ មានកូនប្រាំនាក់។

**ស៖** លោក វ៉ាន់ ម៉ាត់ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ទេ ហើយនិងក៏ដូចជាមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើរបាយការណ៍នេះ ពិតត្រឹមត្រូវ ដែរឬទេ?

**ឆ៖** បាទ លោកប្រធានត្រឹមត្រូវហើយ។

**ស៖** ហើយលោកមានជំនឿសាសនាអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទមានកាន់សាសនាអ៊ីស្លាម។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះក៏សូមជម្រាបជូនភាគីជ្រាបដែលថា ឯកសារដែលគាត់នៅពីមុខគាត់នោះគឺជាខ្លឹមសារនៃពាក្យសម្បថដែលអង្គជំនុំជម្រះ -- ក្រឡាបញ្ជីនៃអង្គជំនុំជម្រះរៀបចំសម្រាប់គាត់អានពេលធ្វើសម្បថ។ សូមបញ្ជាក់ឲ្យយល់ដឹងអំពីបញ្ហានោះ កុំជៀសវាងការភ័ន្តច្រឡំ។ បង្គាប់ឲ្យក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ធ្វើការសម្របសម្រួលណែនាំឲ្យសាក្សីរូបនេះ ធ្វើសម្បថតាមជំនឿសាសនារបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:២១:២៥]

**ក្រឡាបញ្ជី៖**

ជម្រាបសួរលោកសាក្សី។ ជាបន្តទៅនេះ ខ្ញុំនឹងរៀបចំពិធីសម្បថដល់លោក។ សូមលោកសាក្សីដាក់បាតដៃស្តាំនៅលើគម្ពីរអាល់គូរ៉អាន ដែលនៅពីមុខលោក។ ខ្ញុំនឹងអាននូវពាក្យសម្បថ ហើយសូមលោកនិយាយនូវពាក្យសម្បថនេះតាមខ្ញុំ នៅពេលដែលខ្ញុំបញ្ចប់ការអាន។ ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចងចាំផ្ទាល់។ ក្នុងនាំខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាមដែលមានអល់ឡោះជាម្ចាស់តែមួយ និងមហាម៉ាត់ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គូរ៉អានជាសម្តីរបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម។ ខ្ញុំសូមស្បថដែលមានគម្ពីរអាល់គូរ៉អាននៅពីមុខខ្ញុំស្រាប់ វល់-ឡ-ហ៊ី ពិល-ឡា-ហ៊ី បញ្ជាក់ថាអ្វីៗដែលខ្ញុំនិយាយសុទ្ធតែជាការពិតទាំងអស់។ សូមលោកសាក្សីអានតាម។

**លោក វ៉ាន់ ម៉ាត់៖**

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ និងបានដឹង និងបានចាំផ្ទាល់ ក្នុងនាំខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាមដែលមានអល់ឡោះជាម្ចាស់តែមួយ និងមហាម៉ាត់ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គូរ៉អានជាសម្ដីរបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម ខ្ញុំសូមស្បថថា មានតែគម្ពីរតែអស់ឡោះ -- គម្ពីអាល់គូរ៉អាននៅពីមុខខ្ញុំស្រាប់ "វល់-ឡ-ហ៊ិ ពិល-ឡា-ហ៊ិ" បញ្ជាក់ថាអ្វីៗដែលខ្ញុំនិយាយសុទ្ធតែជាការពិតទាំងអស់។ សូមអស់។

[០៩:២៣:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ ជាបន្តទៅនេះយើងប្រាប់អំពីសិទ្ធិ និង ករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិលោក វ៉ាន់ ម៉ាត់ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរនីតិវិធីការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឱ្យលោកធ្វើការអត្ថាធិប្បាយរៀបរាប់ដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោក វ៉ាន់ ម៉ាត់ ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឱ្យលោកចម្លើយតប ឬការធ្វើអត្ថាធិប្បាយដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយឱ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

[០៩:២៤:០៩]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ហើយលោក វ៉ាន់ ម៉ាត់ តើលោកធ្លាប់ផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ១ប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? នៅពេលណា លោកចាំដែរទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ លោកប្រធាន ធ្វើទៅដល់ផ្ទះខ្ញុំបាទ នៅឯខេត្តក្រចេះ លោកប្រធាន។ ទៅសម្ភាសខ្ញុំបាទនៅហ្នឹង។

**ស៖** លោកចាំធ្វើនៅពេលណាដែរទេ? យ៉ាងហោចក៏ចាំឆ្នាំដែរ?

**ឆ៖** សូមគោរពលោកប្រធាន វាឆ្នាំ២០០៨ លោកប្រធាន។

**ស៖** ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ? ព្រោះលោកបានផ្ដល់កិច្ចសម្ភាសន៍នោះ តាំងពីឆ្នាំ២០០៨ មកម្ល៉េះ។

**ឆ៖** បាទ លោកប្រធាន បានអាន បានពិនិត្យហើយ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះគឺវាពិតជាត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នា ទៅនឹងចម្លើយដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីឆ្នាំ២០០៨នោះដែរឬទេ?

**ឆ៖** បាទ ស៊ីចង្វាក់គ្នាហើយលោកប្រធាន។

[០៩:២៦:០៣]

**ប្រធានអង្គជំនុំ៖**

ហើយតាមព័ត៌មានគឺ ថាលោកមានបញ្ហាសុខភាពដែលអាចទៅតម្រូវការទៅបន្ទប់ទឹកញឹកញាប់ ហើយសូមលោកកុំខ្លាចក្រែងរអែងអី ក្នុងករណីណាលោកមានបំណងទៅ លោកគ្រាន់តែលើកដៃជាសញ្ញា គឺយើងនឹងអនុញ្ញាតឲ្យលោកចាកចេញទៅបន្ទប់ទឹកបាន ប្រសិនបើលោកមានតម្រូវការដូច្នេះណា នៅក្នុងអំឡុងពេលនៃដំណើរការសវនាការនេះ។ ហើយបញ្ជាក់ថា ដំណើរការសវនាការ យើងមិនធ្វើជាប់រហូតនោះទេ យើងធ្វើតែ១ម៉ោងជាង ១ម៉ោង១០នាទី ឬក៏១ម៉ោង យើងសម្រាកម្ដងហើយ។ អ៊ីចឹងប្រហែលជាអាចដោះស្រាយបញ្ហានេះបាន ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ បើចាំបាច់គឺលោកអាចលើកដៃប្រាប់យើង ជាសញ្ញាប្រាប់យើង យើងនឹងអនុញ្ញាតឲ្យលោកអាចចាកចេញទៅរកបន្ទប់ទឹកក្នុងអំឡុងពេលនៃផ្ដល់សក្ខីកម្មបាន។

ក្នុងការសួរដេញសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក

អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:២៧:២៧]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកសាក្សី។ លោកប្រធាន មុនពេលដែលខ្ញុំចាប់ផ្ដើម ខ្ញុំបានសង្កេតឃើញថា សាក្សីគាត់មានការសម្ភាសលើកទី២ ជាមួយខាងសហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០១១។ <ឯកសារនេះបានដាក់ចូលក្នុងសំណុំរឿងរួចហើយ។> ហើយខ្ញុំមានឯកសារនេះនៅក្នុងដៃរបស់ខ្ញុំដែរ។ ហើយខ្ញុំនឹងប្រើប្រាស់ឯកសារនេះ ហើយខ្ញុំគិតថាមេធាវី<ការពារក្ដី>ក៏នឹងប្រើប្រាស់ឯកសារនេះដែរ។ <វា>ប្រហែលជា<មានប្រយោជន៍សម្រាប់>សាក្សីគាត់មានឱកាសបានពិនិត្យមើលទៅលើឯកសារនេះ <ប៉ុន្តែខ្ញុំមិនដឹងថា ពេលណាជាឱកាសល្អសម្រាប់ធ្វើបែបនោះទេ>។ <សម្រាប់ប្រតិចារិក>ឯកសារគឺឯកសារ E3/8735។ ប្រហែលជាយើងអាចប្រគល់ឯកសារនេះ ជូនសាក្សីឱ្យពិនិត្យមើល នៅពេលឈប់សម្រាក<>។ ហើយ<បន្ទាប់មក ក្រោយពីយើងចូលពីសម្រាកលើកដំបូងមកវិញ គាត់នឹងត្រូវសួរសំណួរមួយចំនួន អំពីភាពត្រឹមត្រូវដូចដែលយើងធ្លាប់ធ្វើជាប្រក្រតី។>

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក វ៉ាន់ ម៉ាត់ តើបានពិនិត្យ និងអានឯកសារ មុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះប៉ុន្មាន ឯកសារប៉ុន្មានដែលលោកបានអានកន្លងមកហើយនេះ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ លោកប្រធាន អានឯកសារតែមួយទេ មិនទាន់អានអស់។

[០៩:២៩:០៥]

**ស៖** ហើយលោកមានដែលផ្ដល់សក្ខីកម្មម្ដងទៀតទេ ក្រោយឆ្នាំ២០០៨ បានន័យថានៅក្នុងអំឡុង២០១១ តើធ្លាប់បានផ្ដល់សក្ខីកម្មដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក នេះ សាជាថ្មីម្ដងទៀតដែរឬទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ លោកប្រធាន ពេលហ្នឹងខ្ញុំចាំអត់បាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតដោយសារតែនេះវាជាឯកសារនៅក្នុងសំណុំរឿងក្ដី ហើយគួរតែទុកលទ្ធភាព សំណួរពាក់ព័ន្ធនឹងបញ្ហានេះ ក្រោយដើម្បីឲ្យគាត់អាននៅក្នុងអំឡុងពេលឈប់សម្រាក ជាការសមស្រប។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** សូមជម្រាបសួរលោក វ៉ាន់ ម៉ាត់។ ខ្ញុំជាសហព្រះរាជអាជ្ញា។ ហើយខ្ញុំជាដំបូងគេក្នុងការសួរលោក។ ជាដំបូងខ្ញុំសូមសួរបញ្ហាមួយចំនួនទាក់ទងនឹងភូមិរបស់លោក គឺភូមិ<ជំនីក>។ តើលោកអាចរៀបរាប់ពី<ទីតាំង>ភូមិបាន<នោះ>ទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ រៀបរាប់បាន។ ភូមិ ភូមិជំនីក ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

**ស៖** តើខ្ញុំអាចនិយាយបានទេ គឺវានៅតាមឆ្នេរខាងត្បូងនៃទន្លេមេគង្គ តាមមាត់ទន្លេខាងត្បូងនៃទន្លេមេគង្គ?

[០៩:៣០:៥៨]

**ឆ៖** បាទ ឃុំហ្នឹងវាជាប់នឹងទន្លេមេគង្គ ខាងត្បូង។ ត្រឹមត្រូវហើយ។

**ស៖** តើលោកអាចប្រាប់បានទេថា ភូមិហ្នឹងមានចម្ងាយប្រហែលប៉ុន្មានដែរពីកោះផល?

**ឆ៖** ភូមិហ្នឹងចម្ងាយពីកោះផល ប្រហែល១០គីឡូដី។

**ស៖** តើវាមានចម្ងាយប្រហែលប៉ុន្មានដែរ ពីស្វាយឃ្លាំង?

**ឆ៖** ពីស្វាយឃ្លាំង ប្រហែលជាង២០គីឡូ។

**ស៖** តើវាមានចម្ងាយប្រហែលប៉ុន្មានដែរ ពីវត្តស្វាយដំណាក់?

**ឆ៖** វត្តស្វាយដំណាក់ទៅកោះផល ប្រហែល៩គីឡូ។

**ស៖** ខ្ញុំចង់និយាយអំពីពេលវេលាមុនពេលខ្មែរក្រហមមកដល់ភូមិរបស់លោក។ តើលោកអាច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ប្រាប់បានទេថា<នៅពេលនោះ> នៅក្នុងភូមិជំនីកហ្នឹង តើប្រជាជនហ្នឹងជាប្រជាជនចាមសុទ្ធ ឬក៏ចាមលាយខ្មែរ ឬក៏មាន<ជនជាតិដទៃទៀតរស់នៅលាយឡំគ្នា>?

**ឆ៖** នៅប្រជាជន មានពាក់កណ្ដាលម្នាក់។ ប្រជាជនចាមពាក់កណ្ដាល ខ្មែរពាក់កណ្ដាល នៅក្នុងឃុំហ្នឹង។

**ស៖** តើលោកអាចប៉ាន់ស្មានបានទេ ថាតើមានប្រជាជនចាមប្រហែលប៉ុន្មាន<គ្រួសារ>ដែរនៅក្នុងភូមិ<ជំនីក> មុនពេលខ្មែរក្រហមចូលមកដល់?

[០៩:៣៣:២០]

**ឆ៖** ប្រហែលជាង១០.០០០នាក់។

**ស៖** តើលោកកំពុងតែនិយាយហ្នឹង និយាយ១០.០០០នាក់ ឬក៏១០.០០០គ្រួសារ?

**ឆ៖** មួយភូមិណា មួយឃុំមិនដឹងប៉ុន្មានទេ យើងក្ដាប់អត់បាន យើងមិនមែនអ្នកនេះ។ និយាយក្នុងមួយភូមិ។

**ប្រធានអង្គជំនុំ៖**

ឆ្លើយម្ដងទៀត លោកឆ្លើយអំមិញ គឺក្បាលមីក្រូមិនទាន់ប្រតិបត្តិការទេ។ អ៊ីចឹងបានថាវាអត់ប្រព័ន្ធសំឡេងរបស់លោកមិនទាន់ចែកចាយ ជាពិសេសដល់អ្នកបកប្រែភាសា ដើម្បីបកប្រែទៅជាភាសាអង់គ្លេស និងភាសាបារាំង។

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** សូមទោសអំមិញ មួយភូមិទេណា ព្រោះក្នុងនោះវាច្រើនភូមិ ជំនីក។ និយាយមួយភូមិជំនីកហ្នឹងជាង ១០.០០០នាក់។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** តើមានហាជី ឬក៏តួនដែរឬទេ នៅក្នុងភូមិជំនីកនោះ?

**ឆ៖** ពេល ប៉ុល ពត ចូលមកគឺអស់ហើយហាជី តួន។ គេយកសម្លាប់អស់ហើយ។

**ស៖** ប៉ុន្តែខ្ញុំចង់និយាយអំពីពេលវេលាមុន ប៉ុល ពត ចូលមកគ្រប់គ្រងប្រទេសហ្នឹង <>តើមានហាជី ឬក៏តួន <ឬមេ>ដឹកនាំសាសនា<ផ្សេងទៀត>រស់<នៅ>ក្នុងភូមិជំនីកនោះ<ទេ>?

**ឆ៖** ពេលមុន ប៉ុល ពត ចូលមកមានទាំងអស់ មានតួន មានហាជី មានកឹមអីទាំងអស់។

[០៩:៣៥:៣៣]

**សៈ** នៅក្នុងកិច្ចសម្ភាសន៍ទី១ របស់លោក ហើយខ្ញុំគិតថា ជាឯកសារដែលលោកបានពិនិត្យរួច ហើយ គឺឯកសារ E3/5209 នៅក្នុងសំណួរទី១ លោកបាននិយាយថា មុនពេលខ្មែរក្រហមមកដល់គឺថា លោករៀននៅក្នុងវិហារចាមនៅវត្តជំនីក។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកទៅរៀនអីដែរនៅក្នុងវិហារនៅវត្ត ជំនីកហ្នឹង? ហើយលោកអាយុប៉ុន្មានដែរ ពេលលោកទៅរៀននោះ?

**ឆៈ** ពេលទៅរៀនៗភាសាអ៊ីស្លាមនៅវិហារអ៊ីស្លាមហ្នឹងណ៎ា អាយុ ពេលហ្នឹងអាយុប្រហែល ១៧ឆ្នាំ។

**សៈ** តើលោកមានរៀនមុខវិជ្ជាផ្សេងក្រៅពីមុខវិជ្ជាសាសនាទេ ឬមួយក៏លោករៀនតែមុខវិជ្ជា ទាក់ទងនឹងសាសនាតែប៉ុណ្ណោះ?

**ឆៈ** ពេលហ្នឹងរៀនតែមុខវិជ្ជាសាសនា អត់មានរៀនក្រៅផង។

**សៈ** តើអ្នកណាជាគ្រូរបស់លោកនៅពេលដែលលោករៀននៅព្រះវិហារនោះ?

**ឆៈ** ឈ្មោះតួនជិ គ្រូ ជាគ្រូរបស់ខ្ញុំបាទ – តួនជិ។

**សៈ** តើលោកនៅបន្តរៀននៅព្រះវិហារហ្នឹងរហូតទៅដល់ពេលខ្មែរក្រហមចូលមកដល់ ឬមួយ ក៏យ៉ាងម៉េចដែរ?

**ឆៈ** នៅរៀន ប៉ុន្តែខ្មែរក្រហមចូលមក គេបិទ ឈប់ឲ្យរៀនហើយ។

[០៩:៣៧:៣៩]

**សៈ** ឥឡូវនេះខ្ញុំចង់និយាយដដែលអំពីពេលវេលាមុនខ្មែរក្រហមមកដល់។ <> តើ<> លោក មានធ្វើការងារ <ឬរកស៊ី> ឬក៏មានតួនាទីអ្វីដែរ <នៅស្របពេលលោកកំពុងរៀននោះ>?

**ឆៈ** បាទ អត់មានការងារអីទេ។ រៀនចប់ហើយ អាពតចូលមកប្រើឲ្យទៅឃ្វាលគោឃ្វាល ក្របីហ្នឹង។

**សៈ** ឥឡូវនេះខ្ញុំចង់និយាយ<ពី>ពេលដែលខ្មែរក្រហមចូលមកដល់ភូមិជំនីក តើលោកអាច ប្រាប់បានទេថា តើខ្មែរក្រហមចូលមកដល់ភូមិរបស់លោកនៅពេលណាដែរ នៅមុនពេលដែលខ្មែរ ក្រហមដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ឬក៏ក្នុងពេលជាមួយគ្នា ឬមួយក៏ក្រោយពេលខ្មែរក្រហមចូល កាន់កាប់ទីក្រុងភ្នំពេញហើយ?

**ឆៈ** ក្រោយខ្មែរក្រហមចូលភ្នំពេញ ដែលតឹងតែងបំផុតហ្នឹងមានតែឆ្នាំ១៩៧៦ *(ស៊ីក)*។

**សៈ** ក្រោយពេលដែលខ្មែរក្រហមមកដល់ តើលោកអាចរៀបរាប់បានទេថា វាមានការប្រែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រួលអ្វីដូចជា មានច្បាប់ថ្មី ឬក៏មានការរឹតបន្តឹង<> ទាក់ទងទៅនឹងសហគមន៍ចាមដែរឬទេ?

**ឆ៖** បាទ មាន។ មានបំបិទមិនឱ្យជឿសាសនា មិនឱ្យអីអ៊ីចឹងណ៎ា។ ហើយដល់ធ្វើការជម្លៀស ទីលំនៅ ថាយកទៅណា ខេត្តបាត់ដំបងខេត្តអីនោះ តាំងពី៧៦មក *(ស៊ឹក)*។

**ស៖** ខ្ញុំនឹងនិយាយនៅពេលបន្តិចទៀតទាក់ទងការជម្លៀស។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីការ អនុវត្ត ការគោរពសាសនា ថាតើមានការហាមឃាត់ដែរឬទេ ដូចជាការនិយាយភាសាចាម ការគោរព សាសនាចាម ឬក៏ការហាមឃាត់ការស្លៀកពាក់សម្លៀកបំពាក់ចាម <ការទុកសក់របស់>នារីអីជាដើម តើមានទេ?

**ឆ៖** បាទ មាន។ ឃាត់មិនឱ្យជឿសាសនា ឲ្យ មិនឱ្យស្លៀកពាក់របៀបចាម កាត់សក់ខ្លី បង្ខំ ឱ្យហូបសាច់ជ្រូក ស្អីអ៊ីចឹងមាន។

**ស៖** តើនៅក្នុងភូមិជំនីកហ្នឹង <មានអ្វីកើតឡើង>ចំពោះសៀវភៅ<>គូរ៉អាន ឬក៏សៀវភៅ សាសនាដទៃទៀត<>?

**ឆ៖** ពេលហ្នឹងគេប្រមូលយកទៅដុតចោលទាំងអស់ ខ្លះយកទៅកិតអាចម៍ កិតអីទៅ។ ប្រមូល ដុតចោលទាំងអស់គម្ពីរគូរ៉អាន សៀវភៅអ៊ីស្លាមទាំងអស់។

**ស៖** តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេថា តើចំពោះព្រះវិហារសាសនាអ៊ីស្លាមនៅក្នុង ភូមិជំនីក គឺវិហារដែលលោកទៅរៀន<រហូតដល់ពេលខ្មែរក្រហមចូលមកដល់នោះ> តើមានអីកើត ឡើងដែរ?

**ឆ៖** វិហារហ្នឹងគេយកទៅធ្វើក្រោលគោ ក្រោលអី យកគោទៅដាក់ក្នុងវិហារ ឱ្យគោដេក។

**ស៖** ឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត តើលោកដឹងទេអំពីការតវ៉ាដែលកើតឡើង នៅស្វាយឃ្លាំង ហើយនិងកោះផលនៅក្នុងចុងឆ្នាំ៧៥ តើលោកដឹងទេ?

**ឆ៖** ដឹង ប៉ុន្តែអត់ច្បាស់ ព្រោះពេលហ្នឹងវាមិនឱ្យទាក់ទងគ្នា គ្រាន់តែឮតាមគ្នា ពេលពួកហ្នឹង បះបោរណ៎ា ព្រោះភូមិណា អ្នកភូមិណានៅនុ៎ងហើយ អត់អាចដើរទៅណារួចទេ។ អ៊ីចឹងគ្រាន់តែឮ ដំណឹងតាមគ្នា អត់មានដឹងការពិតច្បាស់ទេហ្នឹង។

**ស៖** ខ្ញុំនឹងសួរលោកនៅពេលក្រោយទាក់ទងទៅនឹងអ្វីដែលលោកដឹងអំពីការតវ៉ា។ ឥឡូវនេះខ្ញុំ ចង់និយាយបន្តិចអំពីពេលដែលខ្មែរក្រហមចូលមកដល់ហើយ ប៉ុន្តែមុនពេលដែលមានការបះបោរ។ ដូច្នេះក្នុងចន្លោះពេលហ្នឹង ថាតើមានការចាប់ខ្លួនជនជាតិចាមនៅក្នុងភូមិជំនីកដែរឬទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៤៣:២៨]

**ឆ៖** មាន។ ចាប់ទាំងអស់ អ្នកច្រើនដែរ ជំនីក កោះផលអីហ្នឹងចាប់យកអស់ហើយ។ វាថាមេឯណា សេ.អ៊ី.អា ម៉េច។ ចាប់អ្នកដែលមានមុខមានមាត់ ចាប់ទៅច្រើនណាស់ ទាំងគ្រូបង្រៀន ទាំងអ្នកចេះដឹងទាំងប៉ុន្មាន ចាប់។ ពេលចាប់ហ្នឹង គេចាប់យកទៅមន្ទីរអប់រំ មន្ទីរសន្តិសុខគេនៅស្រុកក្រូចឆ្មារ ចាប់យកទៅបាត់ទាល់ឥឡូវហ្នឹង មិនឃើញម្នាក់មកវិញផង។

**ស៖** តើលោកដឹងទេថា មន្ទីរសន្តិសុខហ្នឹងនៅត្រង់ទីកន្លែងណាដែរក្នុងស្រុកក្រូចឆ្មារ?

**ឆ៖** សម័យហ្នឹងគេនេះហើយ គេរុះចោលអស់ហើយពេលនេះ នៅខ្សាច់ប្រឆេះទីតាំងនុ៎ង។ ទីតាំងនោះនៅខ្សាច់ប្រឆេះ ស្រុកក្រូចឆ្មារ។

**ស៖** តើលោកដឹងទេ អ្នកណាជាអ្នកដឹកនាំការចាប់ខ្លួននេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** គេប្រាប់ថា អង្គការថ្នាក់លើឲ្យចាប់ទៅជនក្បត់អ៊ីចឹងណ៎ា មិនដឹងមួយណាផង។ ប៉ុន្តែមកច្រើនតែពួកសន្តិសុខស្រុកអ៊ីអ៊ីចឹង វាមកហើយ ចុះមកចាប់។ ដឹងតែប៉ុណ្ណឹង។

[០៩:៤៥:២៦]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកបាននិយាយថា គេហៅថាជាជនក្បត់ ហើយលោកក៏ថាដែរថាគេចោទថាជា<ភ្នាក់ងារ> សេ.អ៊ី.អា<> ជាដើមនោះ។ ដូច្នេះខ្ញុំចង់ដឹង ថាតើលោកដឹងទេថាពួកគាត់ហ្នឹងបានធ្វើអ្វីដែរ ទើបគេចាត់ទុកពួកគាត់ហ្នឹងថាជា<ភ្នាក់ងារ> សេ.អ៊ី.អា<> អីជាដើមនោះ?

**ឆ៖** ការពិតពួកគាត់អត់មានដឹងអីផង ប្រជាជនធម្មតាមានដឹងអី គេចេះតែចោទទៅ។ ប្រជាជនសាមញ្ញធម្មតា មានទៅចេះធ្វើអី។

**ស៖** ខ្ញុំគិតថាមុននេះបន្តិច លោកបាននិយាយថា អ្នកត្រូវគេចាប់ខ្លួនគឺមានទាំងមេសាសនា ក៏ដូចជាមនុស្សធម្មតា។ <ផ្តោតទៅលើមេដឹកនាំសាសនា តើអ្នកទាំងនោះរួមមាន>ហាជី, កឹម, តួន ជាដើម<>ទេ<ដែលលោកបាននិយាយពីខាងដើមនោះ>?

**ឆ៖** ហាជី, កឹម, តួនអស់ហើយ ចាប់ទាំងអស់ មានសល់មួយផង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01216697



**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាការចាប់ខ្លួន<អ្នកទាំងនោះមានអ្វីប៉ះពាល់ដល់ខ្លួនលោក និង>អ្នកដែលលោកស្គាល់<> ឬក៏អ្នកដែលលោក<បាននិយាយជាមួយ>នៅក្នុងភូមិជំនីកនេះ?

**ឆ៖** ស្គាល់បានច្រើនពេក ស្គាល់មិនអស់ទេ ចាប់មិនមែនម្នាក់ពីរឯណា រាប់សិបនាក់នោះ។

**ស៖** ឥឡូវនេះយើងនិយាយអំពីផលប៉ះពាល់ចំពោះអ្នកភូមិ តើអ្នកភូមិគាត់មានអារម្មណ៍ថាគាត់មានសន្តិសុខ មានសុវត្ថិភាព ឬក៏អត់ទេ?

**ឆ៖** អ្នកភូមិគឺអត់មានសន្តិសុខ អត់មានសេរីភាពទេ មានការទុក្ខកង្វល់រាល់យប់ រាល់ថ្ងៃអ៊ីចឹង អត់មានពេលណាសប្បាយអីអ៊ីចឹង។

[០៩:៤៨:០២]

**ស៖** ខ្ញុំចង់និយាយអំពីប្រធានបទនៃការតស៊ូបះបោរនៅកោះផល ហើយស្វាយឃ្លាំង។ លោកប្រាប់ថានៅពេលនោះ គេអត់ឲ្យលោកចេញពីភូមិទេ ប៉ុន្តែខ្ញុំចង់សួរថា តើលោកបានឃើញ ឬក៏បានឮការវាយប្រហារគ្នានៅកោះផល និងស្វាយឃ្លាំង ឬក៏តើលោកដឹងអំពីផលប៉ះពាល់ណាមួយដែលកើតឡើងពីការតស៊ូបះបោរនោះដែរឬទេ?

**ឆ៖** នៅកោះផលឮកាំភ្លើង។ បើនៅស្វាយឃ្លាំងអត់ឮទេ។ កោះផលវាជិត ដល់អ៊ីចឹងឮផ្ទុះអាវុធ បាញ់គ្នាហ្នឹង ប៉ុណ្ណឹង។

**ស៖** តើលោកបានឃើញកប៉ាល់ ឬក៏កាណូតយោធាដែរឬទេ<>នៅតាមទន្លេមេគង្គ<នៅពេលនោះ>? ប្រសិនបើលោកបានឃើញ តើលោកឃើញប្រហែលប៉ុន្មានដែរ<ហើយតើពួកគេធ្វើអ្វី>?

**ឆ៖** កប៉ាល់យោធាវាបើកចុះឡើងរហូត ច្រើនដែរ។ ច្រើនតែបើកពីក្រចេះទៅកំពង់ចាមអ៊ីចឹង បើកកាត់ទន្លេហ្នឹង ប៉ុណ្ណឹងឯង។

**ស៖** តើលោកឃើញកប៉ាល់យោធាហ្នឹងឃើញជាញឹកញាប់ ឬមួយក៏យ៉ាងម៉េចដែរ គឺថាឃើញតាំងពីមុនមានការបះបោរ ឬក៏<>ទើបតែឃើញនៅពេលដែលមានការបះបោរតស៊ូនោះទេ?

**ឆ៖** គ្មានទេ បះបោរហើយ បានចេញមកច្រើនកប៉ាល់ហ្នឹង។ ពីមុនមានមួយៗទេ ដល់បះបោរកប៉ាល់វាមកចល័តរហូត ប៉ុណ្ណឹង។

**ស៖** ឥឡូវនោះខ្ញុំចូលទៅ<>និយាយអំពី<រយៈពេល>ក្រោយការបះបោរនៅកោះផល។ តើខ្មែរក្រហមមានចាត់ការអ្វីដែរ<នៅភូមិជំនីករបស់លោក> ក្រោយពីការបះបោរ<>ហ្នឹង?

[០៩:៥០:៤៤]

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** កាលភូមិជំនីកនេះ គេអត់ទាន់ធ្វើអីទេ។ គេយកតែពួកកោះផលទេ ជម្លៀសយកទៅណាទៅណី ខ្ញុំអត់ដឹងផង។ ចេញពីភូមិទាំងអស់ ស្ងាត់ឈឹង។

**ស៖** ខ្ញុំគិតថា លោកបានលើកឡើងពីខាងដើមរួចមកហើយ។ សូមកែតម្រូវខ្ញុំផង បើសិនជាខ្ញុំយល់ច្រឡំ ពាក់ព័ន្ធទៅនឹងប្រជាពលរដ្ឋនៅភូមិជំនីក ដែលត្រូវជម្លៀសចេញពីភូមិនៅពេលណាមួយនោះ ប្រហែលជាទៅឲ្យធ្វើការនៅបាត់ដំបង ឬទៅនៅកន្លែងណាមួយ។ តើលោកអាចជម្រាបជូនតុលាការបានទេ <តើវាកើតឡើងនៅពេលណា ហើយសូមលោករៀបរាប់>អំពីព្រឹត្តិការណ៍<នោះផង>?

**ឆ៖** ការពិតឆ្លើយថា យកទៅបាត់ដំបង អត់មានយកទេ ដាក់នៅខាងកំពង់ធំវិញ។ ប្រជាជនយកពីជំនីកទៅឆ្នាំ៩៦ *(ស៊ីក)* បាទ ប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

ឆ្នាំណា យកទៅឆ្នាំណា? ៩៦ ឬក៏ឆ្នាំណាច្បាស់លាស់? ម៉េច៩៦ មានហេតុការណ៍អីកើតឡើង៩៦? កុំៗអាលទាន់! មើល៍។

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឥឡូវសុំទោស ៧៦ – ឆ្នាំ១៩៧៦ កាលហ្នឹង។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** តើប្រជាជនចាមទាំងអស់នៅក្នុងភូមិជំនីក <>ត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅកំពង់ធំ ឬក៏គេបញ្ជូនតែប្រជាជន<>មួយចំនួនទេ?

[០៩:៥២:៤៨]

**ឆ៖** ទៅកំពង់ធំ មានតែភូមិហ្នឹងទេ យកតាំងពីស្រុកឆ្លងទៅ ជម្លៀសទៅនុ៎ងដែរ។ កាណូតគេបើកឆ្លងកាត់តាមហ្នឹង ប៉ុណ្ណឹង។

**ស៖** ក្នុងចំណោមនុ៎ង មានរូបលោកម្នាក់ដែរទេ?

**ឆ៖** ពេលហ្នឹងអត់មានទេ ឆ្នាំ១៩៧៨បានមាន ចុងក្រោយនេះ។

**ស៖** ឥឡូវនេះខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ពីសក្ខីកម្មរបស់លោក។ តើលោករស់នៅភូមិជំនីកចាប់ពីពេលដែលខ្មែរក្រហមចូលទៅដល់ រហូតដល់ខ្មែរក្រហមជម្លៀស<លើកចុងក្រោយ>នៅក្នុងឆ្នាំ១៩៧៨ឬ?

**ឆ៖** បាទ រស់រហូត។ តាំងពីនោះរហូតដល់ថ្ងៃរំដោះតែម្ដង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគួរតែជំទាស់តាំងពីមុននេះបន្តិចឯណោះ។ តំណាងសហព្រះរាជអាជ្ញារងនេះបានសួរថា នៅពេលដែលខ្មែរក្រហមចូលទៅដល់។ មិនដឹងថា តើសំណួរគាត់ហ្នឹង គាត់ចង់សួរដើម្បីតែសួរសាក្សី ឬក៏ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ<ពិត ដែលខ្មែរក្រហមបានចូលទៅដល់ស្រុកក្រូចឆ្មារតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០>។

[០៩:៥៥:៤០]

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំយល់ឃើញ ខ្ញុំសួរសាក្សីដោយយោងទៅលើការដឹងរបស់គាត់។ គាត់បានប្រើប្រាស់<ពាក្យថា ខ្មែរក្រហម ជាច្រើនដងនៅ>ក្នុងចម្លើយរបស់គាត់។ <ដូច្នេះខ្ញុំសួរគាត់ដោយផ្អែកទៅលើការយល់ដឹងរបស់គាត់ថាតើ ពាក្យថា ខ្មែរក្រហម មានន័យថាម៉េច?> ហើយបើសិនជាមេធាវីការពារក្តីចង់សួរចំណុចនេះ គឺថាចាំដល់ពេលគាត់ទៅ។

**លោក វ៉ិចទ័រ កូប៉េះ**

ប្រហែលជាការជំទាស់របស់ខ្ញុំមិនច្បាស់ទេ។ ខ្ញុំមិននិយាយពីអង្គភាពខ្មែរក្រហមទេ ខ្ញុំនិយាយពីកាលបរិច្ឆេទនៅក្នុងឆ្នាំ១៩៧០ <ស្រុកក្រូចឆ្មារបានធ្លាក់ទៅក្រោមការកាន់កាប់របស់ខ្មែរក្រហមរួចហើយនៅ>ឆ្នាំ១៩៧០ <មិនមែនដូចសាក្សីនិយាយថា ឆ្នាំ១៩៧៥ ទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចំណុចនេះ តើគ្រាន់តែជាការយល់ឃើញ ឬក៏យ៉ាងណា <វាដូចជាការបញ្ចេញមតិ ច្រើនជាងការជំទាស់> ដោយសារថាសំណួរបានសួររួចទៅហើយ? ហើយលោកអាចសួរសំណួរបញ្ជាក់ចំណុចនេះឡើងវិញ នៅពេលដល់វេនលោកសួរ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកទើបតែជម្រាបជូនតុលាការថា លោករស់នៅភូមិជំនីកហ្នឹងរហូតដល់ឆ្នាំ១៩៧៨។ តើមានប្រជាជនចាមប៉ុន្មាននាក់<នៅសល់ជាមួយលោក នៅក្នុង>ភូមិ<ជំនីក>រហូតដល់ឆ្នាំ៧៨<>?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** អត់បានដឹងច្បាស់ទេ។ ដឹងរស់នៅបានច្រើនគ្នា ប៉ុន្តែអត់ដឹងប៉ុន្មាន អត់ដឹងប៉ុន្មាននាក់ អត់មានធ្វើរបាយការណ៍អីផង។

[០៩:៥៦:២៤]

**ស៖** សូមប្រាប់មកខ្ញុំផង បើលោកយល់ថា លោកមិនអាចឆ្លើយនឹងសំណួររបស់ខ្ញុំបាន។ តើចំនួនប្រជាពលរដ្ឋនៅភូមិជំនីកហ្នឹង គេបញ្ជូនចេញឲ្យទៅធ្វើការហ្នឹងប៉ុន្មានភាគរយដែរ <៥០>ភាគរយ ឬ<តិចជាង ឬក៏ច្រើនជាង៥០ភាគរយ>?

**ឆ៖** បាទ ប្រហែល៥០ភាគរយ។

**ស៖** ខ្ញុំសូមសួរលោកសំណួរមួយខ្លីទេ ដោយសារក្នុងចម្លើយរបស់លោកលើកទី១ គឺឯកសារ E3/5209 ERN អង់គ្លេស 00242067, បារាំង 00293936, ខ្មែរ 00218536។ នេះគឺអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ "ក្រោយមកគេឲ្យខ្ញុំទៅឃ្វាលគោ និងចូលធ្វើការនៅកង<ពលតូច>ចល័ត។ គេឲ្យខ្ញុំធ្វើការនៅទីនេះរហូតដល់៧៨។ ហើយក្រោយមកគេចាត់ឲ្យខ្ញុំចូលទៅធ្វើការក្នុងព្រៃ។ កន្លែងនោះគឺនៅជិតបឹងក្រចាប់ ហើយក្រុមគ្រួសារខ្ញុំក៏<ប្ដូរទៅ>រស់នៅទីនោះដែរ ប៉ុន្តែធ្វើការនៅការដ្ឋាន<> ខុសៗគ្នា។" បញ្ចប់ការដកស្រង់។ សូមលោកជម្រាបជូនតុលាការថា ព្រឹត្តិការណ៍នេះ វាពិតជាអីចឹងមែនទេ? តើ<ពីបឹងក្រចាប់ទៅភូមិជំនីកមានចម្ងាយប៉ុន្មានដែរ>?

**ឆ៖** បាទ ទៅនុ៎ងមែន។ មនុស្សជាច្រើនណាស់ដែលទៅ មួយស្រុកក្រូចឆ្មារមកទាំងអស់។

**ស៖** តើបឹងក្រចាប់នេះ ស្ថិតនៅក្នុងស្រុកណាដែរ នៅក្នុងស្រុកក្រូចឆ្មារ ឬក៏ក្នុងស្រុកណា?

**ឆ៖** នៅក្នុងស្រុកត្បូងឃ្មុំ សួង។

**ស៖** ដូច្នេះតើបឹងក្រចាប់នេះ មានចម្ងាយប៉ុន្មានពីភូមិជំនីក?

**ឆ៖** ប្រហែលជា១០០គីឡូហើយមើលទៅ។

[០៩:៥៩:១៦]

**ស៖** ហើយតើលោកនៅធ្វើការនៅឯបឹងក្រចាប់ហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** រយៈពេល៣ខែ ជំនាន់ហ្នឹងគេចាត់តាំងឲ្យទៅធ្វើការលើកទំនប់ហ្នឹង ៣ខែ។

**ស៖** ហើយក្រោយរយៈពេល៣ខែនេះមក តើលោកត្រឡប់មកភូមិជំនីកវិញឬ?

**ឆ៖** បាទ គេបញ្ជូនមកភូមិវិញ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ហើយក្នុងអំឡុងពេលដែលលោកនៅឯបឹងក្រចាប់ តើពេលហ្នឹងលោកនៅក្នុងកង<ពលតូច>ចល័ត ដូចដែលលោកបញ្ជាក់នៅក្នុងចម្លើយរបស់លោកនេះឬ?

**ឆៈ** ហ្នឹងហើយ ការពិតហើយនៅក្នុងកងចល័ត។

**សៈ** តើក្រោយពេលដែលលោកត្រឡប់មកភូមិជំនីកវិញ លោកនៅតែក្នុងកង<ពលតូច>ចល័តដដែលហ្នឹង ឬ<លោកត្រូវបានគេឲ្យចេញពីកងនោះ>?

**ឆៈ** បាទ នៅក្នុងកងចល័តដដែល។

**សៈ** ហើយពេលដែលលោកត្រឡប់មកភូមិជំនីក លោកបន្តនៅក្នុងកង<ពលតូច>ចល័តនេះដដែល អ៊ីចឹង តើលោកធ្វើការអ្វីដែរ ក្រោយពេលដែលត្រឡប់មកភូមិវិញ ហើយក៏នៅតែកង<ពលតូចចល័ត>ដដែលហ្នឹង តើធ្វើការងារអ្វីដែរ?

**ឆៈ** នៅកងចល័តដដែល គេឲ្យមកលើកទំនប់នៅក្រោយភូមិវិញ នៅគេហៅកណ្ដុរ។ កណ្ដុរនៅក្រោយភូមិជំនីកហ្នឹង លើកទំនប់វិញទៀត។

[១០:០១:២២]

**សៈ** ហើយតើអ្នកនៅក្នុងកង<ពលតូច>ចល័តជាមួយលោកហ្នឹង គឺអ្នកទាំងអស់នោះសុទ្ធតែជាចាម ឬក៏សុទ្ធតែជាខ្មែរ ឬក៏មានទាំងចាម ទាំងខ្មែរ?

**ឆៈ** នៅចម្រុះគ្នា ទាំងចាម ទាំងខ្មែរ ប៉ុន្តែមេចល័តហ្នឹងខ្មែរ ប្រធានកងចល័តហ្នឹង។

**សៈ** បាទ សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅប្រធានបទមួយថ្មីទៀត <> តើលោកនៅនឹកឃើញទេថា <នៅពេលណាមួយ>គេមានចាប់កម្មាភិបាល<>ភូមិភាគបូព៌ា<ជាច្រើន>ដែរទេ?

**ឆៈ** មាន។ កាលហ្នឹងវាសង្គ្រាមមួយ ដូចភូមិភាគកណ្ដាលនិងបូព៌ា។ គេមកបោសសម្អាតខាងកម្មាភិបាលបូព៌ាហ្នឹង ហើយឃើញគេចាប់ ខាងបូព៌ាគេបាក់ទ័ពបាក់អី ទម្លាក់កាំភ្លើងពេញភូមិអ្នកស្រុកមានមែនកាលនុ៎ង។ គេថាខាងបូព៌ាក្បត់នឹងអង្គការ ដល់អ៊ីចឹងគេមកបោសសម្អាតខាងបូព៌ាទៅ។ ប៉ុណ្ណឹង។

**សៈ** ធ្វើម៉េចបានលោកដឹងថា មានសង្គ្រាមរវាងភូមិភាគបូព៌ា និងភូមិភាគកណ្ដាល <ហើយនិងការបោសសម្អាតភូមិភាគបូព៌ា ដោយភូមិភាគកណ្ដាលនោះ>?

**ឆៈ** ពេលហ្នឹងស្លៀកពាក់ដូចតែគ្នា។ ដល់គេមកសួររកថា ឃើញពួកអាក្បត់បូព៌ាទៅណាអស់ហើយ អីណាណីនុ៎ង។ ប៉ុន្តែខាងនុ៎ងគេរត់អស់ហើយ នៅតែសួររក -- សួរប្រជាជនថា មានឃើញមាន

ខ្លាំងអត់។ ការពិតស្ទៀកពាក់ពណ៌ដូចតែគ្នាហ្នឹង តាមបាញ់គ្នារហូត។ ដល់ខាងបូព៌ាគេរត់អស់ទៅ នៅខាងណា ភូមិភាគកណ្ដាល គេមកបោសសម្អាត។ ប៉ុណ្ណឹង អត់ដឹង។

**ស៖** <ក្រោយ>ការបោសសម្អាតនេះ លោកដឹងថា អ្នកណាមកត្រួតត្រាភូមិភាគបូព៌ា លោកដឹងទេ?

**ឆ៖** គ្រាន់តែដឹងថា អង្គការមកពីភូមិភាគកណ្ដាល គេថាប៉ុណ្ណឹង។ មកគ្រប់គ្រងខាងបូព៌ា។

[១០:០៤:១៦]

**ស៖** ខ្ញុំចង់សួរលោកពីចំណុចមួយដែលលោកឆ្លើយនៅក្នុងចម្លើយលើកទី២របស់លោក។ លោកប្រធាន ប្រហែលជាខ្ញុំសូមការអនុញ្ញាតអានសម្រង់ចេញពីចម្លើយលើកទី២របស់គាត់ ដើម្បីជួយរំឭកដល់ការចងចាំរបស់គាត់ គឺឯកសារ E3/8735, ERN អង់គ្លេស 00722241, ខ្មែរ <00716487> និងបារាំង 00727597។ នៅក្នុងកិច្ចសម្ភាសន៍លើកទី២ លោកបានឆ្លើយថា៖ “តាម ពិត កែ ពក ធ្វើជាមេភូមិភាគកណ្ដាល ប៉ុន្តែក្រោយពីចាប់អ្នកបូព៌ា កែ ពក ត្រូវបានចាត់តាំងឲ្យមកគ្រប់គ្រងភូមិភាគនេះតែម្ដង។” តើចំណុចនេះជាចំណុចដែលលោកចងចាំដូច្នោះមែន? ហើយតើវាជួយរំឭកដល់ការចងចាំរបស់លោកនោះដែរទេ?

**ឆ៖** បាទ ពេលហ្នឹង ប៉ុល ពក ដឹងគេគ្រប់គ្រងមែន ក៏មិនមែនទេ ប៉ុន្តែឮតែឈ្មោះ ថាអ្នកដឹកនាំធំបូព៌ាគឺមាន ប៉ុល ពក អីអ៊ីចឹង។ ប៉ុន្តែអត់ដែលឃើញមុខគាត់ម៉េចផង ឮតែឈ្មោះគេនិយាយតៗគ្នាប៉ុណ្ណឹង។

**ស៖** ខ្ញុំឮសួរលោកទើបតែនិយាយពីឈ្មោះ ប៉ុល ពត។ <តើនេះជាអ្វីដែលលោកចង់និយាយឬ>?

**ឆ៖** ប៉ុល ពក។

**ប្រធានអង្គជំនុំ៖**

ម្ដងទៀត! ម្ដងទៀត!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឈ្មោះ ប៉ុល ពក -- អំ! មិនមែន ប៉ុល ពត ទេ, ប៉ុល ពក – ពកអ្ហ៎! “ប៉ុល” ដូចគ្នាប៉ុន្តែ “ពក” ប្រហែលជាប្រធានភូមិភាគកណ្ដាល។ ប៉ុណ្ណឹង ឮហើយនិងដឹង។

[១០:០៦:៣២]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** មិនថ្វីទេ ប៉ុន្តែបុគ្គលម្នាក់ដែលលោកនិយាយឈ្មោះនេះ គឺថាជាអ្នកគ្រប់គ្រងភូមិភាគកណ្ដាល។ តើលោកធ្លាប់ដឹងថាគាត់ទៅពិនិត្យមើលស្រុកក្រូចឆ្មារដែរទេ?

**ឆ៖** ធ្លាប់ឮគេប្រាប់ថាមក ប៉ុន្តែយើងអត់ដែលដឹងថាមកនៅត្រង់ណា ឮថាមកពិនិត្យមើល។

**ស៖** តើលោកស្ដាប់ឮថា គាត់មកពិនិត្យមើលស្រុកក្រូចឆ្មារហ្នឹងនៅពេលណា?

**ឆ៖** ខែអត់ចាំ ចាំឆ្នាំ១៩៧៨។

**ស៖** ខ្ញុំចង់យល់ឲ្យបានច្បាស់លាស់អំពីឈ្មោះដែលលោកទើបតែលើកឡើងអម្បាញ់មិញនេះ តាមដែលខ្ញុំយល់ លោកមិនចង់និយាយសំដៅទៅលើ ប៉ុល ពត ទេ គឺលោកថា ប៉ុល ពក គឺដោយមានឈ្មោះ ពក ពីខាងក្រោយ ប៉ុល ដូចគ្នាអ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ ហ្នឹងហើយ ឈ្មោះហ្នឹង។ មិន ប៉ុល ពត ទេ, ប៉ុល ពក ហ្នឹង។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំយល់ឃើញថា ពេលវេលាក៏ជិតដល់ពេលសម្រាកហើយ ហើយប្រហែលជាអាចឈប់ ស្នើសុំការឈប់សម្រាកត្រឹមនេះសិន ដោយឲ្យសាក្សីគាត់ពិនិត្យមើលចម្លើយរបស់គាត់ឲ្យបានច្បាស់ មុននឹងខ្ញុំបន្តការតាំងសួរតទៅទៀត ដើម្បីសួរឲ្យច្បាស់នៅចំណុចចុងក្រោយនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ ម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់ និងម្ភៃប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៩ នាទី ដល់ម៉ោង ១០:២៨ នាទី)*

[១០:២៧:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ត្រាវីស ហ្វារះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារះ**

**ស៖** លោកសាក្សីមុនពេលឈប់សម្រាក យើងបាននិយាយគ្នាអំពីអត្តសញ្ញាណរបស់លេខាភូមិភាគកណ្តាល ហើយលោកគិតថាឈ្មោះរបស់គាត់គឺឈ្មោះប៉ុល ពក។ ឥឡូវនេះលោកមានឱកាសពិនិត្យមើលចម្លើយលើកទីពីររបស់លោកដែលលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេត។ ខ្ញុំសូមដកសម្រង់ចេញពីចម្លើយរបស់លោកហ្នឹង ERN ជាអង់គ្លេសគឺ 00722241, ខ្មែរ <00716487>, បារាំង 00727597 ។ នេះគឺអ្វីដែលលោកឆ្លើយនៅក្នុងចម្លើយនេះ៖ "តាមពិត កែ ពក គឺជាលេខាភូមិភាគកណ្តាល ប៉ុន្តែក្រោយពីពេលចាប់អ្នកភូមិភាគបូព៌ា <កែ ពក> ក៏ត្រូវបានចាត់តាំងឲ្យគ្រប់គ្រងភូមិភាគនេះ <សំដៅទៅលើភូមិភាគរបស់លោក>។" ក្រោយខ្ញុំអានសម្រង់នេះរួចហើយ តើវាជួយរំឭកដល់ការចងចាំរបស់លោកដែរទេ?

[១០:២៩:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសាក្សី! លោកមេ -- លោកវ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នៅខាងមុខខ្ញុំនេះ ខ្ញុំមានឯកសារមួយផ្សេងទៀតគឺ E3/5209.1 ERN អង់គ្លេស 01153931, បារាំង 01152702 និងខ្មែរ 01151671 ដែលជាផ្នែកមួយនៃប្រតិចារឹក <របស់> ឯកសារ<សំឡេង> <D125/104R>។ ហើយអ្នកបកប្រែក៏បាននិយាយទៅកាន់<>សាក្សីដូចតទៅ៖ "ប៉ុន្តែលោកបាននិយាយថា <លោកបានឮរឿងនេះ> លោកបាន<ឮ>ច្បាស់ណាស់ថាឈ្មោះនៅក្នុងអង្គប្រជុំហ្នឹងគឺឈ្មោះ កែ ពក"។ ហើយសាក្សីលោកឆ្លើយថា៖ "ពេលនោះគេហៅថា ប៉ុ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01216705



ល ពក មិនមែន កែ ពក ទេ ហើយជាប្អូន<ប្រុស>របស់ ប៉ុល ពត មួយ<> ពត, មួយ <> ពក។ អ៊ីចឹងអ្នកទាំងពីរហ្នឹងបងប្អូនគ្នា?" សាក្សីឆ្លើយថា៖ "ជាបងប្អូនគ្នា។" ដូច្នេះដើម្បីប្រតិចារឹក ខ្ញុំក៏សូមបង្ហាញឯកសារនេះជូនទៅសាក្សីផងដែរដើម្បីបញ្ជាក់ឲ្យបានច្បាស់មើលថាតើ ប៉ុល ពត និង កែ ពក នេះពិតជាបងប្អូនបង្កើតនឹងគ្នាដូចដែលលោកឆ្លើយ ឬក៏យ៉ាងណា?

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមទោស ខ្ញុំមិនដែលបានឃើញឯកសារដែលមេធាវីលើកឡើងទេ។ ហើយហាក់បីដូចជា<បញ្ជាក់ថា>សាក្សីនិយាយថា ប៉ុល ពក។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ដូច្នេះម្តងទៀតលោកសាក្សី ដូច្នេះហាក់បីដូចជាក្នុងចម្លើយមួយនោះ លោកឆ្លើយថា លេខាភូមិភាគបូព៌ាថា ប៉ុល ពក <តាមដែលលោកបាននិយាយនៅថ្ងៃនេះ>។ ហើយនៅក្នុងចម្លើយមួយនេះលោកឆ្លើយថា កែ ពក។ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀត បើលោកអាចឆ្លើយបានហ្នឹង ឈ្មោះហ្នឹងឲ្យពិតប្រាកដទៅ ឈ្មោះអ្វី?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឈ្មោះពិតប្រាកដ អត់ដឹងច្បាស់ដែរ ព្រោះអ្នកស្រុកជួនកាលគេហៅ កែ ពក ជួនកាលហៅ ប៉ុល ពក។ តាមអ្នកស្រុកគេនិយាយណ៎ា ប៉ុន្តែយើងអត់ដឹងប្រវត្តិត្រកូលគាត់ច្បាស់លាស់ទេ។

**ស៖** បាទ សូមអរគុណចំពោះការបញ្ជាក់នេះ។ ប៉ុន្មាននាទីមុននេះ ខ្ញុំបានសួរលោកអំពីការធ្វើដំណើររបស់គាត់ទៅកាន់ភូមិភាគបូព៌ា ហើយលោកឆ្លើយថាលោកបានឮ<>ថាគាត់ក៏ទៅពិនិត្យមើលស្រុកក្រូចឆ្មារ<ប្រហែលពីរបីដង>។ ឥឡូវហ្នឹង ខ្ញុំសូមប្តូរទៅប្រធានបទមួយថ្មីទៀត គឺប្រធានបទពាក់ព័ន្ធទៅនឹង<បុគ្គល>ឈ្មោះ ពក នេះ<បានកោះហៅមេដឹកនាំ>ភូមិភាគបូព៌ា<ទៅប្រជុំនៅភូមិភាគកណ្តាល។> <តើ>លោកដែលឮ<>ឈ្មោះ ពក <កោះហៅមេដឹកនាំ>ភូមិភាគបូព៌ា<ទៅប្រជុំនៅភូមិភាគកណ្តាលដែរឬទេ>?

[១០:៣៣:១៥]

**ឆ៖** បាទ អត់ដែលឮ។ អត់ដែលផង។ ឮតែជួនកាលគេហៅថា ប៉ុល ពក ជួនកាលហៅ កែ ពក ទៅពិនិត្យ មកពីភូមិភាគកណ្តាលហ្នឹង។ ឮប៉ុណ្ណឹង សូមអស់ហើយ។

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកនូវអ្វីដែលលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍លើកទី២ ដែល

01216706



លោកទើបតែមានឱកាសអានមុននេះ ERN ជាភាសាអង់គ្លេស 00722241, ខ្មែរ 00716487, បារាំង 00727597។ អ្នកស៊ើបអង្កេតបានសួរលោកអំពីឈ្មោះ<ពក>នេះ តើគាត់មកភូមិភាគបូព៌ាញឹកញាប់ប៉ុនណាដែរ? ហើយលោកបានឆ្លើយថា គាត់មកពិនិត្យមើលស្រុកក្រុចឆ្មារពីរបីដង ហើយបន្ទាប់មកលោក<>និយាយដូចតទៅ សូមដកស្រង់៖ "ប៉ុន្តែជារឿយៗ ខ្ញុំដឹងថាគាត់កោះហៅថ្នាក់ដឹកនាំភូមិភាគបូព៌ាឲ្យទៅប្រជុំនៅភូមិភាគកណ្តាល គឺនៅខេត្តកំពង់ធំ ដែលគាត់ជាលេខារបស់ភូមិភាគនេះ។" បញ្ចប់ការដកស្រង់។ ក្រោយស្តាប់ចម្លើយរបស់លោកហើយនេះ តើវាជួយរំឭកដល់ការចងចាំរបស់លោក<ទេ? តើលោកដឹងអ្វីខ្លះអំពីឈ្មោះ> ពក នេះបានកោះហៅ<មេដឹកនាំ>ភូមិភាគបូព៌ាហ្នឹងឲ្យមកប្រជុំនៅខេត្តកំពង់ធំ? <>

**ឆ៖** បាទ ចងចាំ។ ពេលហ្នឹងមេឃុំជំនីកប្រាប់ មេឃុំគេប្រាប់ថា គេទៅប្រជុំនៅស្អី ប្រាប់កងចល័តទាំងអស់ គេថាប្រជុំនៅភូមិភាគកណ្តាល ជាមួយប្រធានភូមិភាគ កែ ពក ហ្នឹង។ ប៉ុណ្ណឹង គ្រាន់ដឹងប៉ុណ្ណឹង។

[១០:៣៥:២៨]

**ស៖** តើការកោះហៅប្រជុំដែលលោកបានឮថា គាត់នេះបានកោះហៅកម្មាភិបាលភូមិភាគបូព៌ាឲ្យទៅប្រជុំនៅភូមិភាគកណ្តាលហ្នឹង តើលោកឮប៉ុន្មានដងដែរ?

**ឆ៖** ឮតែម្តង។ គេប្រជុំប្រាប់កងចល័តទាំងអស់ គេថាទៅប្រជុំនៅភូមិភាគកណ្តាល។

**ស៖** ដូច្នេះលោកបានឆ្លើយថា មេឃុំជំនីកបានប្រាប់<លោកថា>មេកងចល័ត<ត្រូវ>ទៅប្រជុំនៅភូមិភាគកណ្តាល។ តើមានអ្វីកើតឡើងក្រោយពីនេះមកទៀត?

**ឆ៖** ពេលហ្នឹងអត់មានចល័តទៅប្រជុំទេ។ គេទៅតែថ្នាក់ដឹកនាំគេ មេឃុំ ហើយនិងចៅហ្វាយស្រុកអីទេ ប្រធានតំបន់អីអ៊ីចឹងណា។ គ្រាន់តែមេឃុំប្រជុំប្រាប់ ប្រធានចល័តហ្នឹងគេមិនបាននៅ គេទៅប្រជុំនៅភូមិភាគកណ្តាល។ ប៉ុណ្ណឹងហ្នឹងទេ សូមអស់។

**ស៖** ចុះលោកវិញ មានបានទៅប្រជុំនឹងគេទេ?

**ឆ៖** អត់បានចូលរួមទេ។ បើយើងអត់មានតួនាទីអីនឹងគណៈនេះផង យើងប្រជាពលរដ្ឋ បានអីចូលរួម អត់ទេ អត់មាន។ សូមអស់។

**ស៖** តើលោកមានបានធ្វើដំណើរទៅ<>កាន់ទីកន្លែងប្រជុំហ្នឹង<ជាមួយអ្នកណា>ដែរទេ?

**ឆ៖** បាទ ពេលហ្នឹងមេសង្កាត់ហ្នឹងឲ្យខ្ញុំជូនជាមួយចៅហ្វាយស្រុកហ្នឹង បើកកាណូតទៅស្ទឹង

ត្រង់។ បើកស្ទឹងត្រង់ ដល់ស្ទឹងត្រង់ គេអត់ចេះជិះម៉ូតូ ក៏ឲ្យពឹងខ្ញុំជូន ជិះម៉ូតូទៅ ម៉ូតូពីរគ្រឿង។ ដល់ពេលទៅប្រជុំភូមិភាគហ្នឹង សម្រាប់តែ កែ ពក គេប្រកាស ខ្ញុំឮតាមមីក្រូ ខ្ញុំនៅក្រៅកន្លែងប្រជុំហ្នឹង នៅក្រៅសាលាប្រជុំ ឮតាមមីក្រូ គេប្រកាសប្រាប់ថា ហៅកងនេះទាំងអស់មកប្រជុំ ខាងភូមិភាគបូព៌ាហ្នឹងដែលបោសសម្អាតហើយ គេចាត់តាំងអ្នកថ្មីទៅកាន់កាប់នៅហ្នឹង នៅភូមិភាគបូព៌ាហ្នឹង។ សុទ្ធមកពីភូមិភាគកណ្ដាលទាំងអស់។ ប៉ុណ្ណឹងឯង។

[១០:៣៨:៣១]

**ស៖** សូមអរគុណចំពោះការបញ្ជាក់នេះ។ សូមជម្រាបជូនតុលាការម្តងទៀតមើល៍ <តើនរណា >ដែលលោកជិះម៉ូតូ<ដឹក>ទៅកាន់ទីកន្លែងប្រជុំហ្នឹង? <តើជា>មេឃុំ ឬក៏<>មេស្រុក?

**ឆ៖** បាទ សូមជម្រាប មេឃុំទេ។ មេស្រុកគេជិះ មាននីវសារគេផ្សេង។ ជិះជាមួយមេឃុំ ៗ អត់ចេះជិះម៉ូតូ។

**ស៖** លោកចាំឈ្មោះមេឃុំដែលលោកជិះម៉ូតូ<ដឹក>ទៅកាន់ទីកន្លែងប្រជុំនោះទេ?

**ឆ៖** បាទ នៅចាំ ឈ្មោះ ហ៊ុន, ឈ្មោះ ហ៊ុន។

**ស៖** តើ ហ៊ុន ជាមេឃុំជំនីក ឬក៏ជាមេឃុំណាផ្សេង?

**ឆ៖** មេឃុំជំនីក ទើបចាត់តាំងថ្មី ពេលគេបោសសម្អាតហើយ ក៏ដាក់មេឃុំហ្នឹងមកបណ្ដោយតែប៉ុណ្ណឹង មេឃុំជំនីក។ សូមអស់។

**ស៖** តើលោកអាចជម្រាបជូនតុលាការឲ្យច្បាស់លាស់បានទេ តើកិច្ចប្រជុំនេះគេរៀបចំធ្វើនៅកន្លែងណា? នៅក្នុងទឹកដីឃុំណា ស្រុកណា <>តំបន់ណា <និងភូមិភាគណា>បើលោកអាចនៅចាំបាន?

**ឆ៖** នៅចាំបាន គេហៅថា កំពង់ថ្ម នៅកំពង់ថ្ម ការដ្ឋានគេនៅកំពង់ថ្ម។

[១០:៤០:២៦]

**ស៖** ហើយតើកំពង់ថ្មនេះចំណុះឲ្យស្រុកណា តំបន់ណា <និងភូមិភាគណា>ដែរ?

**ឆ៖** ជំនាន់ហ្នឹងគេប្រាប់ថា នៅតំបន់ភូមិភាគកណ្ដាលហ្នឹងហើយ កំពង់ថ្ម ភូមិភាគកណ្ដាល។ សូមអស់។

**ស៖** លោកទើបតែបានឆ្លើយថា លោកមិនបានចូលរួមប្រជុំទេ ដោយសារលោកជាប្រជាជនធម្មតា ប៉ុន្តែលោកបាននិយាយថា លោកបានស្ដាប់ឮសួរអ្វីដែលគេនិយាយ ដោយសារគេនិយាយតាមមីក្រូ។ តើលោកអាចរៀបរាប់បានទេ អង្គប្រជុំនុ៎ង គេប្រជុំនៅក្នុងអគារបែបណាដែរ? អគារនោះសាង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សង់ពីអ្វីដែរ? <តើជញ្ជាំងអគារនោះធ្វើពីអ្វី?>

**ឆ៖** អគារហ្នឹងសាងសង់ពីថ្ម ប្រក់ក្បឿងលើ បង្អួចឈើ។

**ស៖** ចុះលោកវិញ លោកស្ថិតនៅឯណាដែរ នៅពេលគេប្រជុំហ្នឹង លោកនៅខាងក្រៅ <ជញ្ជាំង> ឬក៏លោកនៅខាងក្រោមផ្ទះហ្នឹងតែម្តង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** នៅជិតផ្ទះហ្នឹង ជិតផ្ទះគេប្រជុំនៅសាលាគេប្រជុំហ្នឹង ប៉ុន្តែអត់មានក្នុងសាលា នៅក្រៅសាលា។

[១០:៤២:០៨]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ដោយសារថា វាជាផ្ទះថ្ម ធ្វើម៉េចបានជាលោកស្តាប់ឮពីខាងក្រៅទៅបាន?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាល់ទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ផ្ទះនុ៎ងប្រក់ក្បឿងមិនជិតដូចនេះទេ ផ្ទះថ្មទេ ប្រក់ក្បឿង ហើយនិងជញ្ជាំង បង្អួចវាឈើ ដល់អ៊ីចឹងនិយាយមីក្រូមក អាចឮមកក្រៅបាន។ សូមអស់។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ហើយមុននេះបន្តិច លោកបានឆ្លើយថា លោកស្តាប់ឮសួរតាមមីក្រូថា គ្រប់<>តំបន់ទាំងអស់<ពីភូមិភាគបូព៌ា>បានចូលរួមប្រជុំក្នុងអង្គប្រជុំនោះ។ អ៊ីចឹងសូមលោករៀបរាប់ឲ្យបានលម្អិតបន្តិចមើលថា <តើ>គេនិយាយ<>អ្វីខ្លះ<អំពីអ្នកចូលរួមក្នុងការប្រជុំនោះ>?

**ឆ៖** ពេលអង្គប្រជុំឮមកតាមមីក្រូខាងក្រៅហ្នឹង គេដាក់ផែនការឲ្យខាងមេថ្មីមកកាន់នៅភូមិភាគបូព៌ាហ្នឹង ឲ្យនៅអនុវត្តផែនការរបស់អង្គការ។ គេសួរថា បានប៉ុន្មានភាគរយហើយកន្លែងមួយៗដែលយកពួកចាមទៅកម្ទេចនុ៎ង។ រួចខ្លះគេថាបាន៥០ភាគរយ កន្លែងខ្លះ៣០ភាគរយ តាមចម្លើយរបស់គេ នៅកន្លែងប្រជុំហ្នឹង។ ហើយមួយទៀតអង្គការគេដាក់ផែនការមកថា កម្ទេចឲ្យអស់នៅភូមិភាគបូព៌ា

ហ្នឹង កុំថាតែចាម ខ្មែរចល័តអឹមក កម្ទេចអស់ ព្រោះខាងនោះ វាពួកក្បត់អង្គការ។ ហើយមួយទៀតថា អង្គការឧបត្ថម្ភអឹមកហ្នឹង គ្មានសល់ទេ ពួកហ្នឹងវាយកទៅលក់ឲ្យយួនអីអឹចឹងណ៎ា ពួកកម្មាភិបាលនៅបូព៌ានេះ។ ដល់អឹចឹងវាបោសសម្អាតអស់ហើយកម្មាភិបាលហ្នឹង នៅតែប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងក្បត់ជាមួយអង្គការហ្នឹង ក៏យកមកកម្ទេចដែរ។ ដឹងតែប៉ុណ្ណឹង សូមអស់យោបល់ហើយ ឈប់អស់ហើយ។

[១០:៤៤:៣៨]

**ស៖** លោកទើបតែបានឆ្លើយថា នៅក្នុងអង្គប្រជុំគេនិយាយថា កម្មាភិបាលថ្នាក់ទាបត្រូវតែអនុវត្តគោលនយោបាយរបស់អង្គការ ពាក់ព័ន្ធទៅនឹងការកម្ទេចជនជាតិចាម។ តើលោកនៅចាំ ឬក៏អាចជម្រាបជូនតុលាការបានទេ អ្នកណានិយាយពីចំណុចនេះ?

**ឆ៖** ពេលឮក្នុងនុំងគេឧទ្ទេសនាមថា មេគេឈ្មោះ ឧទ្ទេសនាមថា អង្គការឈ្មោះ កែ ពក ឬក៏ពក ហ្នឹងហើយ ដែលឧទ្ទេសនាមឲ្យខាងក្រោមអនុវត្តផែនការហ្នឹង។ សូមអស់។

**ស៖** ហើយលោកក៏បាននិយាយថា មានអ្នកខ្លះនិយាយថាសម្រេចផែនការបាន៥០ភាគរយ អ្នកខ្លះទៀតថាបាន៨០ភាគរយហើយ។ តើអ្នកណាដែលលោកបានស្ដាប់ឮ និយាយថាគេបានអនុវត្តផែនការបក្សហ្នឹងបាន៥០ភាគរយ បាន៨០ភាគរយហ្នឹង?

**ឆ៖** ខ្ញុំបានឮមេឃុំជំនីក គេប្រាប់ថាអនុវត្តបាន៥០ភាគរយ។ រួចអ្នកផ្សេងទៀត ចម្លើយមក ខ្ញុំអត់ក្ដាប់បានសំឡេងរបស់គេទេ អត់ដឹងខាងណាផង។ សូមអស់។

**ស៖** តើលោកមានបានស្ដាប់ឮអំពីកាលបរិច្ឆេទកំណត់ការអនុវត្តផែនការហ្នឹងដែរទេ នៅក្នុងអង្គប្រជុំហ្នឹង?

[១០:៤៦:៥២]

**ឆ៖** ឮតែអឹចឹង ឮគេប្រាប់ថា ឲ្យមកវិញអនុវត្តផែនការឲ្យបាន១០០ភាគរយជូនបក្សអឹចឹង ជូនអង្គការអឹចឹង។ ឮប៉ុណ្ណឹង សូមអស់។

**ស៖** តើលោកនៅនឹកឃើញទេ អង្គប្រជុំហ្នឹងគេប្រជុំអស់រយៈពេលប៉ុន្មានម៉ោងដែរ?

**ឆ៖** បាទ រយៈពេលប្រហែលជា២ម៉ោងជាងដែរ។ សូមអស់។

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកអំពីព្រឹត្តិការណ៍ក្រោយអង្គប្រជុំនោះរួចមក។ ក្រោយពីអង្គប្រជុំមក ថាតើលេខាឃុំជំនីកហ្នឹង មាននិយាយប្រាប់លោកអំពីអ្វីខ្លះដែរទេ <គឺ>អំពី<កិច្ចប្រជុំ ឬអ្វី>ដែល

លោកបានឮ នោះខ្លះដែរទេ?

**ឆ៖** បាទ គាត់បាននិយាយប្រាប់ថា បានឮអីកុំនិយាយឲ្យសោះ ដាំដើមគ។ និយាយតែប៉ុណ្ណឹង។ ដឹងអី ឮអី កុំឲ្យនិយាយ។ សូមអស់។

**ស៖** តើ<គាត់>ដឹងថា លោកជាជនជាតិចាមដែរទេ?

**ឆ៖** ដំបូងអត់ដឹងទេ គាត់អត់ដឹងថាខ្ញុំចាម។ គាត់មកឃើញខ្ញុំ គាត់ដូចថា រាប់អានអី ចេះតែប្រើទៅនេះ ទៅនោះទៅ។ ប្រើបើកកាណូតជូនគាត់ទេ កាលហ្នឹងជូនទៅ អត់មានពីណាបើកកាណូត កាណូតដាក់ម៉ូតូទៅពីរ ព្រោះកាលនោះ វាអត់មានផ្លូវទៅ សម្រាប់ទៅហ្នឹង ទាល់តែជិះកាណូតទៅបាន មានផ្លូវទៅនោះ។ អស់ប៉ុណ្ណឹង សូមអស់ហើយ។

**ស៖** លោកបានជម្រាបជូនតុលាការមុននេះបន្តិចថា <គាត់បានប្រាប់លោកថា> កុំឲ្យនិយាយរឿងហ្នឹងឲ្យសោះកុំប្រាប់អ្នកណាឲ្យសោះ។ <តើលោកស្ដាប់តាមបញ្ជានោះ ឬក៏លោកប្រាប់អ្នកណាគេពីអ្វីដែលលោកបានឮនោះ>?

[១០:៤៩:២២]

**ឆ៖** ប្រាប់ផ្ទាល់។

**ស៖** នៅពេលដែលលោកវិលត្រឡប់មកឃុំជំនីកវិញ តើលោកមានប្រាប់អ្នកណាម្នាក់អំពី<អ្វីដែលលោកបានឮក្នុង>អង្គប្រជុំនេះដែរទេ?

**ឆ៖** បាទ ខ្ញុំក៏បានប្រាប់មិត្តភក្ដិខ្ញុំ ប្រធានចល័ត ថាសភាពការណ៍នោះអត់ស្រួលទេ ឲ្យគាត់ហ្នឹងលែលក រត់ចូលព្រៃរត់អីទៅណា។ ប្រាប់គាត់ គាត់ក៏បានរត់ចូលព្រៃទៅ វាផ្អើលនៅនុំង ផ្អើលឆរពីឃុំហ្នឹងទៅ។

**ស៖** ហើយនៅពេលដែលលោកថា លោកប្រាប់មិត្តភក្ដិ<លោកនៅក្នុង>កង<ពលតូច>ចល័តហ្នឹង លោកប្រាប់ទាំងចាម ទាំងខ្មែរនៅក្នុងកង<ពលតូចចល័ត>ហ្នឹង ឬក៏ថាលោកប្រាប់តែក្រុមចាម ឬក៏ប្រាប់តែក្រុមខ្មែរ ឬក៏ប្រាប់ទាំងខ្មែរ ទាំងចាម?

**ឆ៖** ខ្ញុំប្រាប់ទាំងខ្មែរ ទាំងចាម។ ទាំងប្រធានខ្មែរ ទាំងចល័តចាម ប្រាប់ឲ្យប្រយ័ត្នខ្លួនអ៊ីចឹង ព្រោះសភាពការណ៍អត់ស្រួលទេ គេប្រុងយកទៅសម្លាប់ហើយ។ អស់ហើយ សូមអស់។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកអំពីព្រឹត្តិការណ៍កើតមានឡើងនៅក្នុងភូមិជំនីក ពីរបីថ្ងៃក្រោយកិច្ចប្រជុំនោះរួចមក តើលោកអាចជម្រាបជូនតុលាការបានទេ មានព្រឹត្តិការណ៍អ្វីកើតឡើង<នៅភូមិជំនីក>

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពីរបីថ្ងៃក្រោយកិច្ចប្រជុំនោះរួចមក?

**ឆ៖** ក្រោយពីកិច្ចប្រជុំមក ផែនការគេរៀបចំដឹកជម្លៀសប្រជាពលរដ្ឋចាមនៅហ្នឹងបន្ថែមទៀត។

[១០:៥១:២៣]

**ស៖** ហើយថាតើលោកអាចជម្រាបជូនតុលាការឲ្យលម្អិតបន្តិចបានទេ តើគេ<ជម្លៀស>ដោយរបៀបណា? <ឧទាហរណ៍ តើ>អ្នកណាដែលបានប្រាប់លោកថា <លោក>ត្រូវជម្លៀស<នោះ>?

**ឆ៖** ពេលជម្លៀស គេមានកាណូតគេធំៗ សម្រាប់មកដឹកជញ្ជូនតាមមាត់ទន្លេ។ ពេលហ្នឹងជម្លៀសប្រជាពលរដ្ឋហើយ ខ្ញុំចុងក្រោយទេ។ ជម្លៀសពីរបីសាហើយ បានខ្ញុំគេឲ្យជម្លៀសទៅតាមក្រោយគេ។ ជម្លៀសទៅបាត់ ជម្លៀសទៅបាត់ អត់ឃើញមកវិញផង។ រួចអីវ៉ាន់ដែលស្រីហើយនិងកូនក្មេងតូចៗ បង្វេចខោអាវអី ឃើញអត់មានទៅដោយខ្លួនផង ឃើញនៅទុកគរនៅកន្លែងពាណិជ្ជកម្មនៅស្ទឹងត្រង់។ សូមអស់។

**ស៖** លោកបានឆ្លើយថា ការជម្លៀសហ្នឹងគឺជម្លៀសទាំងមនុស្សពេញវ័យ <ស្ត្រី> ក៏ដូចជាក្មេងៗ។ តើការជម្លៀសនេះ តាមដែលលោកចាំហ្នឹង ជម្លៀសតែចាមសុទ្ធ ឬខ្មែរសុទ្ធ ឬក៏ជម្លៀសហ្នឹងមានទាំងខ្មែរ ទាំងចាម ចម្រុះគ្នា?

**ឆ៖** ពេលជម្លៀស ភាគច្រើនចាម ខ្មែរតិចតួច ដែលខ្មែរដែលទៅពីភ្នំពេញទៅហ្នឹង វាប៉ុន្មានប្រហែលមួយភាគរយអីទេ។ ខុសពីហ្នឹងភាគច្រើនចាមហើយ ហើយនិងស្រីក្មេងតូចៗហ្នឹង មានទៅជម្លៀសទៅទាំងអស់។ ទាំងកូនក្មេង ទាំងទារកតូចតាចហ្នឹង យកទាំងអស់។ សូមអស់។

**ស៖** ហើយជនជាតិចាមដែលនៅសេសសល់ក្នុងឃុំជំនីក លោកគិតទៅ គឺមានប្រហែលប៉ុន្មានភាគរយ<នៃជនជាតិចាម>ដែលនៅសេសសល់នៅក្នុងភូមិជំនីកហ្នឹង <ត្រូវបានជម្លៀសនៅពេលនោះ>?

[១០:៥៣:៤០]

**ឆ៖** ក្រោយមកនៅសល់ប្រហែល៣០ភាគរយប៉ុណ្ណឹង ជម្លៀសចេញអស់។ នៅចុងក្រោយប្រហែល៣០ភាគរយ។

**ស៖** ហើយនៅពេលដែលលោកនិយាយថា នៅសល់ប្រហែល៣០ភាគរយ គឺ៣០ភាគរយហ្នឹងជាចំនួនប្រជាជនដែលនៅសេសសល់<>មុនការជម្លៀស ឬក៏៣០ភាគរយហ្នឹង ជាចំនួនតួលេខនៅសល់ក្រោយការជម្លៀស<ដែលលោកកំពុងនិយាយនៅពេលនេះ>?

**ឆ៖** នៅសល់ក្រោយការជម្លៀស សល់ការជម្លៀស។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅថ្ងៃដែលខ្លួនលោកផ្ទាល់ ត្រូវបានគេជម្លៀសដែរនោះ តើលោក<ដឹងយ៉ាងម៉េចថា លោកត្រូវចាកចេញនៅថ្ងៃនោះ?> អ្នកណា<ជាអ្នកប្រាប់លោក>?

**ឆ៖** មាន។ មានគេហៅ មេឃុំរងគេហ្នឹង អ្នកភូមិហ្នឹង គេប្រាប់ថាត្រូវការជម្លៀសហើយ។ ដល់អ៊ីចឹងខ្ញុំគេប្រាប់ឲ្យជម្លៀស ក៏ទៅតាមគេទៅ។ ខ្ញុំទៅហ្នឹងទៅចុងក្រោយហើយ។ ដល់ពេលទៅដល់ហ្នឹង ខ្ញុំប្រាប់មិត្តភក្តិ សភាពការណ៍អត់ល្អទេ មើលទៅ ត្រូវលោតទឹកលោតទៅ។ ស្រាប់ដល់ខាងនុំងភ្លាម នៅខាងស្ទឹងត្រង់ហ្នឹង ស្រាប់តែខាងយោធា ប៉ុល ពត ហ្នឹងគេចុះមកចង គេសូមចងប្រជាពលរដ្ឋហ្នឹង។ អង្គការស្នើចង៥នាទី ដើម្បីការពារសុវត្ថិភាពជូនពុកម៉ែបងប្អូន មុននឹងឡើងទៅលើគោក ព្រោះកន្លងមកមានខ្មាំងដោយមកជាមួយនាំគ្រោះថ្នាក់ដល់បងប្អូនអីអ៊ីចឹង។ អ៊ីចឹងគេសុំសូមសំណូមពរទៅប្រជាពលរដ្ឋហ្នឹង សុំចង។ ប្រជាពលរដ្ឋហ្នឹងក៏ឯកភាពឲ្យចងទៅ។ រួចចងហ្នឹងមិនមែនខ្សែម្នាក់មួយទេ។ ខ្សែ១០ម៉ែត្រ ២០ម៉ែត្រ គេចងតគ្នាបណ្តោយ។ រួចខ្ញុំឮសភាពអ៊ីចឹង ក៏ខ្ញុំក៏លោតចុះទឹកជាមួយមិត្តភក្តិទៅ ចុះទៅវាបាញ់អីផងៗ ចេះតែមុជហែលទៅ រួចខ្លួន។ ប៉ុណ្ណឹងបាទ។

[១០:៥៦:០៦]

**ស៖** តើលោកអាចជម្រាបជូនតុលាការឲ្យលម្អិតបន្តិចបានទេថា <តើមានអ្វីកើតឡើងក្រោយពេល>លោកលោតចុះទឹក? <តើមានការប៉ុនប៉ងទប់ស្កាត់មិនឲ្យលោកគេចខ្លួនដែរទេ?>

**ឆ៖** ព្រោះសភាពការណ៍គេចងយើងហើយ យើងទៅទុកចិត្តអីទៀត។ ឮតែចងជិតដល់ក្រោយហើយ ចងបានជាងពាក់កណ្តាល ខ្ញុំនៅក្រោយកាណូតហ្នឹង លោតបណ្តោយ។ យករួចខ្លួនសិន។ បើមិនលោតហ្នឹង មិននៅដល់សព្វថ្ងៃទេ នៅ ទៅបាត់ហើយ។ នាំគ្នាពីរបីនាក់ហ្នឹង បានហែលទឹកមកជាមួយគ្នាហ្នឹង។ អាមិត្តភក្តិមួយចំនួនលោតដែរ ប៉ុន្តែជាប់ចំណង មិនដឹងជាទៅណាទេ អត់ឃើញរហូតទាល់តឡូវហ្នឹង។ សូមអស់ហើយ ប៉ុណ្ណឹង។

**ស៖** តើមានជនប្រដាប់អាវុធ<>ដែរទេ នៅលើកាណូតហ្នឹង ពេលដែលគេ<>ដឹកជញ្ជូន <លោក>ទៅស្ទឹងត្រង់នុំង?

**ឆ៖** បាទ មាន។ ក្នុងកាណូតមួយមានពីរទៅបីនាក់។ ទៅដល់ស្ទឹងត្រង់បានមានកម្លាំងគេច្រើននៅចាំទទួល យកទៅបន្ត។ មានកងយោធារបស់ ប៉ុល ពត ហ្នឹងជាច្រើននៅចាំនៅខាងស្ទឹងត្រង់ ស្រុកស្ទឹងត្រង់នុំងណា។ សូមអស់។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពី -- សូមសួរមួយសំណួរទៀតសិន។ <តើជនប្រដាប់អាវុធមាន

បាញ់លោកទេ ក្រោយ>ពេលដែលលោកលោតចេញពីកាណូតហ្នឹង<>?

**ឆ៖** បាទ មានបាញ់ជាច្រើនគ្រាប់ដែរ។ ខ្ញុំមុជទឹកទៅបាញ់អត់ត្រូវ យប់ងងឹតផង បាញ់ព្រាវពេលនុំងយប់ម៉ោងប្រាំបួនយប់ហើយ។ សូមអស់។

[១០:៥៨:១៦]

**ស៖** ខ្ញុំនឹងចូលមកនិយាយព្រឹត្តិការណ៍នៅស្ទឹងត្រង់ ក្រោយពេលលោករត់គេចខ្លួន ដើម្បីឲ្យយល់ដំណើររឿងលោកឲ្យបានពេញលេញតែម្តង។ លោកបានឆ្លើយថា អនុប្រធានឃុំហ្នឹងបានប្រាប់<លោកថា លោកត្រូវ>ជម្លៀសខ្លួននៅថ្ងៃនោះ។ តើលោកនៅចាំឈ្មោះអនុប្រធានឃុំនោះដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់ ៖**

**ឆ៖** ឈ្មោះ អ៊ូន មួយ, ឈ្មោះ ហៅ មួយអនុឃុំនុំង។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ចុះតើពួកគាត់ទាំងពីរនេះមានប្រាប់លោកថា លោកត្រូវជម្លៀសដោយសារមូលហេតុអីដែរទេ?

**ឆ៖** អត់ប្រាប់មូលហេតុផង ថាអង្គការឲ្យជម្លៀស ប្រាប់តែប៉ុណ្ណឹង ជម្លៀស។ សូមអស់។

**ស៖** តើលោកមានបានឃើញអ្នកណាម្នាក់បដិសេធមិនព្រមឲ្យគេជម្លៀសទៅដែរទេ? ហើយបើសិនជាមានមែន តើមានអ្វីកើតឡើងដល់អ្នក<នោះ>?

[១០:៥៩:៣៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** មាន។ ជួបហេតុផលនៅជំនីក មុននឹងឡើងទូកហ្នឹង នុំងអត់ព្រមឡើង ចាប់មកកាត់កនៅនឹងមុខហ្នឹងបណ្តោយ បោះទៅទឹកទន្លេបណ្តោយ ដែលម្នាក់ប្រឆាំងមិនព្រមជម្លៀស។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** នេះគឺជាចំណុច ដែលលោកបានឆ្លើយនៅជាមួយនឹងមន្ត្រីស៊ើបអង្កេតនៃការិយាល័យសហ

ចៅក្រមស៊ើបអង្កេត<លោកហាក់ដូចជាបង្ហាញថា ហេតុការណ៍នោះបានកើតឡើងចំពោះមនុស្សម្នាក់> ។ តើរឿងហ្នឹងកើតមានតែចំពោះអ្នកតវ៉ាម្នាក់ហ្នឹងទេ ឬក៏មានអ្នកតវ៉ាផ្សេងទៀតដែរ?

**ឆ៖** អត់មានអ្នកសុំ អ្នកហ៊ានតវ៉ាផង មានតែម្នាក់ហ្នឹង អត់ព្រម។ ព្រោះយកតែគាត់ ក្រុមគ្រួសារគាត់អត់ទៅ គាត់អត់ព្រមទៅ។ ដល់អ៊ីចឹងវាត្រូវនេះ ពេលសម្លាប់ហ្នឹងក៏មិនមែនចាមដែរ ខ្មែរចិនទេ កាត់ចិន។ វាអត់ព្រមទៅហ្នឹង។ ដល់ពួកចាមខ្លាចគេចេះតែទៅហើយ គេប្រើទៅណាទៅ ម្នាក់ហ្នឹងគេអាងតែគេចិនខ្មែរហ្នឹង គ្រួសារគេអត់ទៅ គេអត់ទៅ។ អត់ទៅ យោធាចាប់ផ្តើមចាប់ផ្តើមធ្វើបាបបណ្តោយ សម្លាប់បណ្តោយ។

**ស៖** តើលោកឡើងជិះកាណូតហ្នឹងនៅភូមិជំនីក ឬក៏ឡើងជិះនៅទីតាំងផ្សេង?

[១១:០១:២១]

**ឆ៖** គេឲ្យដើរពីភូមិជំនីកមក ១ទីតាំងភូមិស្វាយដំណាក់ ចម្ងាយពីភូមិមក១គីឡូដី។ បើនៅមាត់ទន្លេ គេហៅភូមិវត្តដំណាក់ ស្វាយដំណាក់។ គេប្រមូលប្រជាពលរដ្ឋដែលត្រូវជម្លៀសមកជុំគ្នានៅក្នុងវត្តស្វាយដំណាក់ហ្នឹងបណ្តោយ។ សូមអស់។

**ស៖** ដូច្នេះតើមានប្រជាជនប៉ុន្មាននាក់ដែលដើរជាមួយលោកពីភូមិជំនីកមក<>ស្វាយដំណាក់?

**ឆ៖** វា៤០០ទៅ៥០០នាក់ មកម្តង កាណូតបួនប្រាំ។ សូមអស់ហើយ។

**ស៖** នៅពេលលោកទៅដល់វត្តស្វាយដំណាក់<តើក្រុមលោក>ដែលមានប្រជាជន៤០០ទៅ៥០០នាក់ហ្នឹង <>ចូលរួមជាមួយនឹងប្រជាជនក្រុមផ្សេង<ទៀត> ឬក៏<ក្រុមតែមួយទេនៅ>វត្តស្វាយដំណាក់ហ្នឹង?

**ឆ៖** អត់មានផ្សេងទេ មានតែយកពីភូមិជំនីកមកដាក់ហ្នឹងទាំងអស់។ គ្រាន់តែទីតាំងវា កន្លែងវា ១ឲ្យយកមកដាក់កន្លែងហ្នឹងដើម្បីស្រួលត្រួតពិនិត្យឈ្មោះដែលត្រូវទៅជម្លៀសដាក់។ នៅស្វាយដំណាក់ហ្នឹង នៅជិតសាលាឃុំវានៅនុំង មុខសាលាឃុំ វាយកសាលាឆាន់ធ្វើមន្ទីរឃុំរបស់វាបណ្តោយ។ សូមអស់។

**ស៖** លោកទើបតែជម្រាបជូនតុលាការថា អ្នកដែលគេជម្លៀសទៅជាមួយលោកហ្នឹង គឺភាគច្រើនហ្នឹងគឺជាជនជាតិចាម ហើយ<ខ្មែរ>ដែលទៅពីភ្នំពេញនេះមានចំនួនតិចណាស់។ អ៊ីចឹងបើសិនណាជាលោកបំបែកអ្នកដែលគេត្រូវជម្លៀសចេញជាពីរក្រុម តើចាមមានប៉ុន្មានភាគរយ និងប្រជាជនខ្មែរដែលចេញទៅពីភ្នំពេញនេះមានប៉ុន្មានភាគរយ?

**ឆ៖** ប្រជាជនចាមវាមានដល់៩៨ភាគរយ។ ប្រជាជនខ្មែរយកពីភ្នំពេញ ប្រហែល២ភាគរយអីហ្នឹង។ សេសសល់ពីស្លាប់នៅតាមព្រៃមក គាត់យកមកដាក់នឹងភូមិ។ សូមអស់។

[១១:០៤:២៤]

**ស៖** ខ្ញុំចង់សួរលោកទាក់ទងទៅនឹងការស្តាប់ចម្លើយទី១គឺ E3/5209 អង់គ្លេសមានលេខ 00242068, ខ្មែរមានលេខ 00218538 និងបារាំងមានលេខ 00293938។ គេបានសួរអំពីអ្វីដែលកើតឡើង<>ក្រោយពេលដែលលោកទៅកិច្ចប្រជុំនោះ ហើយលោកបានឮមនុស្សម្នាក់ឈ្មោះ ពក បាននិយាយ លោកបាននិយាយថា "មនុស្សរាប់ពាន់នាក់ ទាំងស្រី ទាំងប្រុស ទាំងក្មេង <>ត្រូវបាន គេជម្លៀស<ចេញទៅមុនខ្ញុំ">។ ដូច្នេះខ្ញុំចង់សួរថា តើលោកចង់និយាយហ្នឹង មានន័យថាម៉េច ដែលលោកថាមនុស្សរាប់ពាន់នាក់នោះ?

**ឆ៖** មនុស្សអ្នកពាន់នាក់ គោលការណ៍គេជម្លៀសតាំងពីយូរមកហើយ មិនឥឡូវណា។ ជម្លៀសរាប់នេះ រាប់ម៉ឺនហើយ តាំងពីនោះមក។ បួនដប់ថ្ងៃ ជម្លៀសបួនប្រាំកាណូតអីអ៊ីចឹងទៅ។ ជម្លៀសជារៀងរហូត អត់មានពេលឈប់ផង។ សូមអស់។

**ស៖** នៅពេលដែលលោកមកដល់ស្វាយដំណាក់ហ្នឹង តើលោកឡើងជិះកាណូតភ្លាមៗ ឬមួយក៏<មានអ្វីកើតឡើង>នៅកន្លែងហូបអាហាររួមគ្នា<ដែលលោកបានជួបជុំគ្នា មុនពេលលោកឡើងជិះកាណូតនោះ?>?

**ឆ៖** មានហូបអាហារអីទេ គេឲ្យអង្គុយចាំ។ ដល់ម៉ោងយប់ព្រលប់ បានគេឲ្យចេញ។ គេខ្លាចបែកការណ៍ដែរ តាមមើលទៅ ដោយសារយប់បានឲ្យចេញឡើងកាណូត។ អង្គុយចាំដល់ម៉ោង គេឲ្យចេញហ្នឹងហើយ មានធ្វើអីបាន។

[១១:០៦:២០]

**ស៖** លោកនិយាយថា មានកាណូតប្រហែលជាបួនទៅប្រាំកាណូត។ ដូច្នេះខ្ញុំចង់ដឹងថា តើក្នុងមួយកាណូតហ្នឹង មានមនុស្សជិះប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** តាមកាណូតតូចកាណូតធំ មានអា១០០ មាន១៥០, ២០០នាក់ឡើង ប្រភេទកាណូតគេនោះ។ សូមអស់។

**ស៖** ហើយលោកនិយាយថា មានមនុស្សប្រដាប់អាវុធនៅតាមទូក នៅតាមកាណូតនីមួយៗ។ ដូច្នេះតើក្នុងកាណូតនីមួយៗ មានអ្នកប្រដាប់អាវុធហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** មួយកាណូតជូនកាលពីរនាក់ ជូនកាលបីនាក់ វាដាក់តាមកាណូត។ ពេលកំពុងឡើងទៅមើលឃើញវាដាក់ទាហានដាក់អីទៅតាមហ្នឹង។ ពេលកំពុងចុះទៅ វានៅភ្លឺដែរ ប្រហែលម៉ោងប្រាំល្ងាចឃើញគេរៀបចំទាហានតាមកាណូត មានអាកាណូតធំដាក់បីទៅ អាតូចដាក់ពីរទៅ តាមហ្នឹង ប៉ុណ្ណឹង។

**ស៖** តើទាហានប្រដាប់អាវុធហ្នឹង គេកាន់កាំភ្លើងអីដែរ?

**ឆ៖** កាំភ្លើង អា.កា កាំភ្លើងម៉ាក អា.កា៤៧។

**ស៖** ហើយលោកបានប្រាប់យើងថា លោកធ្វើដំណើរតាមកាណូតទៅស្ទឹងត្រង់។ ដូច្នេះខ្ញុំចង់ដឹងថា តើកាណូតទាំងអស់ហ្នឹង គឺធ្វើដំណើរទៅស្ទឹងត្រង់ជាមួយគ្នាដែរឬទេ? ហើយតើគេធ្វើដំណើរក្នុងពេលជាមួយគ្នា ទៅដល់កន្លែងហ្នឹង ក្នុងម៉ោងជាមួយគ្នា ឬមួយក៏យ៉ាងម៉េចដែរ?

[១១:០៨:១៧]

**ឆ៖** ទៅម៉ោងជាមួយគ្នា។ ដល់ពេលដល់ហ្នឹងគេទុកកាណូត ប្រុសៗទៅក្រោយ។ គេមិនឲ្យឡើង មិនទាន់ឲ្យឡើងគោកទេ ទាល់តែខាងស្រីៗឡើងមុន ជាមួយកុមារតូចតាចហ្នឹង ឡើងមុន។ ដល់ប្រុសឡើងក្រោយ គេចងហើយ បានគេឲ្យឡើងគោក។ បើស្ត្រីមានកូន មានចៅ ឲ្យឡើងធម្មតា។

**ស៖** តើលោកចាំទេថា មាននរណាម្នាក់និយាយថា រកពួកក្បត់អីដែរឬទេនៅពេលនោះ?

**ឆ៖** មាន គេប្រជុំហ្នឹង គេថាអង្គការជម្លៀសបងប្អូនមកខាងភូមិភាគកណ្តាលហ្នឹង ដើម្បីសម្រាលសេដ្ឋកិច្ចនៅខាងបូព៌ា ព្រោះខាងបូព៌ាសុទ្ធតែពួកក្បត់។ អង្គការឧបត្ថម្ភសម្ភារៈដូចជាថ្នាំពេទ្យ ស្បៀងអង្ករ ក្រណាត់អីហ្នឹង ពួកហ្នឹងយកទៅលក់ឲ្យយួនអស់ហើយ។ ដល់អីចឹងពួកអាក្បត់នៅបូព៌ាហ្នឹង កម្មាភិបាលដែលនៅបូព៌ាហ្នឹង ក្បត់អង្គការអស់ហើយ។ អីចឹងអង្គការត្រូវជម្លៀសបងប្អូនមកភូមិភាគកណ្តាលនេះ ដើម្បីសម្រាលសេដ្ឋកិច្ចនៅខាងនេះ។ ប៉ុណ្ណឹងបាទ។

**ស៖** លោកបាននិយាយអំពីក្រុមកម្មាភិបាលដែលមកជួប<លោក>នៅពេលដែលកាណូតហ្នឹង<ទៅដល់>។ <តើលោកអាចពណ៌នាអំពីក្រុមមនុស្សដែលជួបកាណូតនោះបានទេ? ចង់និយាយថា មិនមែនអ្នកដែលធ្វើដំណើរជាមួយលោកនៅលើទូកនោះទេ។ ប៉ុន្តែគឺអ្នកដែលនៅរង់ចាំលោក។> តើពួកគាត់ស្លៀកសម្លៀកបំពាក់អីបែបណាដែរ? <តើពួកគេកាន់អ្វី? ហើយតើពួកគេមាននិយាយអីខ្លះ>?

**ឆ៖** គាត់ស្លៀកពាក់យោធា។ ខោអាវយោធារបស់ខ្មែរក្រហមបណ្តោយ។ អស់ប៉ុណ្ណឹង។

**ស៖** តើពួកគេនុ៎ង មានកាន់កាំភ្លើង កាន់អាវុធអីដែរទេ?

**ឆ៖** មានៗអាវុធគ្រប់ដៃ។ អស់ហើយ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សះ** តើអាវុធនុំងប្រភេទអីដែរ?

**ឆះ** ដូចយើងបញ្ជាក់ខាងដើមអំមិញ ប្រភេទអា.កា ហ្នឹងហើយ មានប្រើអីខុសពីហ្នឹងទេ ខាងនុំង។ សូមអស់ហើយ។

[១១:១១:០៧]

**សះ** បន្ទាប់ពីវៀតណាមចូលមកដល់ប្រទេសកម្ពុជា តើលោក<ធ្លាប់>ត្រឡប់ទៅភូមិជំនីកវិញ ឬមួយក៏យ៉ាងម៉េច?

**ឆះ** ពេលខ្ញុំទៅដល់ភូមិជំនីកហ្នឹង ក៏ខ្ញុំប្រមូលកងចល័តទាំងអស់ហ្នឹង ហើយនិងប្រជាជនទាំងអស់ហ្នឹងឲ្យរត់ចូលព្រៃ កុំឲ្យមានការយកទៅសម្លាប់ទៀត។ ប្រជាជនទាំងអស់ក៏តាមខ្ញុំ រត់ទៅទាំងអស់គ្នា នៅក្នុងព្រៃនោះ។ រួចដល់អ៊ីចឹង រត់ទៅប្រហែល រយៈប្រហែលតែ២ខែ បានកងទ័ពរំដោះ គេមករំដោះបាន។ នៅក្នុងព្រៃអស់រយៈ២ខែ សម័យនុំង។ សូមអស់។

**សះ** ខ្ញុំនឹងនិយាយអំពីការរត់គេចរបស់លោក លោកនិយាយថា លោក<>លោតចូលទៅក្នុងទឹក <ហើយគេបាញ់កាំភ្លើងជាច្រើនគ្រាប់ តែមិនត្រូវលោក>។ <បន្ទាប់មកតើលោកធ្វើអ្វី?> តើលោកទៅណាដែរ?<>ទន្លេមេគង្គជាទន្លេធំមួយ<តើលោកធ្វើយ៉ាងម៉េច>? <តើទីតាំងបន្ទាប់កន្លែងណាដែលលោកត្រូវទៅ>?

**ឆះ** ពេលលោតចូលក្នុងទន្លេហ្នឹង ផុតពីកាណូតហ្នឹងឆ្ងាយហើយ ក៏ខ្ញុំហែលទៅខាង។ ហែលខាងហ្នឹង ឃើញ រកយកស្នឹតោងមិនបាន មាននេះជាមួយមិត្តភក្តិខ្ញុំហ្នឹង ឃើញថាខ្មោចអណ្តែតទឹកពេញទន្លេហ្នឹង នៅអែបៗខាងហ្នឹង ក៏នាំគ្នាដោះខោអាវហ្នឹង រុំខ្មោចហ្នឹង តោងហែលទន្លេមកតាមខ្សែទឹកមក។ ប៉ុណ្ណឹង សូមអស់។

[១១:១៣:០៨]

**សះ** ខ្ញុំគិតថា លោកប្រាប់យើងថា ពេលដែលលោកឡើងដល់គោកហើយ លោកទៅ<តាមរក>កងចល័ត<របស់លោក> ហើយបន្ទាប់មកទៀត លោកប្រាប់ពួកនៅក្នុងកងចល័តហ្នឹង។ ដូច្នេះខ្ញុំចង់ដឹងថា តើលោកប្រាប់គេថា យ៉ាងម៉េចដែរ? <តើបន្ទាប់មក អ្នកទាំងអស់គ្នាធ្វើអ្វី>?

**ឆះ** បាទ ខ្ញុំប្រាប់ថា ផែនការគេ អ្នកជម្លៀសទៅហ្នឹង អត់មានរស់ទេ ស្លាប់អស់ហើយ។ កងចល័ត គេហែកក្រុមាប៉ុន្មានបារ នៅចាំចងកងចល័តហ្នឹង។ ដូច្នេះក៏កងចល័តហ្នឹង ឮតែអ៊ីចឹងក៏នាំគ្នារត់ទៅទាំងអស់គ្នាចូលព្រៃទាំងអស់គ្នាទៅ។ ដឹងសភាពការណ៍ថា គេប្រុងយកកងចល័តទាំងអស់ ទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្លាប់ហើយ។ រួចម្យ៉ាងជាក់ស្តែង គេហែកក្រមាថែមទៀត។ នៅក្នុងចល័តដឹងដែរ ប៉ុន្តែអត់ដឹងគេហែកធ្វើអី។ គោលការណ៍គេហែកសម្រាប់ចងកងចល័តហ្នឹង យកទៅកម្ទេចបណ្តោយ។ សូមអស់។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺលោកបាននិយាយអំពីការចូលរួមក្នុងការបះបោរប្រដាប់អាវុធ។ ដូច្នេះតើលោកអាចរៀបរាប់ដោយសង្ខេបបានទេ អំពីការបះបោរប្រដាប់អាវុធរបស់លោកនោះ?

**ឆ៖** ពេលហ្នឹងខ្ញុំពិភាក្សាជាមួយមិត្តភក្តិប្រធានចល័ត។ បើសិនជាយើងមិនតស៊ូបះបោរទេ យើងមានតែស្លាប់ ព្រមទាំងប្រជាជនទៀត។ ដល់អ៊ីចឹងមិត្តភក្តិហ្នឹងសួរថា យើងមានអាវុធមកពីណា? ដល់ប្រជាជននៅក្នុងភូមិនេះ គេប្រាប់ថា អាវុធគាត់ឃើញមានពួក០៩ហ្នឹង យកទៅទម្លាក់ចោលនៅក្នុងអណ្តូង។ ដល់អ៊ីចឹងក្រុមខ្ញុំក៏នាំគ្នាទៅរាវមើលក្នុងអណ្តូងហ្នឹង ក៏ឃើញមានកាំភ្លើង។ កាំភ្លើង មកបាញ់បំបែកផែនការវា កំពុងកៀរប្រជាជនប្រុងយកទៅសម្លាប់ហ្នឹងទាំងកាណូត ក្រុមខ្ញុំក៏បាញ់ទម្លាយឱ្យធ្លាយ កុំឱ្យវាសកម្មភាពបាន។ ទម្លាយអាតាមមាត់ទន្លេហ្នឹង ចតទុកសម្រាប់យកប្រជាជនទៅវ៉ៃចោលហ្នឹង ក៏បាញ់កម្ទេចកាណូតហ្នឹងឱ្យលិចធ្លាយទៅ។ ហើយប្រជាជនទាំងអស់ក៏នាំគ្នារត់ចូលព្រៃអស់ទៅទៅអស់។ រួចក្រោយមក ក្រុមខ្ញុំក៏នៅចេះតែការពារបងប្អូនទៅ កុំឱ្យចូលភូមិ ក្នុងព្រៃអាពត វាអត់ហ៊ានទៅ វាមានកម្លាំងការពារមួយចំនួនហើយ។ យើងមានអាវុធប៉ុន្មាន គ្រាន់តែការពារកុំឱ្យវាដើរទៅកៀរប្រជាជនក្នុងព្រៃទៀត។ ដល់អ៊ីចឹង ប៉ុល ពត អត់ហ៊ានទៅដែរ ក្នុងព្រៃ។ អស់ប៉ុណ្ណឹងបាទ។

**ស៖** នៅក្នុងប្រតិបត្តិការដែលលោករៀបរាប់ហ្នឹង គឺគោលដៅសំខាន់ហ្នឹង គឺគ្រាន់តែរំខានទៅដល់<ការជម្លៀសបន្ថែមទៀត> តើអ៊ីចឹងមែនទេ?

[១១:១៦:១៤]

**ឆ៖** បាទ គ្រាន់តែរាំងផែនការវា កុំឱ្យវាសម្លាប់មនុស្សតទៅទៀត តែប៉ុណ្ណឹង។ អត់មានថាយើងនៅក៏ស្លាប់ដែរ ធ្វើម៉េចតដៃសិនទៅ ឱ្យវារស់មួយរយៈសិនទៅ។ ដល់តស៊ូបានជោគជ័យមែន។ ដល់កងកម្លាំងទ័ពធំរបស់ពីណាពីណីមក ប្រហែលមួយខែពីរខែ ស្រាប់តែពួកងទ័ពមកដល់តំបែរហ្នឹង ក៏នាំប្រជាជនទៅដល់តំបែរនោះ ជួបកងទ័ពដែលរំដោះពីនោះមកទៅ ក៏បានរួចខ្លួនដល់សព្វថ្ងៃទៅ កុំអីហ្នឹងទៅអស់ហើយ គ្មានសល់ទេ ព្រោះវាមកកៀររាល់ថ្ងៃ។ ប៉ុល ពត មកតាមសម្លាប់ប្រជាជនរាល់ថ្ងៃ។ ថ្ងៃណាក៏មានកងឃោធាមករកតាមផ្ទះ ប៉ុន្តែរកអត់ឃើញប្រជាជនចូលព្រៃអស់។ សូមអស់។

**ស៖** មុននេះបន្តិចលោកបាននិយាយថា នៅពេលដែលលោកត្រឡប់ទៅកងចល័តវិញ លោក

ប្រាប់គេថា អ្នកដែលត្រូវគេជម្លៀសជាមួយលោកត្រូវបានគេយកទៅសម្លាប់។ ដូច្នេះខ្ញុំចង់ដឹងថា ហេតុអីបានជាលោកគិតថា អ្នកដែលគេជម្លៀសទៅជាមួយលោកហ្នឹង ត្រូវបានគេយកទៅសម្លាប់បាត់អស់ហើយ?

**ឆ៖** មូលហេតុថាយកទៅសាមុនហ្នឹង អ្នកដែលស្គាល់ខ្ញុំនៅខាងនោះ គេប្រាប់ខ្ញុំថាអ្នកជម្លៀសទាំងប៉ុន្មានហ្នឹង គេយកសម្លាប់អស់ហើយ គ្មានសល់មួយទេ។ រួចពេលហ្នឹងបានខ្ញុំដឹងថា ប៉ុលពត ពិតជាសម្លាប់មែន ដោយសារប្រជាជនដែលគាត់ចងហើយហ្នឹង ដើររអិលស្ពាន កាណូត។ ដល់រអិលទៅធ្លាក់ទៅ ធ្លាក់ទៅ គាត់ជេរថា ដើរភ្លើៗ! គាត់បាញ់ពីលើទៅសម្លាប់ទាំងអស់នៅនុំងបណ្ដោយ។ បានឮអ៊ីចឹង បានខ្ញុំអីនាំគ្នារត់ចុះធ្លាក់ពីលើកាណូត។ គ្រាន់តែគ្នាដើរធ្លាក់ពីលើស្ពានបាញ់សម្លាប់គ្នាដែរ គ្មានជម្លៀសណាទេ។ សូមអស់ប៉ុណ្ណឹង។

[១១:១៨:១៧]

**ស៖** លោកបានប្រាប់ថា លោកនៅក្នុងព្រៃរហូតទៅដល់ពេលគេរំដោះ គឺ<>រហូតដល់ពេលវៀតណាមចូលមកដល់ ទើបលោកត្រឡប់ទៅភូមិរបស់លោក គឺភូមិជំនឹកវិញ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងហើយ។ រំដោះមកបាន បានមកជំនឹកវិញ។

**ស៖** តើលោកអាចប្រាប់បានទេថា <>តើប្រជាជនចាម<ភូមិជំនឹកប្រហែលប៉ុន្មានភាគរយ> ដែលនៅសល់<>នៅពេលដែលលោកត្រឡប់មកវិញក្រោយពេលរំដោះដោយវៀតណាមនោះ?

**ឆ៖** អត់ដឹងច្បាស់ទេនេះ និយាយអត់ច្បាស់ អត់ទាំងហ៊ានឆ្លើយ។ នៅសល់ច្រើនដែរ តែមិនដឹងប៉ុន្មាន។

**ស៖** ក្នុងចំណោមមនុស្សប្រហែលជា<បួន ឬ>ប្រាំ<>រយនាក់ដែលជម្លៀសទៅជាមួយលោកនោះ តើលោក<ដឹងថាបាន>ឃើញអ្នកណា<ម្នាក់ ក្នុងចំណោមអ្នកទាំងនោះ តាមដែលលោកចាំ តើលោកធ្លាប់ឃើញនរណាម្នាក់ក្នុងចំណោមអ្នកទាំងនោះម្ដងទៀតទេ> ក្រោយពេលវៀតណាមចូលមករំដោះ<នោះ>?

**ឆ៖** អត់មានសល់ទេ អស់រលីងហើយ។ ទាំងមុន ទាំងក្រោយ គ្មានមកវិញទេ ទៅអស់។ ពីមុនមករាប់ពាន់ រាប់ម៉ឺននាក់ មុនខ្ញុំ អត់ទាំងឃើញម្នាក់មកវិញផង គឺស្លាប់អស់ហើយ។

**ស៖** តើលោកអាចប្រាប់បានទេ ថាលោកនៅក្នុងភូមិជំនឹកហ្នឹង អស់រយៈពេលប៉ុន្មានដែរ? <តើឆ្នាំណា>ដែលលោកផ្លាស់ទៅក្រចេះ?

**ឆ៖** ខ្ញុំតាំងពីក្មេងមកនៅជំនីករហូត ដល់ក្រចេះទាល់ឆ្នាំ៩១នោះបានទៅ។ ទៅក្រចេះឆ្នាំ១៩៩១ ហ្នឹងហើយ។ តាំងពីកើតមក នៅជំនីករហូត។

[១១:២០:៤៥]

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណអស់លោកសាក្សីដែលបានឆ្លើយទៅសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំសូមបញ្ចប់ការសាកសួររបស់ខ្ញុំ ហើយខ្ញុំបានសន្យាជាមួយខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ថាខ្ញុំទុកពេលគាត់ជូនគាត់២០នាទី។ <ខ្ញុំកត់សម្គាល់ថា ព្រឹកមិញនេះយើងបានចាប់ផ្ដើមយឺតប្រហែល១៥នាទី។ ដូច្នេះខ្ញុំសង្ឃឹមថា ពួកគេនឹងមានពេល២០នាទី សម្រាប់សួរសំណួរ>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញបាទ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ មេធាវីនាំមុខសូមប្រគល់សិទ្ធិនៅក្នុងការសួរនេះ ជូនលោកស្រីមេធាវី ជេត វណ្ណលី ហើយលោកស្រីអាចនឹងប្រើមេធាវី -- អំប្រើរយៈពេលលើសពី២០នាទីនេះ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** នាងខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ សួស្ដីលោកសាក្សី។ លោកបានបញ្ជាក់យ៉ាងច្បាស់នៅចំពោះមុខអង្គសវនាការតាំងពីពេលព្រឹកមក ពីហេតុការណ៍ និងព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងចំពោះលោក។ ឥឡូវខ្ញុំភ្ជាប់ជាមួយនឹងសហព្រះរាជអាជ្ញា ខ្ញុំចង់គ្រាន់ឲ្យលោកបញ្ជាក់ថា តើនៅឆ្នាំណាដែលគេដឹកលោកតាមទូកយកទៅសម្លាប់? ហើយពេលនោះលោកលោតពីទូកដើម្បីរំដោះខ្លួនលោក?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:២២:៣៨]

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឆ្នាំ១៩៨៨ -- អ៎ា ៧៨។

**ស៖** អរគុណលោក។ ហើយខ្ញុំចង់ឱ្យលោកបញ្ជាក់បន្ថែមទៀតថា តើទូកដែលថ្ងៃដែលលោកចេញដំណើរហ្នឹង លោកបានបញ្ជាក់ទៀតថា ការជម្លៀសហ្នឹង គឺជាការជម្លៀសលើកចុងក្រោយ ហើយខ្ញុំចង់ឱ្យលោកបញ្ជាក់ថា តើចំនួនទូកប៉ុន្មានទូកនៅថ្ងៃនុ៎ង? ហើយហេតុអីបានជាពួកហ្នឹងត្រូវការចងលោកដែរ ត្រូវការចង? លោកបានបញ្ជាក់ថា ចងតែប្រុសទេ ស្រី និងកុមារអត់ចងទេ ដូច្នេះហេតុអីបានជាពួកវាទាមទារការចងហ្នឹង? ចាស អរគុណ។

**ឆ៖** ទាមទារការចង ដោយសារកំលោះមានកម្លាំងខ្លាំង។ មនុស្សស្រី មានកម្លាំងអីនឹងតដៃជាមួយក្រុមគាត់។ គឺជម្លៀសមិនមែនចុងក្រោយទេ ចុងក្រោយ ដោយសារខ្ញុំមកវារាំងទប់សភាពការណ៍វាពេលដែលខ្ញុំរួចខ្លួនហ្នឹងមកទេ។ កុំអីនៅបន្តរហូត ទាល់តែអស់ប្រជាពលរដ្ឋនៅខាងបូព៌ានោះ។ ដល់ចុងក្រោយខ្ញុំនិយាយមួយម៉ាត់ចុងក្រោយអំមិញ ចុងក្រោយដល់ខ្ញុំមកក្រោយគេ។ មកមុនៗ វាទៅអស់ហើយ សម្លាប់អស់ហើយ។ ខ្ញុំមកក្រោយគេ បានខ្ញុំទៅវិញ លោតទៅៗ បានរួចខ្លួនហ្នឹង ទៅរៀបរាប់ប្រាប់ខាងប្រធានចល័ត ប្រាប់អីទៅ ឱ្យគេដឹងពីសភាពការណ៍ជម្លៀសហ្នឹង វាមានបញ្ហាអីចឹង។ ក៏នាំគ្នារត់ចូលព្រៃទៅ ទៅរាំងសភាពការណ៍វាជម្លៀសបន្តទៀត ហ្នឹងវាបាននៅទាល់ថ្ងៃហ្នឹង។ បាទ សូមចប់។

**ស៖** អរគុណលោក។ តើលោកមានបានដឹងទេ ថាវាសនារបស់ស្ត្រី និងកុមារដែលគេអត់ចងនោះ តើការសម្លាប់ហ្នឹង វារបៀបម៉េចដែរ លោកមានបានដឹងទេ នៅពេលហ្នឹង?

**ឆ៖** អត់បានដឹងទេ ព្រោះកុមារអី អ្នកស្ត្រីអី គេដាក់ទូកផ្សេង គេអត់មានប្រុសអីទៅជាមួយទេ។ គេយកទៅចុះកន្លែងផ្សេង កន្លែងណា យើងអត់ដឹង ប៉ុន្តែរួមដំណើរទៅជាមួយគ្នាហ្នឹង។

[១១:២៤:៤៤]

**ស៖** ប៉ុន្តែលោកដឹងទេថា ស្ត្រី និងកុមារហ្នឹង ក៏ត្រូវគេយកទៅសម្លាប់ដែរ មែនទេ?

**ឆ៖** បាទ ប្រាកដជាសម្លាប់ហើយ ព្រោះតាំងពីពេលហ្នឹងមកឥឡូវ មិនឃើញមនុស្សណាម្នាក់ដែលឃើញរត់មកវិញផង។ វាអស់រលីងហើយ។

**ស៖** អរគុណលោក។ ខ្ញុំចង់ឱ្យលោកបញ្ជាក់ជូនអង្គសវនាការដែរថា ថាតើការដែលដឹកសម្លាប់

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមទូកហ្នឹង ភាគច្រើនជាប្រជាជនចាម ឬក៏យ៉ាងម៉េចលោក?

**ឆ៖** បាទ ភាគច្រើនចាម ចាមទាំង ចង់១០០ភាគរយ ប៉ុន្តែវាមានខ្លះតិចតួច ១០ភាគរយ, ពីរភាគរយតែប៉ុណ្ណឹងទេ។

**ស៖** អរគុណលោក។ តើលោកមានបានដឹងទេថា ផែនការទាំងនេះ ផែនការដែលលោករៀបរាប់តាំងពីព្រឹកមកនេះ តើផែនការទាំងអស់ហ្នឹងជាបញ្ជារបស់ថ្នាក់ណាដែរ?

**ឆ៖** ឮថាតែអង្គការៗ ដឹងថ្នាក់ណាផង ថ្នាក់លើរបស់អង្គការ ថាអ៊ីចឹង។ អត់ដឹងថ្នាក់គាត់ដល់ណាផង។ ឮតែអង្គការមួយម៉ាត់ហ្នឹង គឺចប់បាត់ហើយពេលនុ៎ង ថ្នាក់លើហើយ។ សូមអស់។

**ស៖** ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា តើអង្គការថ្នាក់លើហ្នឹង លោកដែលមានឮឈ្មោះអ្នកដឹកនាំណាទេ នៅក្នុងពាក្យដែលថា "អង្គការ" ហ្នឹង?

**ឆ៖** ឮច្រើនជាងគេមានតែឈ្មោះ ប៉ុល ពត ហ្នឹងហើយ មេដឹកនាំធំហ្នឹង។

[១១:២៦:៤៣]

**ស៖** អរគុណលោកសាក្សី។ ឥឡូវខ្ញុំសូមបកទៅរកប្រធានបទមួយទៀត កន្លងមកលោកបាននិយាយពីព្រឹកហើយថា ចាប់ពីឆ្នាំ១៩៧៥មក គឺប្រជាជនចាមត្រូវស្ថិតនៅក្រោមការគាបសង្កត់ ការបង្ខំឲ្យធ្វើការជាទម្ងន់ ហើយបង្ខំទាំងប្រពៃណី ទាំងការហូបចុក។ ឥឡូវខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើដោយសារប្រជាជនចាមមិនហូបសាច់ជ្រូក តើប្រជាជនចាម តើគេ -- តើលោកហូបអីដែរ នៅពេលដែលលោកធ្វើការនៅក្នុងការដ្ឋាន?

**ឆ៖** ជួនកាលគេហូបសាច់ជ្រូកទៅ យើងមានអំបិលមានអី លួចហូបអំបិលអីទៅ មានស្អីតាមហ្នឹងទៅ។ គេហូបសាច់ជ្រូកហូបទៅ ប៉ុន្តែយើងគេឲ្យអាម៉េចយើងយកទៅទុកណាសិនទៅ។ យើងហូបអត់បាន ចេះតែហូបម៉េច។

**ស៖** ពេលដែលលោកនៅក្នុងការដ្ឋាននោះ តើការរស់នៅរបស់ប្រជាជនចាម មានការរស់នៅខុសគ្នាដូចម្តេចខ្លះពីប្រជាជនខ្មែរយើង ទាំងការងារ ទាំងការរស់នៅ ទាំងការឈឺថ្កាត់ ទាំងប្រពៃណីទំនៀមទម្លាប់?

**ឆ៖** រស់នៅក្នុងការតាមដានរបស់ខាងអង្គការច្រើនជាងខាងខ្មែរ។ ហូបចុកក៏មានការខ្វះខាតជាងដែរ។ ការងារបង្ខំលើសកម្លាំងជាងដែរ ជាងខ្មែរដែរ។ សូមអស់បាទ។

**ស៖** តើពេលដែលលោករស់នៅនៅក្នុងការដ្ឋាន តើពួកខ្មែរក្រហមមានដឹងថាលោកជាជនជាតិ

01216723



ចាមទេ?

[១១:២៨:៤៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** អង្គការក្រោយអត់ដឹងផង អង្គការមុនៗដឹង។ ក្រោយមកព្រោះអង្គការហ្នឹងផ្លាស់មុខៗរហូត បន្តិចឈ្មោះនេះ បន្តិចឈ្មោះនោះ។ ដូរមកខុសៗប្លែកពីគ្នាទាំងអស់ មួយជំនាន់ទៅមួយជំនាន់ គឺខុសនេះគ្នា។ មួយមកតឹងបន្តិច ពីរមកតឹងបន្តិច ដល់ចុងក្រោយហ្នឹងសម្លាប់អស់តែម្តង។ សូមអស់យោបល់។

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** អរគុណលោក។ លោកបានបញ្ជាក់ថា ប្រជាជនចាមត្រូវគេគាបសង្កត់មិនឱ្យគោរពប្រពៃណី សាសនា មិនឱ្យសូត្រធម៌។ តើមានប្រជាជនចាមដែលប៉ានលួចលាក់សូត្រធម៌ ឬធ្វើល្មើសនឹងការបញ្ជារបស់ពួកខ្មែរក្រហមទេ?

**ឆ៖** អត់សូវប៉ានទេ អត់សូវប៉ានគោរពសាសនា ធ្វើអីសូត្រធម៌អីទេ។ បើសូត្រ ៗក្នុងចិត្តអីបាន សូត្រធម៌អីឮលិចកើត អត់មានទេ។

**ស៖** អរគុណលោកសាក្សី។ តើការប្រកាសរបស់អង្គការ ឬរបស់រដ្ឋអំណាចនៅក្នុងសម័យនោះនៃពួកខ្មែរក្រហម តើគេប្រកាសនៅក្នុងអង្គប្រជុំ ឬក៏ជាប្រកាសប្រាប់ដោយបុគ្គល ឬក៏ប្រកាសហៅប្រជាជនចាមមកប្រជុំ ដើម្បីប្រកាសថា មិនឱ្យធ្វើនេះ មិនឱ្យធ្វើនេះ មិនឱ្យធ្វើនេះ? តើគេធ្វើជាចំហ ឬក៏ជាស្ងាត់ជាបុគ្គលៗ?

[១១:៣០:២៥]

**ឆ៖** គេហៅទៅប្រជុំជាចំហបណ្តោយ ប្រកាសជាជំហ។

**ស៖** តើផែនការនោះ គេប្រកាសយ៉ាម៉េចខ្លះដែរ លោក?

**ឆ៖** គេប្រកាសមិនឱ្យយើងជឿអបិយជំនឿអីផ្តាស ផ្តេសផ្តាសអីអ៊ីចឹងណ៎ា មិនឱ្យគោរពអីគ្មានបានការ បានអីទេ។ ប្រាប់អ៊ីចឹង មិនឱ្យយើងគោរពតាមសាសនា តាមប្រពៃណីអ៊ីស្លាម មិនឱ្យគោរពសោះ ដាច់ខាតតែម្តង។ សូមអស់។

**ស៖** អរគុណលោក។ ពីព្រឹកលោកបានបញ្ជាក់ថាគម្ពីរ គឺថាគម្ពីរសាសនារបស់មូស្លីម គឺថាត្រូវគេកម្ទេចចោល ឬក៏គេយកទៅប្រើប្រាស់ដែលជាមិនសមស្រប។ ប៉ុន្តែតើមានអ្នកដែលលាក់ទុកគម្ពីរនោះទេ? ហើយបើសិនជាគេដឹង តើមានអ្វីនឹងកើតឡើងចំពោះពួកគេ?

**ឆ៖** មានអ្នកខ្លះ យកទៅកប់ក្នុងពាងលាក់ដែរ បានគេអត់ដឹងទាល់សព្វថ្ងៃ។ លួចលាក់កប់ក្នុងពាង កប់ដីណា។ យកគម្ពីរទៅកប់ហ្នឹង នៅសល់ប៉ុណ្ណឹង គេប្រមូលតាមផ្ទះយកទៅកម្ទេចអស់ហើយគ្មានសល់។ សូមអស់។

**ស៖** អរគុណលោក។ នៅក្នុងរបបខ្មែរក្រហម គេហាមប្រាមមិនឲ្យលោកកាន់ប្រពៃណី តមអាហារ។ ចុះពួកលោក នៅពេលដែលរ៉ាម៉ាដន មានការតមអាហារទេ ឬក៏លោកអត់បានដឹងពីរ៉ាម៉ាដននោះទេ?

**ឆ៖** ពេលហ្នឹងលែងស្គាល់ លែងដឹងអស់ហើយ តាំងពីជំនាន់ហ្នឹងមក។ មិនដឹងថ្ងៃណាទេ ទើបយើងដោះហើយ បានស្គាល់វិញ។ ០៧ មករា បានដឹងរ៉ាម៉ាដន ដឹងអីនោះ សល់ពីហ្នឹង អត់មានដឹងអីទេ ព្រោះវាបិទអស់ហើយ មិនដឹងថ្ងៃសុក្រ មិនដឹងថ្ងៃសៅរ៍ម៉េចផង។ សូមអស់បាទ។

[១១:៣២:៣៩]

**ស៖** អរគុណលោក។ ដោយសារប្រពៃណីចាម មិនអនុញ្ញាតឲ្យសាចជ្រូក ឬសម្លាប់ជ្រូក ប៉ុន្តែនៅក្នុងរបបខ្មែរក្រហម លោកមានដែរដឹងទេថា ពួកខ្មែរក្រហមបង្ខំឲ្យលោកសម្លាប់ជ្រូក ចិញ្ចឹមជ្រូក ឬមួយហូបសាចជ្រូក?

**ឆ៖** មាន។ ខាងខ្មែរក្រហមបង្ខំឲ្យចិញ្ចឹមជ្រូកមែន។ ចិញ្ចឹមបានៗហូបហ្នឹង ជួនកាលគ្នាអត់ -- ហូបហើយ ក្អួតមកវិញអីអ៊ីចឹងណា។ បើមិនហូបមិនកើតទេ។ មានចាប់បង្ខំអ៊ីចឹងមែន។

**លោកស្រី ជេត វណ្ណលី៖**

លោកប្រធាន តើខ្ញុំសុំអនុញ្ញាត៥នាទីទៀតបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** លោក ខ្ញុំចង់ឲ្យលោកបញ្ជាក់ដែរថា នៅក្នុងរបបខ្មែរក្រហម តើបងប្អូនប្រជាជនចាមនិយាយភាសាចាម ឬមួយក៏និយាយភាសាខ្មែរ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ និយាយជាភាសាខ្មែរ ហាមមិនឲ្យនិយាយភាសាចាមទេ កាលហ្នឹង។

**ស៖** តើពួកលោកមានការលំបាកទេ ក្នុងការប្រាស្រ័យគ្នា ព្រោះជាធម្មតាលោកនិយាយភាសាចាម ប៉ុន្តែដល់ពេលឲ្យនិយាយភាសាខ្មែរ តើមានការលំបាកទេ ក្នុងការប្រាស្រ័យទាក់ទងនៅក្នុងការរស់នៅក្នុងរបបខ្មែរក្រហម?

[១១:៣៤:២០]

**ឆ៖** រឿងពិបាក វាហួសនឹងពិបាកទៅហើយ។ មិនដឹងធ្វើម៉េច បើគេហាមអត់ឲ្យនិយាយ យើងចេះអី បើនិយាយវាយកទៅសម្លាប់។ យើងពិបាកម៉េច ចេះទ្រាំអ៊ីចឹងទៅ ក្នុងការទាក់ទងគ្នា។ ជួនកាលអ្នកខ្លះអត់ចេះខ្មែរផងហ្នឹង មិនដឹងថាម៉េច។ សូមចប់។

**ស៖** តើនៅក្នុងរបបខ្មែរក្រហម លោកចំពោះកុមារ--

**ប្រធានអង្គជំនុំ៖**

មីក្រូ! ក្បាលមីក្រូហ្វូន!

**សួរដោយលោកស្រី ជេត វណ្ណលី៖**

**ស៖** នៅក្នុងរបបខ្មែរក្រហម ចំពោះកុមារតូចៗ ដែលជាកូនរបស់ប្រជាជនចាម តើពួកខ្មែរក្រហមបានប្រមូលកុមារទាំងនោះទៅដាក់កន្លែងប្រមូលផ្តុំ ឬក៏ឲ្យនៅជាមួយម្តាយឪពុក? ហើយបើហើយការ -- តើលោកដែលជាប្រជាជនចាមហ្នឹង បានអប់រំកូនរៀនជាភាសាចាម ឬក៏បង្រៀនកូនឲ្យនិយាយជាភាសាខ្មែរ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ពេលហ្នឹងកុមារតូចៗវាយកទៅដាក់ម្តុំ សម្រាប់រើសអាចម៍គោ ឬក៏រកចាស់ទុំម្នាក់សម្រាប់មើលក្មេងក្មាងហ្នឹង ហើយនិយាយជាភាសាខ្មែរ បង្រៀនឲ្យចេះនិយាយខ្មែរ។ សូមអស់ហើយ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ជូនអង្គសវនាការដែរថា តើក្នុងរបបខ្មែរក្រហមគេអនុញ្ញាតឲ្យលោករស់នៅជាមួយប្រពន្ធ ជាមួយកូន ឬក៏គេបំបែកទៅតាមការដ្ឋាន និងទៅតាមការងារ?

**ឆ៖** គេបំបែក មិនឲ្យនៅជុំៗ ជួបជុំកូនចៅ ក៏ប្រពន្ធកូនទេ ឲ្យនៅបែកគ្នា។

[១១:៣៦:១៧]

**លោកស្រី ជេត វណ្ណលី៖**

សូមអរគុណលោកសាក្សី។ ខ្ញុំសូមអរគុណចំពោះចម្លើយរបស់លោក និងការបញ្ជាក់ដ៏ក្បោះក្បាយរបស់លោកជូនអង្គសវនាការ។ លោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៧ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។ ហើយដំបូងនេះផ្តល់វេទិកាជូនក្រុមសហមេធាវីការពារ -- សូមផ្អាកបន្តិចសិន ឥឡូវមានលោកចៅក្រម ហ្វង់ម៉ាក ឡាវ៉ែន៍ ទំនងមានសំណួរសួរសាក្សី។ សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្វង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោក ជាពិសេសខ្ញុំចង់ឲ្យលោកបំភ្លឺនូវចំណុចមួយចំនួនពាក់ព័ន្ធនឹងការប្រជុំនៅក្នុងភូមិភាគកណ្តាលក្នុងឆ្នាំ៧៨ គឺបើសិនជាខ្ញុំមិនច្រឡំទេ នៅកំពង់ធំ។ តើលោកអាចបញ្ជាក់បានទេ អ្នកណាជាអ្នកដឹកនាំកិច្ចប្រជុំនោះ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឮដំណឹងថាមេភូមិភាគឈ្មោះ កែ ពក ហ្នឹងវាអ្នកដឹកនាំ។ ខ្ញុំមិនដឹងច្បាស់ ព្រោះខ្ញុំប្រជាពលរដ្ឋ គ្រាន់តែប្រើឲ្យជូនដំណើរគេ ជូនទៅ។ គ្រាន់ក្នុងឧទ្ទេសនាម គាត់ថា អង្គការឈ្មោះ កែ ពក ឬក៏ ប៉ុល ពក ហ្នឹង ដឹងតែប៉ុណ្ណឹង។ សូមអស់។

**ស៖** បាទ សូមអរគុណ។ តើលោកមានស្តាប់ឮថា អ្នកណាជាអ្នកនិយាយ<នៅក្នុងកិច្ចប្រជុំនោះ>?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បទឧទ្ទេសនាម គេឧទ្ទេសថាមេភូមិភាគជាអ្នកឧទ្ទេសនាមបណ្តោយ គ្មានពីណាធំជាងគាត់នៅនុ៎ង។ ទៅៗស្តាប់គាត់និយាយហ្នឹងហើយ។ សូមអស់យោបល់។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** នៅពេលនោះ តើគាត់បាននិយាយអ្វីខ្លះ ពាក់ព័ន្ធនឹងជនក្បត់? កាលពីព្រឹកមិញខ្ញុំស្តាប់ឮថាមានការនិយាយអំពីរឿងជនក្បត់។ អ៊ីចឹងតើពាក្យពេចន៍ ឬក៏សម្តីដែលគាត់និយាយពេលនុ៎ងពាក់ព័ន្ធនឹងជនក្បត់ហ្នឹង គាត់និយាយថាម៉េចខ្លះ?

**ឆ៖** គាត់និយាយរឿងជនក្បត់ សំដៅលើអ្នកខាងនៅខាងភូមិភាគបូព៌ាបណ្តោយ ដោយសារអ្នកខាងភូមិភាគបូព៌ា អង្គការចាស់ សុទ្ធតែក្បត់របស់ថ្នាក់លើទាំងអស់។ អ៊ីចឹងគេត្រូវបោសសម្អាតឲ្យអស់ ខាងភូមិភាគបូព៌ាហ្នឹង។ អស់ប៉ុណ្ណឹង។

**ស៖** <តើគាត់និយាយអំពី>មនុស្សទាំងអស់នៅភូមិភាគ<>បូព៌ា<ឬ?> <តើគាត់បាននិយាយអំពី>ប្រជាជនថ្មី<ទេ?> <តើគាត់បាននិយាយអំពី>ប្រជាជនមូលដ្ឋាន<ទេ? តើ>គាត់មានរៀបរាប់ទេថាអ្នកណាឲ្យប្រាកដជាជនក្បត់នោះ ឬក៏មនុស្សទាំងអស់នៅ ភូមិភាគបូព៌ាហ្នឹងត្រូវតែបោសសម្អាត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចោលទាំងអស់?

**ឆ៖** ការពិតគោលការណ៍គេ បោសសម្អាតចោលទាំងអស់បណ្ដោយ មិនថាអ្នកថ្មី អ្នកចាស់ ចាម ឬក៏ខ្មែរទេ ព្រោះគេថានៅបូព៌ាក្បត់ទាំងអស់ សុទ្ធតែខ្លួនខ្មែរក្បាលយួន។ គេចោទអ៊ីចឹងបណ្ដោយ។ អស់យោបល់ហើយ។

[១៣:៣៥:៤០]

**ស៖** នៅពេលណាមួយនោះក្នុងពេលប្រជុំ តើគេមាននិយាយអំពីរឿងជនជាតិយួនទេ? តើគេមានកំណត់មុខសញ្ញាចំពោះយួនទេ?

**ឆ៖** គេគ្រាន់តែនិយាយថា កម្មាភិបាលនៅភូមិភាគបូព៌ា ខ្លួនខ្មែរក្បាលយួន។ ហើយក្រៅខុសហ្នឹងគេថា ក្រុមចល័តជាក្រុមខ្លាំង ចលនាខ្លាំងជាងគេរបស់ចោរព្រៃ។ ចល័តរបស់ចោរព្រៃវិញណា។ ហ្នឹងនិយាយប៉ុណ្ណឹង។ អស់យោបល់ហើយ។

**ស៖** ក្នុងពេលប្រជុំ តើគេមាននិយាយអំពីជនជាតិចាមទេ? ហើយបើមាននិយាយ តើគេនិយាយអ្វីខ្លះអំពីចាមនេះ?

**ឆ៖** ដូចពាក្យហ្នឹងអត់ឮនិយាយផង បើចាមកំពុងតែដឹកទៅហើយ ជម្លៀសរាល់ដងហើយ។ គេយកពួកក្បត់នៅបូព៌ាបន្ថែមទៀត។ អស់យោបល់ហើយ។

**ស៖** លោកចាំថា មានបុគ្គលម្នាក់ឈ្មោះ អ៊ីសា ឧស្មាន ទៅសម្ភាសលោកទេ?

**ឆ៖** នៅចាំ។

**ស៖** ខ្ញុំនឹងអានទូវសម្រង់មួយចេញពីសៀវភៅរបស់គាត់ "ការបះបោររបស់ចាម"។ គេបានអានឲ្យលោកស្ដាប់រួចហើយ នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតស្ដាប់ចម្លើយរបស់លោក។ ឯកសារហ្នឹងគឺមានលេខ E3/9323 ERNជាភាសាបារាំង <00286658>, ជាភាសាខ្មែរ 00 275387, ជាភាសាអង់គ្លេស 00218542។ អ៊ីសា ឧស្មាន បានសរសេរនៅក្នុងសៀវភៅរបស់គាត់ពាក់ព័ន្ធនឹងកិច្ចប្រជុំនេះ។ គាត់ថា៖ "នៅពេលមួយនោះ ក្នុងពេលប្រជុំ កែ ពក ដែលជាលេខាភូមិភាគកណ្ដាលដែលតំណាងមួយចំនួនទើបតែឡើងកាន់កាប់ភូមិភាគ<បូព៌ា>ទាំងកំរោល បានសួរទៅលេខាស្រុកក្រូចឆ្មារ ថា គម្រោងដែលដាក់ជូនដោយបក្ស តើបានបញ្ចប់ប៉ុន្មានភាគរយហើយ? ពេលហ្នឹងគាត់និយាយថា សឡេះ បាននិយាយថា៖ កែ ពក បានបញ្ជាក់បន្ថែមទៀតថា សមមិត្តត្រូវតែកម្ទេចពួកចាមដែលស្ថិតនៅក្នុងកងចល័តមុន ពីព្រោះពួកគេទាំងនោះ សុទ្ធតែជាជនក្បត់ជាតិ។" តើអ្វីដែលខ្ញុំអាននេះ

ធ្វើឲ្យលោកនឹកឃើញរឿងហេតុនេះឡើងវិញទេ? ហើយលោកមានអ្វីត្រូវបញ្ជាក់បន្ថែមទេ?

ឆ៖ ខ្ញុំបានបញ្ជាក់ព្រឹកមិញហើយតើ ថាផែនការវាឲ្យកម្ទេចទាំងអស់ហ្នឹង។ គោលការណ៍របស់វា យកកម្ទេចទាំងអស់ហ្នឹង ចល័តទាំងប៉ុន្មាន។ សូមអស់យោបល់។

[១៣:៤០:០៥]

ស៖ អ៊ីចឹងផែនការហ្នឹងគេត្រូវកម្ទេចកងចល័តទាំងអស់តែម្តង ឬក៏កម្ទេចតែចាមដែលស្ថិតនៅក្នុងកងចល័តហ្នឹងទេ?

ឆ៖ ទាំងអស់តែម្តង អត់មានបែងចែកអី ទាំងអស់។

ស៖ នៅក្នុងពេលប្រជុំ <> តើមានការសួរសំណួរអ្វីពាក់ព័ន្ធនឹងចាមទេ?

ឆ៖ គេសួរសំណួរហ្នឹងហើយ សំណួរដែលពាក់ព័ន្ធចាម ទាំងខ្មែរទាំងអីហ្នឹង។ ភូមិភាគបូព៌ាដែលក្បត់ហ្នឹង គឺផែនការគេយកទៅកម្ទេចទាំងអស់ហ្នឹងហើយ។ គោលការណ៍គេមានតែប៉ុណ្ណឹង។

ស៖ ដូច្នេះក្នុងពេលប្រជុំនោះ គេមិនមានបានបញ្ជាក់ថា កម្ទេចតែជនជាតិចាម ឬក៏យ៉ាងម៉េចទេ គឺថាកម្ទេចទាំងអស់ឲ្យតែជាជនក្បត់មែនទេ?

ឆ៖ បាទ ហ្នឹងហើយ។ ឲ្យតែជនក្បត់ គេយកកម្ទេចទាំងអស់ហ្នឹង។

**ចៅក្រម ហ្ស៊ង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកសាក្សី ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

[១៣:៤២:២១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

ស៖ ខ្ញុំសូមចាប់ផ្តើមជាដំបូង ដោយសួរលោកនូវសំណួរមួយចំនួន។ ខ្ញុំចង់សួរលោកថា តើ គន់ គីម គឺជាអ្នកណា?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឯកឧត្តម គន់ គីម គឺជាមេទ័ពមួយខាងរំដោះសង្គ្រោះជាតិ ជួយរំដោះប្រជាពលរដ្ឋដែល ប៉ុល ពត ប្រុងយកទៅសម្លាប់។ ជាមេបញ្ជាការមួយរូបតស៊ូក្នុងការប្រឆាំងជាមួយ ប៉ុល ពត។ សូមអស់យោបល់។

**ស៖** តើ គន់ គីម មានតួនាទីអ្វីដែរមុនពេលដែលគាត់ចូលរួមរណសិរ្សសង្គ្រោះជាតិកម្ពុជា?

**ឆ៖** អត់ដឹងគាត់តួនាទីអីផង។ បានដឹងគាត់ ថាពេលតស៊ូរំដោះជាតិហ្នឹងមានគាត់ធ្វើមេបញ្ជាការក្នុងព្រៃហ្នឹងបណ្ដោយ។ អត់ដឹងថាពីមុនមកគាត់ធ្វើអី អត់ដឹងផង ដឹងតែពីរំដោះជាតិក្នុងនាមរណ-សិរ្សសាមគ្គីសង្គ្រោះជាតិហ្នឹង មានឃើញគាត់ធ្វើមេទ័ពនៅក្នុងហ្នឹង ដើម្បីវៃប្រឆាំងជាមួយ ប៉ុល ពត តែប៉ុណ្ណឹង។ សូមអស់យោបល់។

**ស៖** តើគាត់មានឋានន្តរសក្តិអ្វីដែរ? តើគាត់មានតួនាទីអ្វីដែរនៅក្នុងរណសិរ្សនោះ? តើគាត់មានតួនាទីប៉ុនគ្នាជាមួយនឹង ហេង សំរិន ឬក៏ខ្ពស់ជាង<>?

[១៣:៤៤:២៦]

**ឆ៖** តូចទេ គាត់នៅក្នុងស្រុក។ គាត់តស៊ូរំដោះនៅក្នុងស្រុកហ្នឹង ក្នុងនាមគាត់ជាមេបញ្ជាការតូចដែរទេ មិនធំប៉ុនសម្ដេច ហេង សំរិន ឬក៏ ជា ស៊ីម អីទេ។ គាត់ដឹកទ័ពតូចៗ សម្រាប់ការពារប្រជាពលរដ្ឋក្នុងមូលដ្ឋាននៅត្បូងឃ្មុំ ក្រូចឆ្មារហ្នឹង។ ប៉ុណ្ណឹង សូមអស់យោបល់។

**ស៖** ខ្ញុំសូមអានឲ្យលោកស្ដាប់នូវអ្វីដែលលោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេត គឺឯកសារ E3/5209 អង់គ្លេសមានលេខ 00242069, ខ្មែរមានលេខ 00218538 និងបារាំងមានលេខ 00293938 ដល់39។ "នៅក្នុងឆ្នាំ៧៨ យើង (គឺលោកផងដែរនោះ) <បាន>វាយប្រហារ<ប្រឆាំង>ជាមួយខ្មែរក្រហមនៅក្នុងសមរភូមិ<ចំនួនពីរ> ទី១ នៅស្រុកក្រូចឆ្មារ <ហើយ>មួយទៀតនៅមុខវត្តរកាខ្នុរ។ ក្រោយមកទៀតយើងចូលទៅក្នុងកងធំ របស់ គន់ គីម ហើយយើងបន្តវាយរហូតដល់ពេលរំដោះ។" នៅពេលដែលលោកនិយាយថា គឺថានៅពេលដែលលោកប្រាប់អ្នកស៊ើបអង្កេតថា លោកចូលជាមួយកងធំរបស់ គន់ គីម ហ្នឹង តើលោកចង់មានន័យយ៉ាងម៉េចដែរ?

**ឆ៖** មានន័យថា យើងកំពុងតែទៅចាប់ដៃជាមួយកងទ័ពធំរបស់ឯកឧត្ដម គន់ គីម ព្រោះគាត់មានកងទ័ពច្រើន ហើយខាងខ្ញុំនោះមានកងទ័ពតិចតួច ការពារប្រជាជនមិនគ្រប់។ ប៉ុល ពត មានកម្លាំងច្រើនជាង។ សូមអស់យោបល់។

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថា តើលោកមានន័យយ៉ាងម៉េចដែរ ដែលលោកនិយាយថា ទ័ពធំ របស់ គន់ គីម? តើទ័ពរបស់គាត់ហ្នឹង ធំយ៉ាងម៉េចដែរ?

**ឆ៖** ទ័ពគេធំ មានកម្លាំងបួនប្រាំរយនាក់ទៅ១.០០០នាក់នោះ គាត់ហៅធំហើយ។ គាត់មានកម្លាំងរួបរួមគ្នា ដើម្បីប្រឆាំងជាមួយ ប៉ុល ពត គឺគាត់មានកម្លាំងច្រើន។ ហ្នឹងគេហៅធំហើយ។ ទ័ពធំរបស់គាត់ហើយ។ សូមអស់យោបល់។

[១៣:៤៧:១៧]

**ស៖** តើលោកដឹងទេថា តើអ្នកណាជាមេបញ្ជាការរបស់ គន់ គីម គឺមានន័យថាតើ គន់ គីម គាត់ត្រូវរាយការណ៍ទៅឱ្យមេបញ្ជាមួយណា រូបណាដែរ?

**ឆ៖** ខ្ញុំភ្លាប់អត់បាន ព្រោះតាមរយៈកងខ្ញុំអត់មានមេ មានកោយអីធំដុំទេ មាននៅក្នុងភូមិ ក្នុងស្រុកហ្នឹង។ ដល់ គន់ គីម គេមានកម្លាំងច្រើនជាង ទៅគាត់មេធំហើយនៅនុ៎ង។ តែប៉ុណ្ណឹងទេ អត់មានដឹងថា គាត់មានរយៈពីណាពីណើមក អត់ ភ្លាប់អត់បាន អត់ដឹង។ ព្រោះអត់មានទៅណាឆ្ងាយប៉ុន្មាន ក្នុងជំនាន់ ប៉ុល ពតនុ៎ង ភូមិណានៅភូមិហ្នឹងហើយ។ រួចបានយើងបានរំដោះហ្នឹង បាននៅដើរមួយស្រុកអីបាន។ ខុសពីហ្នឹងទៅណារួច។ មានកម្លាំង ប៉ុល ពត នៅតាមផ្លូវហែហនេះ យើងទៅគ្រោះថ្នាក់ទៀត។ នៅម្តុំណា គឺនៅការពារម្តុំហ្នឹងហើយ។ សូមអស់យោបល់។

**ស៖** តើបច្ចុប្បន្នហ្នឹង គន់ គីម គាត់មានតួនាទីអ្វីដែរ?

**ឆ៖** បច្ចុប្បន្ន គន់ គីម គាត់មានតួនាទីជារងអគ្គមេបញ្ជាការចម្រុះក្នុងកងយោធពលខេមរភូមិន្ទ អគ្គមេបញ្ជាការរង។ សូមអស់យោបល់។

**ស៖** តើក្នុងពេលបច្ចុប្បន្នហ្នឹង គាត់ជាមនុស្សម្នាក់ដែលមានឋានន្តរសក្តិខ្ពស់ជាងគេនៅក្នុងប្រទេសកម្ពុជា មែនទេ?

**ឆ៖** មិនមែនទេ។ មិនមែនគាត់ធំជាងគេទេ មានគេធំជាងគាត់ទៀត ឋានៈថ្នាក់ស័ក្តិហ្នឹង។ ហៅថារង មានធំឯណាទៀត។ បើធំ ហៅមេបាត់ហើយ។ សូមអស់យោបល់។

[១៣:៤៩:៥៤]

**ស៖** តើបច្ចុប្បន្នហ្នឹងគាត់ជា<នាយឧត្តមសេនីយ៍ផ្កាយបួនដែលជា>មេអគ្គសេនាធិការមែនទេ?

**ឆ៖** គាត់ជាអគ្គរង អគ្គសេនាធិការរង។ សូមអស់យោបល់។

**ស៖** <>យើងនិយាយពីមនុស្សតែមួយទេ តើគាត់ហ្នឹងគឺជាមនុស្សតែមួយដែល<ពេលថ្មីៗ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះ>ទទួលបានសញ្ញាបត្របណ្ឌិតពីប្រទេសវៀតណាមហ្នឹង តើមែនទេ?

**ឆ៖** ខ្ញុំអត់ក្ដាប់បានទេរឿងទទួលបណ្ឌិត មិនបណ្ឌិត អត់ដឹងដល់ហ្នឹងទេ។ សូមអស់យោបល់។

**ស៖** នៅក្នុងតំបន់២១ គឺដែលជាតំបន់របស់ស្រុកក្រូចឆ្មារនោះ គឺមានមេសេនាធិការមួយឈ្មោះ គន់ ដេត។ តើលោកដឹងថា គន់ ដេត និង គន់ គីម ហ្នឹងជាមនុស្សតែមួយ ឬក៏ជាមនុស្សផ្សេងគ្នាទេ?

**ឆ៖** អត់ដឹងដែរ ព្រោះអត់ស្គាល់ប្រវត្តិក្រុមគ្រួសារគាត់ឈ្មោះអីៗផងហ្នឹង អត់ដឹង។ សូមអស់យោបល់។

**ស៖** នៅ<កងពលទី៤>ក្នុងភូមិភាគបូព៌ា<មាន>មេបញ្ជាការ<រង>ម្នាក់ឈ្មោះ ហេង គីម <>មានម្ដងនោះគាត់ក្លាយជាប្រធានកងពលលេខ៥ <ក្នុងភូមិភាគបូព៌ា> តើ<លោកដឹងទេថា តើគាត់អាចជាមនុស្សតែមួយ>ជាមួយនឹង គន់ គីម?

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំស្នើសុំចង់ឲ្យមេធាវីការពារក្ដីផ្ដល់នូវឯកសារយោង នៅពេលដែលគាត់ចោទសួរសំណួរបែបនេះ។

[១៣:៥២:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ការសួរសំណួររបស់ខ្ញុំ គឺផ្អែកទៅលើការសម្ភាសរវាង ប៉ែន យៀរនិន ជាមួយ ហេង សំរិន គឺ E3/1568 អង់គ្លេសមានលេខ <00651892>, ខ្មែរមានលេខ 00713967, បារាំងមាន <00743365>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹងគឺថាប្រហែលជា<លោក>មិនដឹង<គាត់ជានរណាទេ>ពីចន្លោះឆ្នាំ៧៥-៧៩<> ប៉ុន្តែតើគាត់គឺជា<កម្មាភិបាល>ម្នាក់ដែលមានតួនាទីខ្ពស់នៅក្នុងភូមិភាគបូព៌ាដែរឬទេ? ហើយថាតើគាត់ជាអ្នកមកពីកំពង់ចាមដែរឬទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ពេលហ្នឹងខ្ញុំក្ដាប់អត់បានទេ។ សូមអត់ដឹង អត់ឆ្លើយ។ អត់ដឹងថា គាត់នៅត្រង់ណាអីត្រង់ណាផង អត់ដឹង។ សូមអស់យោបល់។

**ស៖** តើលោកអាចប្រាប់បានទេ នៅពេលដែលលោកចូលរួមជាមួយទ័ពធំរបស់ គន់ គីម តើ

លោកមានឋានន្តរសក្តិអ្វីដែរ ជាពិសេសចំពោះសមរភូមិពីរដែលលោកចូលរួម ទី១ នៅស្រុកក្រូចឆ្មារនិងមួយទៀតសមរភូមិនៅមុខវត្តរកាខ្នុរ? តើលោកមានតួនាទីអ្វីដែរ ក្នុងនាមលោកជាទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា តើលោកអាចប្រាប់អង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំពេលនោះគ្មានតួនាទីអីទេ។ ឲ្យតែមានកាំភ្លើងចេះតែការពារប្រជាពលរដ្ឋអីប៉ុណ្ណឹងទេ អត់ចាត់តាំងពីណាមេ ណាកោយទេ គឺស្មើគ្នាទាំងអស់បណ្ដោយ។ ឲ្យតែមានការអីព្រួតដៃគ្នាទៅហើយ ព្រោះគ្មានអ្នកណាចាត់តាំងធ្វើមេទេ បើសុទ្ធតែយើងអ្នកតស៊ូប្រឆាំងកុំឲ្យតែងាប់ខ្លួនទៅហ្នឹង។ ប៉ុណ្ណឹងទេបាទ អត់មានមេទេ។ យុទ្ធជនទាំងអស់គ្នាហ្នឹង គ្មានមេគ្មានកោយទេ កន្លែងក្រុមខ្ញុំបាទ។ សូមអស់យោបល់។

[១៣:៥៤:៣៧]

**ស៖** ឥឡូវនេះខ្ញុំសូមបន្តទៅមុខបន្តិច គឺដូចគ្នានឹងERNដដែលដែលខ្ញុំទើបតែលើកយកមកបង្ហាញគឺលោកបាននិយាយថា៖ “ក្រោយមកពួកយើង<៣០០>នាក់<នៅក្នុងកងពលតូចចល័ត>បានរត់ចូលព្រៃ ហើយយើងសម្រេចចិត្តវាយប្រហារជាមួយខ្មែរក្រហម ដើម្បីបញ្ឈប់កុំឲ្យសម្លាប់ជនជាតិចាម។ យើងមានអាវុធតិចតួចទេ តែកាំភ្លើងវែង<ដប់>ប្រាំតែប៉ុណ្ណឹង។ ហើយយើងបាន<ដាក់ឈ្មោះចលនាពួកយើងថា>ជា<>រណសិរ្សសង្គ្រោះជាតិនៅព្រៃងងុយខាងក្រោយភូមិជំនីក។” តើលោកពិតជាបានប្រាប់អ្នកស៊ើបអង្កេតបែបនេះមែនទេ?

**ឆ៖** បាទ ប្រាប់មែន ការពិត។ នាំប្រជាជនទៅហ្នឹង ចាកងទ័ពរណសិរ្សមកដល់ស្រុកដំបែ។ ដល់អ៊ីចឹងនៅនេះវាអស់សង្ឃឹមហើយ ខ្លាចប្រជាជនអត់ស៊ី អត់អី ទៅនឹងវាមានស្រូវ មានអី នាំគ្នាបូតបោចក្បួរស្រូវអីហូបទៅ។ អ៊ីចឹងទម្រាំទៅដល់ហ្នឹង បានជួបក្រុមរណសិរ្សសង្គ្រោះជាតិមកដល់ស្រុកដំបែមែន។ សូមអស់យោបល់។

**ស៖** តើក្រុមរបស់លោកបានអាវុធចំនួន<ដប់>ប្រាំដើមហ្នឹង មកពីកន្លែងណាដែរ?

**ឆ៖** អាវុធប្រាំដើមហ្នឹង ប្រជាពលរដ្ឋដឹងថាកងទ័ព ប៉ុល ពត ហ្នឹងបាញ់ប្រហារជាមួយកងទ័ពភូមិភាគបូព៌ា។ អ៊ីចឹងកងទ័ពភូមិភាគបូព៌ាក៏យកកាំភ្លើងទៅទម្លាក់ចោលក្នុងអណ្ដូងទឹកទៅ។ អ៊ីចឹងប្រជាជនទៅយកកាំភ្លើងហ្នឹង យកមកឲ្យពួកចល័តទាំងអស់គ្នាហ្នឹងប្រើប្រាស់ ដើម្បីវៃប្រហារតបតជាមួយ ប៉ុល ពត កុំឲ្យជម្លៀសប្រជាជនជនតទៀត។ ប៉ុណ្ណឹង សូមអស់យោបល់។

[១៣:៥៦:៤៨]

**សះ** នៅក្នុងចម្លើយរបស់លោក ៗឆ្លើយថាមានកាំភ្លើង១៥ដើម។ ប៉ុន្តែចង់ដឹងថា តើលោក<រកវាឃើញ> មិនមែនបានកាំភ្លើងហ្នឹងពីអ្នកណាម្នាក់ផ្សេងទេ មែនទេ?

**ឆះ** អត់មានពីណាមកទេ ប៉ុន្តែកាំភ្លើងយើងអាចទៅរើសបានតាមអណ្តូង ដែលគេយកទៅទម្លាក់ចោលក្នុងនុំង។ អត់មានពីណាយកមកប្រគល់ឲ្យយើងទេ។ យើងដឹងថាប្រជាជនប្រាប់ថាកាំភ្លើងមានគេយកទៅទម្លាក់ចោល ពេលហ្នឹងយើងដឹងថាពួក ប៉ុល ពត ដេញបោសសម្អាតខាងភូមិភាគបូព៌ា។ ខាងនោះក៏បាក់ទ័ព ក៏យកកាំភ្លើងលាក់ទុកក្នុងអណ្តូងហ្នឹងទៅដើម្បីរត់យករួចខ្លួន។ សូមអស់យោបល់។

**សះ** ខ្ញុំសូមបន្តទៅមុខបន្តិច។ នៅព្រឹកមិញនៅពេលដែលលោកឆ្លើយសំណួររបស់ប្រធាន គឺលោកបាននិយាយថា ឥឡូវហ្នឹងលោកគឺជាអង្គរក្សរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ តើអ៊ីចឹងមែនទេ?

**ឆះ** បាទ ខ្ញុំគឺជាអង្គរក្សមែន។ អស់យោបល់។

**សះ** តើលោកទទួលបានតួនាទីជាអង្គរក្សហ្នឹងនៅពេលណាដែរ មុនឆ្នាំ៧៩ ឬក៏ក្រោយឆ្នាំ៧៩?

**ឆះ** ក្រោយឆ្នាំ៧៩។

**សះ** តើមុនឆ្នាំ៧៩ លោកស្គាល់សម្តេចនាយករដ្ឋមន្ត្រីដែរឬទេ?

**ឆះ** ស្គាល់សម្តេច ប៉ុន្តែមិនដែលបានជួបសម្តេចផង។ សម្តេចនៅធ្វើការសម្តេចទៅ ខ្ញុំនៅការងារខ្ញុំទៅ។ សូមអស់យោបល់។

**សះ** តើលោកមានន័យថាម៉េចដែរ ដែលលោកថាគាត់នៅខាង<បស្ចិមនោះ>?

[១៣:៥៩:២៧]

**ឆះ** គាត់នៅបូព៌ា គេថាគាត់ក្បត់ហ្នឹងហើយ បើគាត់នៅបូព៌ាហ្នឹង។ បើគាត់នៅបូព៌ា ដូចថាខាង ប៉ុល ពត ចោទថាគាត់ក្បត់អង្គការហ្នឹង។

**សះ** តើលោកដឹងទេ នៅពេល<ណា>ដែលគាត់ចាកចេញពីខាងបូព៌ា? <>តើលោកដឹងទេថាគាត់រត់ទៅ<វៀតណាម>នៅឆ្នាំណា? តើគាត់មានប្រាប់លោកទេ?

**ឆះ** បាទ អត់ដឹងគ្នាទេពេលនុំង អាពត អត់ឲ្យទៅណាផង។ សូម្បីតែមួយភូមិ ទៅភូមិមួយ ក៏អត់ដឹងគ្នាដែរ។ រួចដល់សម្តេចទៅដល់ណាដល់ណី ឲ្យដឹងម៉េច។ សម្តេចគាត់នៅមេមត់ នៅឯណានោះ រួចខ្ញុំនៅដល់ទន្លេនោះ ម៉េចដឹង។ អត់បានដឹងគ្នាទេ។

**សះ** តើគាត់បានរត់ទៅវៀតណាមនៅខែមិថុនា ឆ្នាំ៧៧មែនទេ?

**ឆ៖** ខ្ញុំឆ្លើយថា ខ្ញុំអត់ដឹងគាត់ទៅឆ្នាំណា អីឆ្នាំណា អត់ដឹងទេ ព្រោះពេលហ្នឹង អានេះអត់មានទូរស័ព្ទ អត់មានតេអូផង អត់ដឹងគ្នាទេ សុទ្ធតែព្រៃ ដើរទៅណារួច។ ប៉ាន់តែដើរក្រៅភូមិបន្តិច អាចពតបាញ់ងាប់បាត់ហើយ យកទៅសម្លាប់បាត់ហើយ។ សូមអស់យោបល់។

**ស៖** តើ<គាត់>មានបានចូលរួមនៅក្នុង<>សមរភូមិពីរ<>ដែលលោករៀបរាប់ <ថាលោកបានចូលរួមនោះទេ> មួយនៅក្រូចឆ្មារ មួយទៀតនៅ<>វត្តរកាខ្នុរនោះ?

**ឆ៖** អត់មានទេ អត់មានចូលរួមគ្នាបានទេ បើគាត់នៅឯណា ទៅវាយភ្នំពេញ រួចខ្ញុំនៅក្រូចឆ្មារនេះ អត់បានដឹងគ្នាទេ។ អត់បានជួបគ្នាទេ។

[១៤:០១:៤៩]

**ស៖** តើលោកដឹងទេថា សម្តេចមានតួនាទីអ្វីដែរក្នុងឆ្នាំ៧៥ នៅតំបន់២១នោះ?

**ឆ៖** អត់ដឹងទេ ព្រោះខ្ញុំអត់ទាន់ស្គាល់សម្តេចផងកាលនុ៎ង។ អត់ដឹងសម្តេចធ្វើអីផង អត់ដឹងអត់បានដឹង។

**ស៖** ខ្ញុំយល់ ប៉ុន្តែតើពេលក្រោយមកទៀត គាត់មានដែលប្រាប់លោកដែរទេ <អាចថានៅពេលដែលលោកបានក្លាយជាអង្គរក្សរបស់គាត់ ថា> គាត់ជាអនុប្រធានកងវរសេនាធំ<នៅតំបន់២១>នៅឆ្នាំ៧៥នោះ?

**ឆ៖** អត់ទេ អត់ដែលបានប្រាប់ផង អត់ដឹងទេ។

**ស៖** តើសម្តេចធ្លាប់ប្រាប់ទេថា កងវរសេនាធំរបស់គាត់មានតួនាទីក្នុងការកម្ទេចការបះបោររបស់ជនជាតិចាម<នៅចុង>ឆ្នាំ៧៥ដែរឬទេ?

**ឆ៖** អត់មានទេ។ អត់មានឮផង។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយគឺរបស់<កម្មាភិបាល>កងវរសេនាធំ <ឬកងវរសេនាតូច>លេខ៥៥ <> E3/5261, ខ្មែរមានលេខ 00250947 <សូមទោស 43>, បារាំងមាន <00285329>, អង់គ្លេស 00274336។ “នៅពេលនោះ សុខ <សារឿន> បានក្លាយជាប្រធានកងពលភូមិភាគ ហើយ សុខ <សាត> ក្លាយជាប្រធានកងពល៥៥។ សុខ <សាត> បញ្ជាកងទ័ពដើម្បីគាបសង្កត់លើការបះបោររបស់ចាម។ សំណួរ៖ តើលោកដឹងទេ ថាតើ សុខ <សាត> ទទួលបានបញ្ជាពីអ្នកណា? ឆ្លើយ៖ តាមដែលខ្ញុំដឹង សុខ <សាត> ទទួលបញ្ជាពី យុន សុភី។ យុន សុភី គឺជា<មេ>បញ្ជាការ<តំបន់២១>។” តើសម្តេច ហ៊ុន សែន ធ្លាប់ប្រាប់លោកអំពីបញ្ហានេះទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:០៤:៣៥]

**ឆ៖** មិនដែលប្រាប់ទេ។ ឈ្មោះទាំងអស់ក៏ខ្ញុំមិនដែលឮ មិនដែលស្គាល់ដែរ។ សូម្បីតែឮ មិនដែលឮថាឈ្មោះម៉េចៗផងអំមិញ ឈ្មោះនិយាយអំមិញ អត់ដឹងទាំងអស់។

**ស៖** ប៉ុន្តែខ្ញុំគិតថា លោកធ្លាប់ឮឈ្មោះ ហេង សំរិន។ តើអ៊ីចឹងមែនទេ?

**ឆ៖** ហេង សំរិន ពីណាមិនឮ តាំងពីនេះមកហ្នឹង តាំងពីរំដោះមកឮហើយ ឮគាត់អ្នកដឹកនាំប្រទេសមករំដោះស្រុកខ្មែរហ្នឹង។ ឮពេលហ្នឹង ពេលគាត់មករំដោះហ្នឹង។ មុនហ្នឹង អត់ដឹងទេ។

**ស៖** តើនៅក្នុងឆ្នាំ៧៥ ហើយនិងក្រោយមកទៀត គាត់ជាអនុប្រធានសេនាធិការយោធាភូមិភាគដែរឬទេ?

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន សាក្សីបានបញ្ជាក់ថា<លើកដំបូង>គាត់ឮអំពី ហេង សំរិន គឺនៅក្រោយឆ្នាំ៧៩។ ដូច្នេះខ្ញុំមិនដឹងថាមានមូលហេតុអ្វី <ក្នុងការ>សួរទាក់ទងនឹង<តួនាទីសម្តេចហេង សំរិន>ឆ្នាំ៧៥ <នោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំប្រាដកថា សាក្សីបានធ្លាប់ជួបសម្តេច ហេង សំរិន<នៅពេលក្រោយមក ប៉ុន្តែ -->

**លោក ត្រាវីស ហ្វារ៖**

ប្រហែលជាមែន ប៉ុន្តែលោកគួរ<ស្នើសុំ>ជាមុនសិន។ <យើងអាចដាក់ចូលបាន។>

[១៤:០៥:៥៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើក្រោយឆ្នាំ៧៩ លោកធ្លាប់ជួបសម្តេច ហេង សំរិន ដែរឬទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** អត់បានជួបទេ មិនដែលបានជួបសម្តេច ទាល់ឥឡូវហ្នឹងមិនទាន់ជួបគាត់ម៉េចផង កុំថា ៧៩ ឮតែឈ្មោះហ្នឹង។

**ស៖** តើលោកធ្លាប់ឮនរណាម្នាក់ប្រាប់<លោកអំពីសម្តេច ហេង សំរិន> ក្នុងឆ្នាំ៧៥ <ហើយក្រោយមក>គាត់គឺជា<>នាយរងសេនាធិការភូមិភាគបូព៌ាដែរឬទេ?

**ឆ៖** អត់ទេ អត់បានឮទេ។ និយាយរឿងមុនឆ្នាំហ្នឹងមក ខ្ញុំអត់ដឹងទាំងអស់ អត់ដឹង ព្រោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មនុស្សអត់មានអ្នកធ្វើការអីធំដុំ ម៉េចដឹង។ អ្នកណាធ្វើអី ក៏ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំសួរជាទូទៅអីចេះវិញ តើលោកធ្លាប់ឮថា ហេង សំរិន គឺជាមេបញ្ជាការធំ ឬក៏មេបញ្ជាការធំជាងគេបន្ទាប់ពី សោ ភឹម ចន្លោះឆ្នាំ៧៥ ដល់៧៩ ដែរឬទេ?

**ឆ៖** អត់ឮទេ អត់ដែលឮទេ។ អត់ដឹងថាគាត់ធ្វើអីផង តាំងពី៧៥មក។ ដឹងក្រោយថាពីរំដោះមក ៧៩ហ្នឹង បានដឹងថាគាត់អ្នករំដោះប្រទេសជាតិមក តែប៉ុណ្ណឹង។ សួរពីមុនមក លែងដឹងអស់ អត់ដឹង។ សូមអស់យោបល់។

**ស៖** តើលោកធ្លាប់ឮឈ្មោះ សោ ភឹម ទេ?

**ឆ៖** អត់ដែលឮទេ សោ ភឹម សោអីហ្នឹងទេ មិនដឹងនៅណាផង។

**ស៖** អីចឹងលោកចូលរួមជាមួយទ័ពធំជាមួយ គន់ គីម ក្រោយមកទៀតក្លាយជាអង្គរក្សរបស់សម្ដេច ហ៊ុន សែន ហើយឥឡូវហ្នឹងលោកប្រាប់ខ្ញុំថា លោកមិនស្គាល់ សោ ភឹម<>ទេ?

[១៤:០៨:៣០]

**ឆ៖** បាទ ចង់និយាយអីចឹង ព្រោះខ្ញុំអត់ស្គាល់មែន។ គន់ គីម ស្គាល់តែពីរំដោះហើយហ្នឹងទេ ពេលដែលចាប់ដៃគ្នាប្រហែល១ខែរំដោះហ្នឹង។ មុនហ្នឹងក៏ស្គាល់ ដឹងគាត់ធ្វើអីផង។ សូមអស់យោបល់។

**ស៖** លោកសាក្សី មានភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលបង្ហាញថា អ្នកភូមិទាំងអស់នៅក្នុងបូព៌ា <ឬអតីត>ភូមិភាគបូព៌ាសុទ្ធតែស្គាល់ សោ ភឹម <ជានរណា> ហោចណាស់ក៏ធ្លាប់ឮអំពីហេតុការណ៍ សោ ភឹម<ដែរ>។ ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ ថាលោកពិតជាមិនដែលឮឈ្មោះ សោ ភឹម ហ្នឹងមែនទេ?

**ឆ៖** ខ្ញុំអត់ដែលឮទេ ព្រោះខាងនេះវាអត់ឮ មិនដឹងគាត់ធ្វើខាងអី សោ ភឹម។ អត់ដឹងសោះ អត់ស្គាល់ទេ។

**ស៖** តើលោកធ្លាប់ឮឈ្មោះ ចាន់ ដែលជាប្រធានតំបន់២១ ដែរឬទេ?<>

**ឆ៖** អត់ដែលបានឮទេឈ្មោះហ្នឹង។ និយាយទៅ ទាំងចៅហ្វាយស្រុកក្រូចឆ្មារហ្នឹង ក៏អត់ស្គាល់ដែរ ដល់សួរដល់តំបន់ទៀត លែងស្គាល់បាត់ហើយ។ ស្គាល់តែមេឃុំម្នាក់ហ្នឹង ដែលឈ្មោះ ហ៊ុន ហ្នឹង ខុសពីហ្នឹងអត់ស្គាល់ មិនបាច់សួរទេ។ អត់ស្គាល់ទាំងអស់។ ពេលនោះស្គាល់តែមេឃុំហ្នឹងមួយទេ ចៅហ្វាយស្រុក ស្រុកខ្លួនឯង ក៏អត់ដែលស្គាល់ផង ទៅសួរដល់តំបន់ទៀតចប់បណ្ដោយ អត់ស្គាល់ទេ។

**ស៖** ខ្ញុំជួយរំឭកលោកបន្តិច ប្រហែលជាលោកអាចនឹកឃើញ។ តើលោកស្គាល់ឈ្មោះ អ៊ុក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01216738



ប៊ុនឈឿន ដែរឬទេ?

[១៤:១០:៤១]

**ធ៖** អត់ស្គាល់ អ៊ុក ប៊ុនឈឿន ផង នៅណាផង។ អត់ដែលស្គាល់ទេ។

**ស៖** ប្រហែលជាខ្ញុំអានមិនច្បាស់ឈ្មោះនេះ។ តើខ្ញុំអានត្រូវទេ គឺឈ្មោះ អ៊ុក ប៊ុនឈឿន បច្ចុប្បន្នហ្នឹងគឺជារដ្ឋមន្ត្រីជាន់ខ្ពស់មួយរបស់គណបក្សប្រជាជនកម្ពុជា?

**ធ៖** អត់ស្គាល់ទេបាទ។ អត់ដែលស្គាល់ មិនដឹងគាត់នៅខាងណា ធ្វើអីផង។

**ស៖** ឥឡូវនេះខ្ញុំនិយាយពីឈ្មោះ <ចាន់> វិញគឺ <សេង ហុង ហៅ ចាន់> ប្រធានតំបន់២១ <>ហើយ អ៊ុក ប៊ុនឈឿន ជាអនុរបស់គាត់ <រហូតដល់ឆ្នាំ៧៨>។ នៅចំពោះមុខខ្ញុំ ខ្ញុំមានកំណត់ហេតុស្តាប់ចម្លើយរបស់កូន<ប្រុស>គាត់មួយ គឺកូន<ប្រុស>របស់លេខាតំបន់<ឈ្មោះ ចាន់> គឺ E3/5531 សំណួរចម្លើយ៦៦។ គាត់បាននិយាយអំពីការប្រជុំមួយដែលគាត់ចូលរួមជាមួយឪពុករបស់គាត់ គឺ<ប្រហែលឆ្នាំ៧៩ ឬ>ឆ្នាំ៧៨ ហើយឪពុករបស់បុគ្គលម្នាក់នេះគឺឈ្មោះ <ចាន់> បាននិយាយដូចតទៅនេះ៖ “កុំនិយាយអំពីអ្វីដែលកន្លងមក នៅក្នុងតំបន់២១។ គាត់ប្រាប់ខ្ញុំឲ្យប្រាប់<អតីត>អ្នកនៅក្រោមបង្គាប់<គាត់>មិនឲ្យនិយាយអ្វីទាំងអស់ ហើយឲ្យធ្វើអត់ដឹងឮពីតំបន់២១។ ហើយឲ្យប្រាប់ថាខ្លួនឯងហ្នឹងជាកសិករនៅ<> កំពង់ត្របែក។” លោកសាក្សី តើលោកធ្លាប់ឮការបញ្ជា<ណាមួយ>ឲ្យនរណាម្នាក់ <>នៅ<អតីត>ភូមិភាគបូព៌ាហ្នឹងគឺថាធ្វើជាមិនដឹងខ្យល់អីអំពីហេតុការណ៍នៅក្នុងតំបន់ ២១ នេះដែរឬទេ?

**ធ៖** បាទ អត់ដែលឮ អត់ដែលដឹងផង។ អត់មានឮអ្នកណាហាមអីចឹងផង។ អត់ទាំងស្គាល់ឈ្មោះ ចាម ហ្នឹងទៀត មិនដឹងនៅខាងអីផង អត់ស្គាល់ទេបាទ។

[១៤:១៣:៣៤]

**ស៖** តើលោកធ្លាប់ឮឈ្មោះ ហែម សាមីន ទេ?

**ធ៖** អត់ឮ។ មិនដឹងគាត់ធ្វើអីផង នៅណា! អត់ដែលឮ អត់ស្គាល់ផង។

**ស៖** ដើម្បីជួយលោកឲ្យយល់ គឺគាត់មានតួនាទីខ្ពស់មួយនៅក្នុងរដ្ឋាភិបាលក្រោយឆ្នាំ៧៩។ តើឈ្មោះ ហែម សាមិន ហ្នឹងធ្វើឲ្យលោកនឹកឃើញអ្វីដែរឬទេ?

**ធ៖** បាទ ខ្ញុំអត់ស្គាល់ ហែម សាមិន ហ្នឹងទេបាទ អត់នឹកឃើញ អត់ដែលស្គាល់ឈ្មោះហ្នឹងផង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ទបកប្រែ និងខ្ទបកប្រែបន្ត។*

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយមកពីសៀវភៅរបស់អ្នកនិពន្ធម្នាក់គឺ សៀវភៅរបស់ ប៉ែន យៀរ និន <E3/1593> ERN<អង់គ្លេស>មានលេខ <00678637>, ខ្មែរមានលេខ<00637770 ដល់ 71>, បារាំងមានលេខ00639034។ ខ្ញុំសូមដកស្រង់៖ "ហែម សាមិន គឺជាកុម្មុយនីស្តដែលបណ្តុះបណ្តាលនៅហាណូយ ហើយជាអ្នកទោសនយោបាយនៅក្នុងតំបន់ បានបន្ទោសលេខា<ភូមិភាគរបស់បក្សកុម្មុយនីស្តកម្ពុជា> សោ ភឹម អំពីការគាបសង្កត់<លើកដំបូង>ទៅលើជនជាតិចាមនៅក្នុងតំបន់។ គឺគាត់ជាអ្នក<ចុះហត្ថលេខា>បញ្ជាឲ្យ ពង់ សម្លាប់ជនជាតិចាម<នៅភូមិទ្រា>នៅក្នុងឆ្នាំ៧៤ គាត់ហ្នឹងកាចណាស់។" ដូច្នេះទោះបីថាលោក<មិន>ស្គាល់ ហែម សាមិន ទោះបីថា ៗលោកមិនស្គាល់ សោ ភឹម តាមអ្វីដែលលោកនិយាយ តើលោកធ្លាប់ឮអំពីអ្នកណាម្នាក់និយាយថា អតីតលេខាភូមិភាគបូព៌ា <សោ ភឹម>គឺជាអ្នកទទួលខុសត្រូវ<> ឬក៏ថាអាចតាមរយៈសម្តេច ហេង សំរិន ឬក៏សម្តេច ហ៊ុន សែន <ចំពោះ>ការគាបសង្កត់ទៅលើការបះបោររបស់ជនជាតិចាមនៅឆ្នាំ<៧៥ និង>៧៤ ដែរឬទេ?

**ឆ៖** អត់មានទេ។ អត់ដែលឮពាក្យហ្នឹងទេ តាំងពី៧០មក រហូតមកដល់ឥឡូវអត់មានឮពាក្យអ៊ីចឹង គាបអ៊ីចឹងផង អត់មានទេ។

[១៤:១៦:៤២]

**ស៖** តើលោកធ្លាប់ឮឈ្មោះ ប៉ុល សារឿន ដែរឬទេ?

**ឆ៖** ឮតែពេលគាត់ សព្វថ្ងៃហ្នឹងឮ តែពីដើមមកអត់ដឹងគាត់ធ្វើអីផង។

**ស៖** តើឥឡូវហ្នឹងគាត់មានតួនាទីអ្វីដែរ?

**ឆ៖** គាត់មានតួនាទីអគ្គបញ្ជាការយោធពលខេមរភូមិន្ទណោះ។

**ស៖** អ៊ីចឹងៗគាត់ជាមេរបស់ គន់ <គីម> តើអ៊ីចឹងមែនទេ?

**ឆ៖** អត់ដឹងទេ ពីដើមមក ប៉ុន្តែឥឡូវមេហើយ។

**ស៖** ខ្ញុំជួយលោកបន្តិចឲ្យលោកនឹកឃើញ។ តើលោកដឹងទេថា ប៉ុល សារឿន គឺអនុប្រធានទី២របស់សេនាធិការភូមិភាគ គឺក្រោម ហេង សំរិន មួយថ្នាក់ តើលោកដឹងទេ?

**ឆ៖** អត់បានដឹងទេបាទ។ អត់ដឹងទេ ពីរឿងមុនមក អត់ដឹងផង។

**ស៖** ចុះតើលោកដឹងថា ប៉ុល សារឿន ដើរតួនាទីអ្វីនៅក្នុងជួរកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាដែរទេ?

**ឆ៖** បាទ អត់ដឹងផង អត់ដឹងទេ។ ពេលនោះអត់ដឹងថាគាត់នៅក្នុងជួរហ្នឹងដែរ ក៏អត់ដឹងដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចុះលោកធ្លាប់ឮឈ្មោះមនុស្សម្នាក់ឈ្មោះ ម៉ាត់ លី?

**ឆ៖** បាទ ឮ ម៉ាត់ លី ឮឈ្មោះ។

**ស៖** ចុះគាត់ជាអ្នកណាដែរ?

**ឆ៖** អត់ដឹងគាត់ជាអ្នកណាផង អត់ស្គាល់ទេ។ គ្រាន់ស្គាល់ ឮតែឈ្មោះគាត់។

[១៤:១៩:២៨]

**ប្រធានអង្គជំនុំ៖**

បើគាត់មិនស្គាល់ផង ហើយម៉េចដឹងថា ម៉ាត់ លី ជាអ្នកណា។ ហើយមេធាវីដូចជាប្រើប្រាស់ពេលវេលាច្រើនហើយ ហើយសំណួរដូចជាមិនមានផលប្រយោជន៍អ្វីពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះធ្វើសវនាការនេះទេ។ គួររៀបចំសំណួរឡើងវិញ ពិតមែនតែយើងអត់ផ្តត់ក្នុងការមិនកាត់លោកមែន ប៉ុន្តែយើងឃើញថា សំណួរដែលឆ្លើយថាមិនដឹង ហើយលោកចេះតែបន្តការតាំងសំណួរនូវវត្ថុ នូវអ្វីដែលសាក្សីមិនដឹងនោះ លោកធ្លាប់បានតតាំងបានតែ ជំទាស់ច្រើនលើកច្រើនសាហើយចំពោះភាគីដទៃទៀតដែលប្រើប្រាស់សំណួរប្រភេទនេះ។ សូមរំឭកលោកថា គួររៀបចំនូវសំណួរណាដែលមានប្រយោជន៍ដែលសាក្សីដឹង ដើម្បីអាចឈានដល់ការស្វែងរកការពិត ចូលរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

វាជាការពិតហើយ លោកប្រធាន។ យើងនាំគ្នាស្វែងរកការពិតទាំងអស់គ្នា។ <ប៉ុន្តែខ្ញុំបានឮសាក្សីនិយាយថា-->

**ប្រធានអង្គជំនុំ៖**

យើងប្រាប់លោកថា អ្វីដែលសាក្សីមិនដឹង លោកមិនគប្បីសួរនូវអ្វីដែលសាក្សីមិនដឹងនោះតទៅទៀតទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជឿកជាក់ថា សាក្សីស្គាល់ឈ្មោះ ម៉ាត់ លី។ គាត់ថា គាត់ស្គាល់។

[១៤:២០:៤៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំស្តាប់ឮតាមរយៈការបកប្រែជាភាសាអង់គ្លេស គាត់ថា “បាទ”។ អ៊ីចឹងសូមលោក សូមសួរ

សំណួរហ្នឹងឡើងវិញ សំណួរដែលថាស្គាល់នោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកទើបតែឆ្លើយថា លោកបានស្គាល់ឈ្មោះ ម៉ាត់ លី មែនទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ឮឈ្មោះ ម៉ាត់ លី បានស្គាល់គាត់ ផ្ទាល់អត់ស្គាល់ទេ។ អ្នកណាមិនឮ តាម៉ាត់ លី នោះ ខ្ញុំជនជាតិចាមដែរ ឮតែគាត់ហ្នឹង ឮហើយ ប៉ុន្តែមិនដែលបានទំនាក់ទំនងជាមួយគាត់ ស្គាល់ថាគាត់ធ្វើៗវាអត់ដឹងទេ។ អត់ស្គាល់ទេ ឮតែឈ្មោះគាត់។ អ្នករំដោះជាតិអីមក ជាមួយសម្ដេចអីអ៊ីចឹងទៅ។ តែប៉ុណ្ណឹង ស្គាល់តែប៉ុណ្ណឹង។ ហេតុអីមុននេះ ខ្ញុំមិនដែលស្គាល់គាត់នេះផង។

**ស៖** មិនថ្វីទេលោកសាក្សី ខ្ញុំបន្តទៅមុខទៀតចុះ។ នៅពេលដែលឆ្លើយទៅនឹងតំណាងសហព្រះរាជអាជ្ញា លោកបានឆ្លើយថា សូមដកស្រង់៖ “ខ្មែរក្រហមបានចូលមកដល់ស្រុកក្រូចឆ្មារ ក្នុងឆ្នាំ៧៥” តើពិតដែរទេថា ដែលថាទឹកដីស្រុកក្រូចឆ្មារនេះ បានធ្លាក់ទៅក្នុងដៃខ្មែរក្រហមតាំងពីឆ្នាំ៧០មកម្ល៉េះ ពិតឬក៏មិនពិត?

**ឆ៖** អត់ដឹងថាខ្មែរក្រហម ខ្មែរខៀវផងកាលហ្នឹង មកតែមនុស្សតែមួយហ្នឹង ប៉ុន្តែយូរទៅ កាន់តែតឹងទៅ តឹងទៅ មិនដឹងខាងណាខាងណើ។ មកដំបូងអត់មានធ្វើបាបសម្លាប់ប្រជាជនទេ ប៉ុន្តែដល់យូរទៅ ចេះតែមានបញ្ហាអីចឹងទៅ។ សូមអស់យោបល់។

[១៤:២២:៤២]

**ស៖** ពិតហើយលោកសាក្សី លោកអាចឆ្លើយថា ខ្មែរក្រហមពិតជាបានចូលមកដល់គ្រប់គ្រងទឹកដីក្រូចឆ្មារតាំងពីឆ្នាំ៧០ ឬក៏ឆ្នាំ<ដែលរំដោះភ្នំពេញ>។

**ឆ៖** ឆ្នាំ៧០នោះ ដឹងខ្មែរក្រហម ខ្មែររណសិរ្សអីទេ ប៉ុន្តែគេមិនសូវអីទេ ជំនាន់នោះ ដល់៧៥មក គឺមានការកាប់សម្លាប់អីអ៊ីចឹង ដឹងតែប៉ុណ្ណឹង។

**ស៖** ប៉ុន្តែប្រជាជននៅភូមិទ្រាប្រហែលជាមិនយល់ស្របជាមួយលោកទេ។ ប៉ុន្តែត្រឹមត្រូវដែរទេ ដែលថា<អ្នកទទួលខុសត្រូវ>នៅក្នុងខែកញ្ញា, តុលា ៧៥ <គឺជាមនុស្សតែមួយដែលបាន> គ្រប់គ្រង<ស្រុកក្រូចឆ្មារ>នៅក្នុងឆ្នាំ១៩៧០ <ហើយនិងឆ្នាំបន្តបន្ទាប់មកទៀត>?

**ឆ៖** អត់ដឹងពីណាគ្រប់គ្រង ខ្ញុំអត់ស្គាល់ផង អត់ដឹង។

**ស៖** ប៉ុន្តែព្រឹកមិញនេះ លោកបានឆ្លើយថា ជាពិសេសទាក់ទងទៅនឹងព្រឹត្តិការណ៍ឆ្នាំ៧៥ សូម

ដកស្រង់៖ “អង្គការថ្នាក់លើបានចាប់ពួកក្បត់”។ តើលោកចង់មានន័យ<>ថាម៉េចដែរ នៅពេលដែលលោកនិយាយ<បែបនេះ>?

**ឆ៖** ឃើញមកចាប់ប្រជាពលរដ្ឋ ហើយនិងមេតួន ហាកឹម ជីអីយកទៅសម្លាប់ហ្នឹង ហ្នឹងគេនិយាយមកថាថ្នាក់លើ ដឹងថ្នាក់ដល់ណា មកចាប់យកទៅអស់ហើយ។ ឲ្យតែតួន ឲ្យតែអ្នកចេះដឹង យកទៅអស់ហើយ យកទៅសម្លាប់អស់ហើយ។ យកទៅមិនដែលឃើញមកវិញផង ថាយកទៅរៀនសូត្រ យកទៅអប់រំអីណានេះ មកទៅបាត់ឈឹង។ ទាំងតួន ទាំងកឹម ទាំងជី អ្នកចេះដឹងប៉ុន្មានៗទៅអស់រលីងហើយ។ វាអង្គការថ្នាក់លើ សំដៅខាងណាថ្នាក់លើ។ សុទ្ធអង្គការជំនាន់នុ៎ង។ សូមអស់យោបល់។

**ស៖** ប៉ុន្តែលោកមិនដឹងថា អង្គការថ្នាក់លើជាអ្នកណាទេ មែនទេ?

**ឆ៖** ដឹងថា ប៉ុល ពត ថ្នាក់លើហ្នឹង។ ប៉ុល ពត ហ្នឹងហើយអ្នកបញ្ជាមកថ្នាក់ក្រោមហ្នឹង មិនដឹងម៉េច ព្រោះរបបៗ ប៉ុល ពត ហ្នឹងហើយ។

[១៤:២៦:៥៥]

**ស៖** ឥឡូវនិយាយគ្នាអំពី ប៉ុល ពត បន្តិច។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានប្រើឈ្មោះ ប៉ុល ពក ជាបងប្អូន<ប្រុស>ជាមួយនឹង កែ ពក។ តើ<>លោកបានប្រភពព័ត៌មានមកពីណា? <ប្រភពនៃការដឹងរបស់លោកមកពីណា?>

**លោក ត្រាវីស ហ្វារ៖**

តាមដែលខ្ញុំដឹងយល់ ក្រោយពីអានប្រតិចារឹកមក គាត់បានឆ្លើយថា ប៉ុល ពក គឺជា<បង>ប្អូន<របស់>របស់ ប៉ុល ពត មិនថា កែ ពក ទេ។ អ៊ីចឹងសូមបញ្ជាក់ឲ្យបានច្បាស់ចំណុចនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនថ្វីទេ។ តើព្រឹកមិញនេះលោកបានឆ្លើយថា ប៉ុល ពក គឺជា<បង>ប្អូន<ប្រុស>របស់ ប៉ុល ពត ឬ?

**<លោក វ៉ាន់ ម៉ាត់៖>**

**ឆ៖** បាទ ឮតៗគ្នាថាអ៊ីចឹង ថាប្អូនរបស់ ប៉ុល ពត។ ប៉ុល ពក ហ្នឹងប្អូនរបស់ ប៉ុល ពត។ អ្នកក្រៅខ្លះគេហៅ កែ ពក អ៊ីចឹង។ អាហ្នឹងឮតាមរយៈប្រជាពលរដ្ឋដែលគេដឹងឮតៗគ្នាមកថា ប៉ុល ពក ហ្នឹងថាបងប្អូន ប៉ុល ពត ហ្នឹងហើយ ធ្វើមេភូមិភាគកណ្តាលហ្នឹង។ អ៊ីចឹងបានគាត់សាហាវម្ល៉េះនោះ គាត់ថាអ៊ីចឹងណ៎ា។ សូមអស់យោបល់។

**ស៖** ចុះឥឡូវនេះ លោកដឹងថា ប៉ុល ពក និង កែ ពក មិនមែនជាបងប្អូន<ប្រុស>នឹងគ្នាទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ អត់ដឹងច្បាស់ទេរឿងហ្នឹង ឮតៗគ្នាពីជំនាន់នោះមក។ ខ្ញុំមិនទៅស្រាវជ្រាវរឿងប្រវត្តិគេឯណា អត់ដឹង។

**ស៖** ខ្ញុំសូមត្រឡប់ទៅនិយាយការបះបោរឆ្នាំ៧៥។ សហព្រះរាជអាជ្ញាសួរលោក និយាយអំពី <>លោកឃើញ<>ទូកកងទ័ពនៅមាត់ទន្លេ។ សូមលោករៀបរាប់បន្តិចមើល ទូកកងទ័ពនៅឯមាត់ទន្លេនោះ។

[១៤:២៨:២១]

**ឆ៖** កងឃោធារបស់ ប៉ុល ពត គេមកបង្ក្រាបអ្នកបះបោរនៅកោះផលទុំង នៅមាត់ទន្លេ ហើយគេចាប់ដឹកជញ្ជូនអ្នកសេសសល់ ស្រីៗប្រពន្ធរបស់ប្រជាពលរដ្ឋនៅហ្នឹងយកដាក់ទូក មិនដឹងយកទៅណាទេ ខ្ញុំអត់ដែរ។ គេចូលតាមក្នុងព្រែករកាខ្នុរហ្នឹងបណ្ដោយ ជិតភូមិជំនីកហ្នឹង។ ប្រជាជនគេធ្វើនេសាទគេប្រាប់ថា ឃើញដឹកទៅអស់ហើយ ទៅចូលទៅព្រៃអស់ហើយ មិនដឹងយកទៅដល់ណា។ ដឹកប្រជាជននៅកោះផលទុំង ជម្លៀសទៅក្នុងព្រៃ ស្រាប់បាត់ទាល់ឥឡូវហ្នឹង។ ថាចោទថា ប្រឆាំងជាមួយ ប៉ុល ពត ហ្នឹង ប្រឆាំងជាមួយអង្គការហ្នឹង គេយកទៅអស់ហើយ អ្នកភូមិកោះផល។ ដល់៧៩មកទៅមើល គ្មានសល់ម្នាក់ អត់មានមនុស្ស សុទ្ធដើមឈើ។ សូមអស់យោបល់។

**ស៖** ខ្ញុំមិនគិតថា អ្នកភូមិកាលពីឆ្នាំ៧៥ ឮសូរឈ្មោះ ប៉ុល ពត ទេ។ លោកសាក្សី តើលោកធ្លាប់ឮឈ្មោះ ប៉ុល ពត ហ្នឹងតាំងពីឆ្នាំ៧៥មកដែរ ឬក៏អត់ទេ?

**ឆ៖** បាទ ឮរហូតមក ឮតាំងពីមុន៧៥ទៀត។

**ស៖** ចុះលោកធ្លាប់ឮឈ្មោះ ហ្វុលរ៉ូ ឬក៏ខ្មែរ-ស ដែរទេ?

**ឆ៖** អត់ឮផង អត់ដែលឮ។

**ស៖** តើលោកធ្លាប់ឮ សូមយោងទៅឯកសារ E3/1568, ERN អង់គ្លេស 00651889, ខ្មែរ 00713962, បារាំង 00743361។ នេះជាកិច្ចសម្ភាសន៍ជាមួយលោក ហេង សំរិន ថា៖ "ក្នុងឆ្នាំ ១៩៧៦, ៧៧ យើងមានការតស៊ូសម្ងាត់។" បញ្ចប់ការដកស្រង់។ តើលោកធ្លាប់ឮ ហេង សំរិន គាត់និយាយអំពីចលនាតស៊ូសម្ងាត់នៅក្នុងឆ្នាំ៧៦, ៧៧ នោះដែរទេ?

[១៤:៣១:១៦]

**ឆ៖** បាទ មិនបានដឹងទេ អត់ឮទេ។ ៧៧ ចិតអឺនៅក្មេងតូចៗ អត់ដឹងអីទេខ្ញុំ។

**ស៖** ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លោកធ្លាប់ស្តាប់ឮអង្គប្រជុំដែលគេប្រជុំដឹកនាំដោយ <កែ> ពក <>។ <ឥឡូវ និយាយពីរឿងហ្នឹងសិន។> តើធ្វើម៉េចបានជាលោកដឹងថា មេឃុំអាចទៅចូលរួមអង្គប្រជុំដែលដឹកនាំដោយ <កែ> ពក ទៅបាន?

**ឆ៖** បាទ ពេលនុ៎ងគេកោះហៅទាំងចៅហ្វាយស្រុក ទាំងមេឃុំ ព្រោះគោលដៅសំខាន់ គេជម្លៀសចាមនៅឃុំជំនីកនុ៎ង។ ដល់អ៊ីចឹងគេត្រូវហៅមេឃុំទៅ ដើម្បីចាត់វិធានការបោសសម្អាតប្រជាជនចាមនៅក្នុងឃុំជំនីកហ្នឹង បានឃុំនុ៎ងគេត្រូវការទៅ ព្រោះផែនការគេចាំបាច់ ឃុំហ្នឹងមានជនជាតិចាមនៅសេសសល់ជាច្រើន។ ដល់អ៊ីចឹងគេត្រូវហៅមេឃុំហ្នឹងដែលមេឃុំទើបនឹងមកថ្មី ឲ្យមេឃុំហ្នឹងមកបោសសម្អាតប្រជាពលរដ្ឋចាមនៅនុ៎ង។ មិនមែនថាចាមទេ មានទាំងខ្មែរ មានទាំងចិនទៀត។ សូមអស់យោបល់។

**ស៖** ហេតុផលដែលខ្ញុំសួរទៅលោក ដោយសារថាមានភ័ស្តុតាង<ជាច្រើន>បញ្ជាក់ថា មេដឹកនាំភូមិភាគភាគច្រើននេះ គឺថានិយាយទៅកាន់មេតំបន់ ឬក៏មេស្រុក ប៉ុន្តែកម្រនឹងបាននិយាយទៅកាន់មេឃុំណាស់។ តើ<ពេលលោកជូនដំណើរ>មេឃុំនេះ <គាត់>មានបានប្រាប់លោកថា នេះគឺជាករណីពិសេសទេ<>?

[១៤:៣៣:២៥]

**ឆ៖** គេមិនប្រាប់ថា ករណីពិសេសទេ។ គាត់ថាទៅជាមួយចៅហ្វាយស្រុក ដើម្បីប្រជុំទទួលផែនការពីប្រធានភូមិភាគ។ អាហ្នឹងអ៊ីចឹង ព្រោះគោលដៅខ្លាំងបំផុតហ្នឹងនៅជំនីកហ្នឹងហើយ ព្រោះហ្នឹងមានសភាពការណ៍ល្បីថា មានចោរព្រៃនៅទីតាំងចំណុចនុ៎ង។ មានខាងចោរព្រៃអីមកពីណាពីណីនោះ មករំខានការជម្លៀសរបស់អង្គការ។ ដល់អ៊ីចឹងគាត់ចេះតែបារម្ភទៅ គាត់ដាក់ផែនការមកកម្ទេចឲ្យអស់តែម្តងទៅ កុំវាសេសសល់ទៅមុខទៀត នាំពិបាក។ អស់យោបល់។

**ស៖** តើមេឃុំគាត់អាចយល់ពាក្យថា “បោសសម្អាត” បានដោយរបៀបម៉េចដែរ?

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន គឺគាត់បានសួរទៅ<សាក្សីនេះ ពីអ្វីដែល>អ្នកណាម្នាក់យល់ពាក្យហ្នឹង<។> លើកលែងតែមានការសន្ទនាគ្នា <>រវាងសាក្សីរូបនេះ ជាមួយមេឃុំពេលនោះ <គាត់គ្មានមធ្យោបាយអីដឹងថា មេឃុំនោះយល់ពីន័យរបស់ពាក្យនោះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនអ្វីទេ ខ្ញុំរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកមានបាននិយាយទៅកាន់មេឃុំ ដើម្បីចង់ដឹងថាពាក្យ "បោសសម្អាត" មានន័យថា ដូចម្តេចនោះទេ? <>

[១៤:៣៤:៥៦]

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ ខ្ញុំមានសិទ្ធិអីទៅសួរគាត់ទេ ខ្លាចញ៉រខ្លួនហើយ អ្នកណាទៅហ៊ានសួរថ្នាក់ហ្នឹង។ គាត់មានសិទ្ធិសម្លាប់មនុស្ស ថ្នាក់ត្រឹមមេឃុំហ្នឹង ចង់សម្លាប់ទាំងអស់ក៏បានដែរ នៅក្នុងឃុំហ្នឹង។ មានដូចថាតុលាការដូចឥឡូវណា ត្រឹមសិទ្ធិត្រឹមមេឃុំអាចយកមនុស្សទៅសម្លាប់បានហើយ ពេញភូមិហ្នឹង។ អ្នកណាទៅមានសិទ្ធិសួរគាត់ អត់មានសិទ្ធិសួរទេ រឿងគាត់ទៅណាមកណើ យើងអត់មានដឹងទេ។ គេប្រើយើងទៅ គឺទៅតាមគេតែម្តង ឲ្យទៅងាប់ក៏ទៅដែរ កុំថាប្រើទៅនេះ។ សូមអស់យោបល់។

**ស៖** លោកសាក្សី លោកបាននិយាយថា លោកបានស្តាប់ឮអ្នកនិយាយនៅក្នុងអង្គប្រជុំ ទោះជាអ្នកណាក៏ដោយចុះ គឺថានិយាយគ្នាអំពីចំនួនតួលេខភាគរយនៃប្រជាជន គឺ<៥០ភាគរយនៃ>ប្រជាជនចាមនេះតែម្តង។ តើលោក<អាចចាំថាបានឮចំនួន>តួលេខ<>ភាគរយ<ហ្នឹងទេ>?

**ឆ៖** ទេ មិននិយាយរឿងភាគរយជនជាតិចាមទេ។ គេសួរខាងតំបន់មួយៗ ដែលអង្គការដាក់ផែនការមកកម្មេចហ្នឹងបានប៉ុន្មានភាគរយ។ សួរមកថ្នាក់ក្រោមហ្នឹង។ ថ្នាក់ក្រោមជូនកាលឆ្លើយថាបាន ៣០ ខ្លះ៥០អ៊ីចឹងទៅ។ ដឹងកម្មេចរឿងអីខ្លះ យើងអត់ដឹង ព្រោះយើងអត់ទៅធ្វើមេគេផង។ ដឹងតែប៉ុណ្ណឹង។

[១៤:៣៦:៤៩]

**ស៖** លោកសាក្សី ច្បាស់ណាស់ថាលោកមិនបានដឹង ខ្ញុំនេះបានពិនិត្យមើលឯកសារទាំងអស់<និយាយអំពីការប្រជុំ>ដែលលោកបានរៀបរាប់<>នុ៎ង។ ហើយក៏មានការនិយាយគ្នាអំពីចំនួនភាគរយ<>ពាក់ព័ន្ធទៅ<នឹងផែនការ ឬកសិផល> និងទិន្នផលស្រូវ។ គឺ<គេតែងតែ>និយាយថា៥០ភាគរយនៃផែនការត្រូវបានបញ្ចប់។ តើលោកឮសួរគេនិយាយអំពីចំនួនភាគរយនេះ <ប្រហែលជានិយាយចម្រុះគ្នា>សំដៅទៅលើទិន្នផលស្រូវ ឬក៏សំដៅទៅ<ការផលិតកសិផល>?

**ឆ៖** បាទសំដៅស្រូវ គេថាស្រូវហើយ អានេះមិនថាស្រូវ យកមកកម្ទេចហ្នឹងមានស្អី យកស្រូវទៅកម្ទេចដែរ មានយកមនុស្សទៅកម្ទេច។ អាហ្នឹងគេសំដៅលើមនុស្សហ្នឹងហើយ អនុវត្តកម្ទេចមនុស្សប្រជាពលរដ្ឋហ្នឹង។ បើសិនជាសំដៅលើស្រូវ គេថាស្រូវហើយ អានេះកម្ទេច។ សូមអស់យោបល់។

**ស៖** ចុះធ្វើម៉េច<បានលោកដឹង>ក្នុងនាមលោក<> ជាអ្នកភូមិសាមញ្ញម្នាក់ <ថានៅពេលដែលកម្មាភិបាលនិយាយក្នុងកិច្ចប្រជុំនោះ ហើយប្រើពាក្យ ភាគរយ គឺគេសំដៅទៅលើកសិផល និងទិន្នផលស្រូវ តើធ្វើម៉េចលោកដឹងរឿងនេះ? តើលោកបានចូលរួមកិច្ចប្រជុំផ្សេងទៀតទេ>?

**ឆ៖** ព្រោះយើងធ្លាប់នៅក្នុងកងចល័ត មេបក្សរបស់ ប៉ុល ពត ហ្នឹងប្រជុំអារឿងអ៊ីចឹង។ ប្រជុំអារឿងអីណា វាទុកក៏មិនចំណេញដកចេញក៏មិនខាត ធ្លាប់ឮពាក្យហ្នឹងច្រើន។ អង្គការគេដាក់អ៊ីចឹង ថាទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ យកទៅកម្ទេចចោល។ សូមអស់យោបល់ យល់ថាអ៊ីចឹង មិនមិនយល់អីទេ។

**ស៖** លោកសាក្សី លោកមិនដែលធ្លាប់ឮគេនិយាយនៅក្នុងអង្គប្រជុំ នៅពេលដែលគេនិយាយគ្នាអំពីការបោសសម្អាត ឬក៏ការកម្ទេចនោះទេ។ មែនទេ?

[១៤:៣៩:២០]

**ឆ៖** គេសំដៅរឿងបោសសម្អាតកម្ទេចហ្នឹងហើយខាងបូព៌ាហ្នឹង ព្រោះមកបោសមែន បោសគ្រាន់ជាទ័ពបូព៌ារត់ខ្ចាត់ខ្ចាយអស់ហើយ។ រួចដល់អស់ទ័ពទៅ មិនយកប្រជាជនទៅទៀត ប្រជាជនសុទ្ធតែខ្លួនក្បាលយួន ខ្លួនខ្មែរអីណាណី។ ចោទគ្នាអ៊ីចឹង គ្នាទៅដើរធ្វើអីហ្នឹង ភ្លូរតែស្រែ លើកតែទំនប់ហ្នឹង រួចមកចោទគ្នាថា អីខ្លួនខ្មែរក្បាលយួន សេ.អ៊ី.អា អីណាណីវែងឆ្ងាយណាស់។ អស់យោបល់។

**ស៖** សំណួរចុងក្រោយលោកសាក្សី។ តើវាមានគុណវុឌ្ឍិអីខ្លះ លក្ខណៈសម្បត្តិអ្វីខ្លះដែលនាំឲ្យលោកក្លាយទៅជាអង្គរក្សរបស់សម្តេច ហ៊ុន សែន?

**ឆ៖** អាហ្នឹងទឹកចិត្តរបស់ខ្ញុំទៅជួយការពារគាត់ទៅ មានស្អី! មានអ្នកណាទៅនេះ។ ទឹកចិត្តខ្ញុំតើ! គាត់បានធ្វើល្អកន្លងមក ខ្ញុំទៅ សុខចិត្តទៅការពារធ្វើអង្គរក្សគាត់ទៅ។ ខ្ញុំជាកូនទាហានមួយសាមញ្ញ។ សូមអស់យោបល់។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនពេលសម្រាកអំមិញគឺថា ខាងមេធាវី វ៉ិចទ័រ កូប៉េ ថាអស់សំណួរហើយ តើអស់ដោយសារពេលវេលា ឬក៏អស់ដោយសារមិនមានសំណួរទៀត?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំបាននិយាយបែបនេះមែន ហើយប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំនៅមានពេលវេលាបួនប្រាំនាទីទៀតសម្រាប់ការសួរសំណួរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលដែលយើងឈប់សម្រាក ខ្ញុំបានសួរអំពីការចូលរួមរបស់លោកជាមួយនឹងទ័ពធំរបស់ គន់ គីម <និងការប្រយុទ្ធគ្នាចំនួនពីរ ដែលលោកបានរៀបរាប់>។ តើលោកអាចនឹកឃើញអ្វីខ្លះទាក់ទងទៅនឹងការប្រយុទ្ធ<នោះ>? ថាតើមានជនស៊ីវិលស្លាប់ដែរឬទេ? តើទ័ពម្ខាងទៀតមានអ្នកស្លាប់ដែរឬទេ? តើលោកខ្លួនលោកផ្ទាល់មានបានបាញ់សម្លាប់ខ្មាំងដែរឬទេ? តើលោកចាំអំពីចំណុចណាខ្លះនៃសមរភូមិទាំងពីរនេះទេ?

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** នៅចាំ។ ពេលនោះជនស៊ីវិលអត់មានទេ មានតែកម្លាំងទ័ពនិងទ័ពបានប្រយុទ្ធគ្នា មានការ

របួស មានការស្លាប់ខ្លះក្នុងពេលប្រយុទ្ធគ្នា ទាំងសត្រូវ ទាំងកងទ័ពរំដោះ។

[១៥:០២:៤៦]

**ស៖** តើទ័ពហ្នឹងវាមានទំហំបែបណាដែរនៅពេលដែលវាយប្រយុទ្ធជាមួយគ្នា?

**ឆ៖** ទ័ពរាងតូចដែរ ទ័ពវ៉ៃផ្អក់ទៅវិញទៅមកហ្នឹង ម្ខាង៥០, ១០០អីហ្នឹង ដែលពួកប៉ុល ពត មកកៀរយកប្រជាពលរដ្ឋ ពួកយើងខ្ញុំចេះតែបាញ់តបតកុំឱ្យវាកៀរទៅបានហ្នឹង ក៏បាញ់ប្រយុទ្ធគ្នាទៅ។ បានបាញ់ទៅយកតាមចិត្តវា ប្រជាជនងាប់អស់ហើយ អ៊ីចឹងបាញ់តបតជាមួយពួកវាទៅ។ អស់យោបល់។

**ស៖** ហើយសមរភូមិដែលលោកបានវាយប្រយុទ្ធនោះ <តើ>នៅពេលដែលលោកនៅក្នុងកងទ័ពគន់ គីម ហ្នឹង<ឬ? បើមែន> តើពេលនុ៎ងគាត់ជាមេបញ្ជាការលើទ័ពធំហ្នឹងមែនទេ?

**ឆ៖** បាទ គាត់មេបញ្ជាការលើទ័ពធំ គាត់បញ្ជាចុះវ៉ៃនៅខេត្តកំពង់ចាម។

**ស៖** <> តើគាត់ជាមួយនឹងទ័ពរបស់លោកហ្នឹងមានបានចូលរួមនៅក្នុងការបាញ់ពន្លិចកាណូត <>ដូចដែលលោកនិយាយព្រឹកមិញដែរឬទេ?

**ឆ៖** ពន្លិចកាណូតមិនមែនកងទ័ពគាត់មកទេ កងទ័ពខាងផ្លូវជាតិទៅកំពង់ចាម។ មកខាងខ្ញុំកាណូតការពារតាមមាត់ទន្លេ ដល់ ប៉ុល ពត យកកាណូតមកត្រៀមដឹកជញ្ជូនប្រជាពលរដ្ឋយកទៅសម្លាប់។ កងទ័ពគាត់អត់ដឹងទេ កងទ័ពគាត់នៅនោះ នៅត្បូងឃ្មុំធ្វើដំណើរឆ្ពោះទៅទីរួមខេត្តកំពង់ចាម។ រួចខាងខ្ញុំក៏នៅខាងស្រុកក្រូចឆ្មារនោះទេ នៅការពារប្រជាពលរដ្ឋហើយនិងកម្ទេចកាណូតរបស់ប៉ុល ពត សម្រាប់ត្រៀមដឹកជញ្ជូនប្រជាពលរដ្ឋយកទៅវ៉ៃចោលហ្នឹង។ ប៉ុណ្ណឹង។

[១៥:០៤:៥៦]

**ស៖** លោក ហើយនិងយុទ្ធជនបានចូលរួមនៅក្នុងការបាញ់ពន្លិចកាណូតយោធា<ទាំងនោះ>។ តើអ៊ីចឹងមែនទេ?

**ឆ៖** អាកាណូតហ្នឹង កាណូតយោធាសម្រាប់ដឹកប្រជាពលរដ្ឋយកទៅវ៉ៃចោល។ ដល់អ៊ីចឹងកងយុទ្ធជនរបស់ខ្ញុំហ្នឹង ក៏ទៅកម្ទេចកាណូតហ្នឹង មិនឱ្យវាបើកទៅបានទៀត។ អាពតអាល័យតែដេញវ៉ៃគ្នាហ្នឹង មានកម្លាំងខ្ញុំមួយក្រុមទៅកម្ទេចកាណូតហ្នឹង កុំឱ្យវាបើកបរទៅមុខបានទៀត។ សូមអស់យោបល់។

**ស៖** ហើយយុទ្ធជនដែលលោកនិយាយហ្នឹង តើពួកគេជានរណាដែរ? តើគេជាទាហានរបស់

គន់ គីម ឬក៏ជា<ពួកគេជាអតីតសមាជិក>កងចល័ត? <តើកងកម្លាំងហ្នឹងជារបស់អ្នកណា?> ថាតើ <>ទាហានដែលបាញ់ពន្លិចកាណូតហ្នឹង តើពួកគាត់មកពីខាងណាដែរ?

**ឆ៖** មានទាហានមកខាងណា មានកងចល័តហ្នឹងហើយ។ ដល់បង្កើតជាក្រុមដើម្បីតស៊ូប្រឆាំងប៉ុល ពត ហ្នឹង កងចល័តអត់មានទ័ពធំមកពីណាទេ។ ទ័ពធំគេវៃតាមទីរួមខេត្តអីធំៗអីចឹងទៅ។ ទ័ពខាងខ្ញុំនៅកំប៉ិកកំប៉ុកនៅតាមមូលដ្ឋាន តាមភូមិ តាមស្រុក ដើម្បីការពារកុំឲ្យខ្មែរក្រហមយកប្រជាជនទៅវៃចោល ប៉ុណ្ណឹង។ អត់មានទ័ពណាធំមកសហការនៅនោះជាមួយទេ។ មានទ័ពមួយក្រុមរបស់ឯកឧត្តម សៀក សុជាតិ ប្រចាំការនៅរកាខ្នុរ មានក្រុមរបស់គាត់ដែរ មកសហការគ្នា។ ទ័ពគាត់តូចដែរ ម្ភៃសាមសិបនាក់ទេ។ អស់យោបល់ប៉ុណ្ណឹង។

[១៥:០៧:០០]

**ស៖** អ៊ីចឹងកង<ពលតូច>ចល័តហ្នឹង គឺកង<ពលតូច>ចល័តតែមួយ ដែលលោកនិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកថា មានមនុស្សប្រហែលជា៣០០នាក់<មានទាំងជនជាតិខ្មែរ និងចាម> តើមែនទេ?

**ឆ៖** ហ្នឹងហើយ ពិតមែនហើយ កងកម្លាំងចល័តហ្នឹងហើយ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោក ហើយនិងយុទ្ធជន នៅក្នុងកង<ពលតូច>ចល័តរបស់លោកនោះ តើលោកធ្វើយ៉ាងណា អាចបំពេញបេសកកម្មនេះបាន? តើលោកទទួលបានការបណ្តុះបណ្តាល ឬក៏ការហ្វឹកហ្វឺនណាមួយដែរឬទេ នៅពេលដែលលោកចុះវៃ បាញ់ពន្លិចកាណូតនោះ?

**ឆ៖** មានការបណ្តុះបណ្តាលពីខាងណាទេ ដោយសារកម្លាំងឈឺចាប់ កម្លាំងតស៊ូប៉ុណ្ណឹង។ មានកាំភ្លើងចេះតែបាញ់បានហើយ ឲ្យខ្ញុំប្រាប់អានេះ មានតែនេះហ្នឹង គ្រាន់តែបាញ់កាណូតមួយ ពិបាកអី។ បាញ់តិចទៅ លិចហើយ។ អត់អ្នកណាហ្វឹកហ្វឺនអីទេ ចេញពីកងចល័តមូលមកបណ្តោយ។ សូមអស់យោបល់។

**ស៖** អ៊ីចឹងមានន័យថា លោកប្រើកាំភ្លើងទាំង១៥ដើម ដូចដែលបានលោកបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយហ្នឹង គឺលោកប្រើកាំភ្លើង១៥ដើម ដើម្បីបាញ់ពន្លិចកាណូតហ្នឹង តើមែនទេ?

**ឆ៖** ហ្នឹងហើយ ពន្លិចកាណូតហ្នឹងហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធានដែលបានផ្តល់ពេលវេលាបន្ថែមនេះដល់ខ្ញុំ។ សូមអរគុណ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៥:០៨:៥២]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានការឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំនឹងចោទសំណួរបន្ថែមទៅលោកមួយចំនួនទៀត។ សំណួរទី១របស់ខ្ញុំ ទាក់ទងទៅនឹងឆ្នាំ១៩៧៥ដែលនៅក្នុងឆ្នាំនេះ លោកបាននិយាយថា ខ្មែរក្រហមបានមកដល់តំបន់លោករស់នៅ។ ហើយនៅពេលដែលលោកឆ្លើយទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំដូចជាយល់ថា លោកបានឆ្លើយថា មានកិច្ចប្រជុំមួយទាក់ទងទៅនឹងការហាមមិនឲ្យប្រតិបត្តិសាសនា។ ខ្ញុំចោទសំណួរនេះទៅលោកពីព្រោះថា នៅក្នុងចម្លើយរបស់លោក កាលពីឆ្នាំ<២០០៨> គឺឯកសារ E3/5209 លោកបានឆ្លើយថា នៅ ERN ជាភាសាបារាំងគឺ 00293937, ERN ជាភាសាខ្មែរគឺ 00218537, ERN ជាភាសាអង់គ្លេសគឺ 00242067។ លោកបានឆ្លើយថា៖ “មិនមានកិច្ចប្រជុំ ឬ<សេចក្តីថ្លែងការណ៍>នយោបាយប្រឆាំងនឹងយើងទេ ក៏ប៉ុន្តែគេនិយាយថា ការជំនឿលើសាសនាអ៊ីស្លាមនេះ គឺជាជំនឿមួយ។” អ៊ីចឹងសំណួរខ្ញុំសួរថា តើពិតជាមានកិច្ចប្រជុំមួយ<>និយាយអំពីការប្រតិបត្តិសាសនាដែរឬទេ<>?

[១៥:១១:០៥]

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ពេលប្រជុំហ្នឹង មិនហាម មិនឲ្យគោរពប្រណិប័តន៍តាមសាសនាអ៊ីស្លាម។ ប្រជុំហ្នឹងរួមទាំងខ្មែរទាំងអស់ហ្នឹង ទាំងសាសនាព្រះពុទ្ធក៏មិនឲ្យប្រណិប័តន៍ដែរ។ មិនមែនប្រជុំតែចាមទេ គឺប្រជុំរួមទាំងអស់មួយឃុំហ្នឹងបណ្តោយ។ ហាមទាំងខ្មែរ ទាំងចាម ហើយមិនឲ្យតាមសាសនា គោរពសាសនាទាំងអស់គ្នាហ្នឹង។ សូមអស់យោបល់។

**ស៖** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ នៅពេលដែលនិយាយថា មិនមានកិច្ចប្រជុំនៅក្នុងចម្លើយដែលលោកបានឆ្លើយមុននេះ <តើ>លោក<ចង់>និយាយថា មិនមានកិច្ចប្រជុំជាក់លាក់ណាមួយ ពាក់ព័ន្ធ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01216751



ទៅនឹងសាសនាអ៊ីស្លាមទេ ក៏ប៉ុន្តែជាកិច្ចប្រជុំ<ព័ត៌មានទូទៅ>មួយ<ពិភាក្សាអំពី>ការប្រតិបត្តិសាសនាជាទូទៅទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** អត់ត្រឹមត្រូវទេ។ មានការប្រជុំអីច្បាស់លាស់។ អស់ពីប្រជុំហើយ បានមកផ្សព្វផ្សាយស្ងាត់តាមក្រុម តាមអីទៀត។ សូមអស់យោបល់។

**ស៖** តើរូបលោកផ្ទាល់ហ្នឹង លោកបានចូលរួមក្នុងកិច្ចប្រជុំហ្នឹងដែរឬទេ?

**ឆ៖** ចូលរួមប្រជុំ។ នៅយុវជន គេហៅតែទាំងអស់តាម ឲ្យទៅចូលរួមប្រជុំទាំងអស់ហ្នឹង។ តែនារី ស្រីៗហ្នឹងក៏ឲ្យកាត់សក់ខ្លីដែរ ស្រីៗចាមហ្នឹង មិនឲ្យទទូរក្រមា មិនឲ្យអី។ សូមអស់យោបល់។

[១៥:១៣:២០]

**ស៖** អ៊ីចឹងយើងយល់ស្របគ្នាថា នៅក្នុងកិច្ចប្រជុំហ្នឹង គឺថាមានបងប្អូនចាម ហើយក៏មានខ្មែរផងដែរ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ហ្នឹងហើយ មានបងប្អូនចាម ហើយនិងខ្មែរទាំងអស់ទៅចូលរួមប្រជុំ។ សូម្បីតែខ្មែរហ្នឹងក៏ឲ្យកាត់សក់ខ្លីដែរ កុំថាតែចាម រត់ទាំងអស់គ្នា។ សូមអស់យោបល់។

**ស៖** នៅពេលដែលលោកឆ្លើយសំណួរសហព្រះរាជអាជ្ញាកាលពីព្រឹកមិញ ទាក់ទងទៅនឹងចំនួនប្រជាជននៅក្នុងភូមិរបស់លោកនោះ លោកបាននិយាយពីចំនួនប្រជាជនថា មាន១០.០០០នាក់ ក៏ប៉ុន្តែឥឡូវខ្ញុំសូមឲ្យលោកបំភ្លឺចំណុច<នេះ> ថាតើក្នុងចំណោមមនុស្សទាំង ១០.០០០នាក់នេះដែលលោកថាមានទាំងចាម ទាំងខ្មែរបូកបញ្ចូលគ្នា ព្រោះពេលមួយលោកនិយាយថា នៅក្នុងភូមិលោកហ្នឹង ថានៅក្នុងឆ្នាំ៧៥ គឺមានខ្មែរពាក់កណ្ដាល ចាមពាក់កណ្ដាល? អ៊ីចឹងខ្ញុំចង់សួរលោកថា តើចំនួន១០.០០០នាក់ហ្នឹងគឺបានន័យថា ចាម ហើយនិងខ្មែរបូកបញ្ចូលគ្នា <>ឬក៏យ៉ាងណា?

**ឆ៖** មិនមែនទាំងខ្មែរទាំងចាម១០.០០០ទេ នៅក្នុងឃុំហ្នឹងមនុស្សជាច្រើនម៉ឺននាក់។ ថាចាមមួយភូមិទេដែល១០.០០០ ចាមវាមានបីភូមិនៅក្នុងឃុំជំនីកហ្នឹង។ ភូមិ<ជំនីក>មួយហ្នឹង វាមាន១០.០០០នាក់ជាងបាត់ហើយ។ ខ្មែរផ្សេងទៀត។ សូមអស់យោបល់។

**ស៖** ក្នុងចំណោមមនុស្សទាំង១០.០០០នាក់នេះ តើមានទាំងចាមមានទាំងខ្មែរ ឬក៏យ៉ាងម៉េចនៅក្នុងភូមិ<ជំនីក>នេះ?

[១៥:១៥:៤៥]

**ឆ៖** ក្នុង១០.០០០នាក់ហ្នឹងមានតែចាមទេ មិនសរុបដល់ខ្មែរទេ នៅក្នុងភូមិជំនីក។ គាត់សួរ

ព្រឹកមិញហ្នឹងគាត់សួរថាភូមិហ្នឹងមានប៉ុន្មាន ចាមហ្នឹង? យើងនិយាយតែចាមទេ អត់មាននិយាយពាក់ព័ន្ធដល់ខ្មែរទេ។ ខ្មែរផ្សេងទៀត។ ខ្ញុំមិនអ្នកធ្វើស្ថិតិ ខ្ញុំដឹងមិនអស់ទេ វៃត្រួសៗ។

**ស៖** អ៊ីចឹងឲ្យច្បាស់លាស់តែម្តង តើលោកប៉ាន់ស្មានចំនួន<>ហ្នឹង ដោយឈរលើមូលដ្ឋានអីដែរ? <តើលោកធ្វើម៉េចបានដឹងចំនួនជាក់លាក់យ៉ាងនេះ?>

**ឆ៖** លើមូលដ្ឋានរាប់មើលគ្រួសារហ្នឹងមានប៉ុន្មានគ្រួសារហ្នឹង ប៉ុណ្ណឹង ប៉ាន់ស្មាន។

**ស៖** កាលពីព្រឹកមិញ លោកបានឆ្លើយថាមាន១០.០០០នាក់។ តើលោកអាចបញ្ជាក់បានដែរឬទេ ថា<តើមានចំនួន>ប៉ុន្មានគ្រួសារដែរ<ដែលអាចឲ្យលោកប៉ាន់ស្មានអ៊ីចឹង> បើតាមលោកចាំនោះ?

**ឆ៖** ១០.០០០នាក់ហ្នឹងស្មើជាង១.០០០គ្រួសារ។ អាហ្នឹងក្នុងមួយភូមិ<ជំនីក>ហ្នឹង ជាង១.០០០គ្រួសារ។

**ស៖** តើលោកមុខងារអីជាក់លាក់ដែរឬទេ នៅក្នុងភូមិ<ជំនីក>នុ៎ង?

**ឆ៖** អត់មានមុខងារអីផង។

**ស៖** តើលោកមានចំណេះដឹង<ច្បាស់លាស់>អំពីចំនួនគ្រួសារ<> ដោយសារគេប្រាប់លោក ឬក៏ដោយថាតាមការចងចាំរបស់លោក<>?

**ឆ៖** កាលហ្នឹងមានប្រធានភូមិមានអីគេប្រាប់។

**ស៖** ហើយប្រធានភូមិហ្នឹងឈ្មោះអីដែរ? គាត់ប្រាប់លោកហ្នឹងពេលណាដែរ?

**ឆ៖** ឈ្មោះ ម៉ាត់ ហ៊ីម។

[១៥:១៨:៥៣]

**ស៖** ហើយគាត់ប្រាប់ពីចំនួនគ្រួសារនៅក្នុងភូមិហ្នឹង ទៅដល់លោកហ្នឹង នៅពេលណាដែរ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយ!

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ក្នុងឆ្នាំ១៩៧៧។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើ ម៉ាត់ ហ៊ីម ហ្នឹងគាត់ជាជនជាតិចាម ឬក៏យ៉ាងណា?

**ឆ៖** គាត់ជនជាតិចាម។

**សៈ** តើលោកមានដឹងដែរឬទេ ថាតើគាត់នៅតែធ្វើជាមេភូមិរហូតដល់ឆ្នាំ១៩៧៩ ឬក៏យ៉ាងណា?

**ឆៈ** គាត់នៅធ្វើ ដល់ពេលហ្នឹង គាត់ឈប់មួយសាហើយ ប៉ុន្តែក្រោយ៧៩មក គាត់ធ្វើមួយសាទៀត។ ពេលហ្នឹងរត់ចូលព្រៃអស់ហើយ មានអ្នកណាធ្វើអី មេភូមិអីទៀត។ ដល់រំដោះហើយបានគាត់មកធ្វើជាមេភូមិម្ដងទៀត។ សូមអស់យោបល់។

**សៈ** តើលោកដឹងដែរឬទេថា នៅពេលណាដែរដែលគាត់បានឈប់ធ្វើជាប្រធានភូមិ? <ព្រោះលោកនិយាយថា នៅឆ្នាំ១៩៧៧ គាត់នៅតែជាប្រធានភូមិ។> តើគាត់បានដូរមុខងារហ្នឹងនៅពេលណាដែរ? <>

[១៥:២០:៤៤]

**ឆៈ** ដល់៧៨ ព្រោះពេលប៉ុល ពត កំពុងនៅរៀបចំជម្លៀសប្រជាពលរដ្ឋទៅហ្នឹង គាត់ឈប់គាត់ ក៏រត់ចូលព្រៃទៅ ក៏ខានធ្វើទៅ មានប្រធានភូមិ មានប្រធានអីទាំងអស់ហ្នឹង។ សូមអស់យោបល់។

**សៈ** តើលោកមានដឹងថា អ្នកណាជាអ្នកឡើងធ្វើជាប្រធានភូមិជំនួសគាត់ដែរឬទេ<>?

**ឆៈ** អត់មានប្រធានភូមិទេ ព្រោះរត់ចូលព្រៃអស់ហើយ។ ទាល់តែថ្ងៃរំដោះ០៧ មករា ហើយបានបង្កើតប្រធានភូមិថ្មីតទៀត។

**សៈ** ដូច្នេះបើខ្ញុំយល់មិនច្រឡំទេ គឺថាគាត់ធ្វើប្រធានភូមិរហូតដល់ពេលដែលលោក រូបលោកផ្ទាល់ដែរហ្នឹង<>បានរត់ចេញទៅដែរ អ៊ីចឹងមែនទេ?

**ឆៈ** ហ្នឹងហើយការពិតហើយ។

**សៈ** ឥឡូវនេះខ្ញុំសូមចូលនិយាយអំពីពេលដែលលោកនៅកងចល័តដែលលោកបាននិយាយកាលពីព្រឹកមិញ។ លោកបានឆ្លើយទៅកាន់សហព្រះរាជអាជ្ញាថា ពីដំបូងទី គេចាត់ឲ្យលោកទៅមើលយាមគោក្របី ហើយបន្ទាប់មកទៀតគេឲ្យលោកលើកទំនប់ជាមួយប្រជាជនផ្សេងទៀត<ពេលលោក>នៅក្នុងកងចល័ត។ តើលោកចាំដែរឬទេ ថាតើលោកបានចាប់ផ្ដើមចូលធ្វើការក្នុងកងចល័តហ្នឹងចាប់ពីពេលណាដែរ?

**ឆៈ** កងចល័តហ្នឹងតាំងពី៧៧, ៧៨ហ្នឹងរហូតមក។

[១៥:២២:៥៣]

**សៈ** កាលពីព្រឹកមិញ លោកបានឆ្លើយថាកងចល័តរបស់លោកហ្នឹងមានចាមផង ខ្មែរផង។ តើ

លោកនៅចាំដែរឬទេថា នៅក្នុងកងចល័តលោកហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរ<>?

**ឆ៖** ខ្ញុំអត់ដឹងច្បាស់ទេ វាច្រើនរយ ច្រើនពាន់ដែរ មិនតិច។ អត់បានរាប់ អត់ដឹង ព្រោះយើងមិនមែនប្រធាន កូនចៅគេដែរ ប៉ុន្មានៗអត់ដឹងទេ។ គេប្រើរែកទំនប់ រែកទំនប់ គេប្រើដងទឹក ដងទឹក អត់ដឹងចំនួន។

**សៈ** នៅពេលដែលលោកឆ្លើយទៅកាន់សហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5209 ERN ជាភាសាបារាំងគឺ <00293937>, ជាភាសាខ្មែរគឺ 00218537, ជាភាសាអង់គ្លេស 00242068។ លោកបានឆ្លើយថា៖ "នៅពេលណាមួយ<នោះ> មានកម្មាភិបាលសូមឲ្យលោកយាមនៅមន្ទីរពាណិជ្ជកម្ម។" តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាកម្មាភិបាលរូបណាដែលចាត់តាំងឲ្យលោកធ្វើដូចនេះ ទៅយាមនៅមន្ទីរពាណិជ្ជហ្នឹង? ហើយនៅពេលណាដែរ គេចាត់លោកឲ្យធ្វើការនៅទីនោះ?

**ឆ៖** កម្មាភិបាលថ្នាក់ឃុំហ្នឹងហើយ នៅកាន់ពាណិជ្ជកម្មឃុំហ្នឹង សម្រាប់ដោះស្រាយស្បៀងជូនកងចល័តកងអីហ្នឹង នៅឃុំ ថ្នាក់ឃុំ។ នៅឆ្នាំ១៩៧៧។

**សៈ** លោកយាមមន្ទីរហ្នឹង លោកមានអាវុធដែរឬទេ?

**ឆ៖** គ្មានទេ គ្មានអាវុធទេពេលហ្នឹង។ យាមគ្រាន់តែដេកយាមហ្នឹង មានអាវុធអីទៅការពារអី អត់មានអាវុធមានអីទេ។ យាមដូចឃ្វាលគោហ្នឹង វាទៅធ្វើអី មានអាវុធមានអី។ សូមអស់យោបល់។

[១៥:២៥:៣៩]

**សៈ** លោកបានឆ្លើយថា នៅពេលណាមួយនោះ -- ឥឡូវខ្ញុំកំពុងតែនិយាយអំពីឆ្នាំ៧៨ ព្រោះថាលោកថា <> លោកបានជូន<មេ>ឃុំ<>ទៅចូលរួមកិច្ចប្រជុំហ្នឹង។ ហើយនៅឆ្នាំ៧៨ លោកបានឆ្លើយពីព្រឹកមិញថា លោកបានជូនមេឃុំទៅកិច្ចប្រជុំមួយនៅភូមិភាគកណ្ដាល។ អ៊ីចឹងលោកមេឃុំហ្នឹង លោកចង់សំដៅទៅលើមេឃុំដែលលោកបានជូនទៅចូលរួម កិច្ចប្រជុំនៅភូមិភាគកណ្ដាលហ្នឹង ឬក៏បុគ្គលផ្សេងម្នាក់ទៀត?

**ឆ៖** គ្មានបុគ្គលផ្សេងទេ មេឃុំចាត់យើងឲ្យជូនទៅបណ្ដោយ។ មេឃុំទើបមកថ្មី ប៉ុល ពត ទើបចាត់តាំងមកថ្មីថ្មោងបណ្ដោយ។ ពេលគាត់មកដល់ថ្មីថ្មោងហ្នឹង គាត់អាចបោសសម្អាតមេឃុំចាស់សហករណ៍ស្អីៗ មេក្រុម ប្រធានបាយ ប្រធានអី រោងបាយអី គាត់យកទៅកម្ទេចអស់ហើយ។ គាត់នៅតែគាត់ មកគាត់រៀបចំថ្មីទាំងអស់។

**សៈ** តើជាមេឃុំឈ្មោះ អូន? <សម្រាប់អ្នកបកប្រែ ឈ្មោះនេះសរសេរថា-អេ-យូ-អ៊ិន> តើ

ឈ្មោះ អួន <>មិនមែន<ទេ>?

**ឆ៖** ឈ្មោះ អួន ហ្នឹងមេឃុំរងទេ។ ឈ្មោះមេឃុំហ្នឹងឈ្មោះ ហ៊ុន មេឃុំ។ ឈ្មោះ ហ៊ុន មេឃុំ, អួន រង ១ឃុំ។

**ស៖** ព្រឹកមិញលោកបានឆ្លើយថាគឺ ហ៊ុន ហ្នឹងហើយជាមេឃុំ<ដែល>លោកជូនគាត់<> ហើយទៅប្រជុំនៅភូមិភាគកណ្ដាលនោះ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរទេ<>?

**ឆ៖** ត្រឹមត្រូវ។ គាត់ហៅជូនទៅដល់កន្លែងប្រជុំហ្នឹង។

[១៥:២៨:៣៧]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺលោកបានឆ្លើយថា <នៅថ្ងៃនោះ>ចៅហ្វាយស្រុក<ក៏មានវត្តមាន>ផងដែរ <>ហើយ<>នីរសាររបស់គាត់ជូន<គាត់>ទៅប្រជុំដោយជិះម៉ូតូដែរ។ អ៊ីចឹងខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំចោទសំណួរនេះ ដើម្បីសុំការបំភ្លឺលោកនេះ ពីព្រោះថាដោយសារលោកចៅក្រម ឡាវែន៍ គាត់បានអានជូនលោកស្ដាប់អំមិញហ្នឹងគឺថា មានលោក ឧស្នាន គាត់បានសរសេរអត្ថបទមួយចំនួន។ អ៊ីចឹងដែលយើងឃើញហាក់ដូចជាមានកំហុសបន្តិចបន្តួច។ អ៊ីចឹងខ្ញុំសូមអាន ដកស្រង់ចេញពីសៀវភៅលោក អ៊ីសា ឧស្នាន គឺឯកសារ E3/9323 ជាភាសាបារាំងគឺ 00286658, ERN ជាភាសាខ្មែរគឺ 00275387, ERN ជាភាសាអង់គ្លេសគឺ 00218542។ មានសរសេរដូចតទៅនេះ ទាក់ទងនឹងរូបលោកផ្ទាល់មានសរសេរដូចតទៅ៖ “គាត់ប្រាប់ថាចុងឆ្នាំ១៩៧៨ គាត់បាន<ជិះ>ម៉ូតូ<ដឹក>លេខាស្រុកដែលគាត់អត់ចេះជិះម៉ូតូ ឲ្យទៅចូលទៅប្រជុំនៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ។” សូមបញ្ចប់ការដកស្រង់។ <> បើតាមអ្វីដែលលោកបានឆ្លើយបញ្ជាក់អម្បាញ់មិញនេះគឺថា លោកមិនមែនជូនលេខាស្រុកទេ ប៉ុន្តែលោកបានជូនមេឃុំឈ្មោះ ហ៊ុន <>ទៅចូលរួមកិច្ចប្រជុំហ្នឹង។ អ៊ីចឹងលោកអាចបញ្ជាក់បានដែរឬទេ <តើលោកក៏បញ្ជាក់ថា មានកំហុសនៅក្នុង>សម្រង់ដែលខ្ញុំទើបអានជូនលោកស្ដាប់អម្បាញ់មិញនេះ <>?

[១៥:៣១:០៨]

**ឆ៖** មេឃុំ ហើយនិងលេខាស្រុកហ្នឹងទៅរួមដំណើរជាមួយគ្នា។ ដំបូងថាជូនមេស្រុកទេ រួចដល់មេឃុំនេះគេអត់ចេះជិះម៉ូតូ មេស្រុកគេមានម៉ូតូមួយតែគេទៅ គេទៅជិះរួមដំណើរទាំងអស់គ្នាទៅ

ហ្នឹង។ មេឃុំគេទើបដូរថ្មី អត់ចេះជិះម៉ូតូ។ សូមអស់យោបល់។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែហើយ ពីព្រោះតាមរយៈការបកប្រែដែលខ្ញុំស្តាប់ឮនេះ ប្រហែលជាមានបញ្ហាបកប្រែ។ អ៊ីចឹងខ្ញុំសួរលោកម្តងទៀត លោកសាក្សី ខ្ញុំសោកស្តាយ ខ្ញុំសូមឲ្យលោកឆ្លើយម្តងទៀត ខ្ញុំឮជាភាសាបារាំងតាមរយៈការបកប្រែហ្នឹង គេថាលោកនោះត្រូវបានគេចាត់តាំង<លោកទៅ>ឲ្យ<>លេខាស្រុក។ អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ទេ សួរថាតើកាលនោះៗលោកបានជូនមេឃុំទៅប្រជុំ <មិនមែន>ជូនលេខាស្រុកទៅប្រជុំ<ទេ មែនទេ>?

**ឆ៖** មកពីបច្ចេកទេសបកប្រែទេ ខ្ញុំនិយាយទាំងពីរហ្នឹង ទាំងមេឃុំ ទាំងលេខាស្រុកហ្នឹង។ បកប្រែម៉េច ខ្ញុំអត់ដឹងដែរ ព្រោះពេលនោះគេរួមដំណើរទាំងពីរនាក់ហ្នឹង។ សូមអស់យោបល់។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែម៉ូតូដែលលោកបើកហ្នឹង គឺជាម៉ូតូរបស់មេឃុំទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ម៉ូតូនោះមិនមែនម៉ូតូរបស់មេឃុំទេ ម៉ូតូរបស់ខាងពាណិជ្ជកម្មហ្នឹង។ ដល់អ៊ីចឹងមេឃុំនេះគេសុំយកទៅ នៅកន្លែងអង្គភាពពាណិជ្ជកម្ម។ សូមអស់យោបល់។

**ស៖** ខ្ញុំសូមអរគុណដែលបានឆ្លើយលម្អិត។ អ៊ីចឹងខ្ញុំចង់សួរឲ្យលោកបញ្ជាក់មួយសាទៀត គឺលោកហ្នឹង អង្គាល់ហ្នឹងលោកជាអ្នកបើកម៉ូតូជូនមេឃុំទៅប្រជុំ។ តើអ៊ីចឹងមែនទេ?

[១៥:៣៣:៥៩]

**ឆ៖** អាហ្នឹងពេលជូនទៅ មុននឹងជូនទៅ គាត់សួរទៅខាងប្រធានចល័ត។ គាត់សួរថាមានសមមិត្តណាចេះបើកម៉ូតូអត់? ប្រធានចល័តក៏ប្រាប់ថាខ្ញុំ។ ដល់អ៊ីចឹងក៏សុំសំណូមពរខ្ញុំឲ្យជូនទៅ ជូនមេឃុំហើយនិងចៅហ្វាយស្រុកទៅប្រជុំនៅកន្លែងកំពង់ធំ។ ទៅពីនេះទៅជិះកាណូត។ ទៅដល់ស្ទឹងត្រង់លើកម៉ូតូឡើង ម៉ូតូបានគ្រាន់ជិះបន្តទៀតតាមចម្ការលើស្ទឹងត្រង់ ឆ្ពោះទៅកំពង់ធំ។ សូមអស់យោបល់។

**ស៖** អ៊ីចឹងខ្ញុំសន្និដ្ឋានថា លោកជាអ្នកបើកម៉ូតូ<លោក>ជូនមេឃុំទៅប្រជុំ ហើយ<>លេខាស្រុកនោះ<ជិះម៉ូតូមួយទៀតជាមួយនីរសារគាត់>ទៅប្រជុំដែរ<>។ ខ្ញុំនិយាយសរុបអ៊ីចឹង ត្រឹមត្រូវដែរទេ?

**ឆ៖** ចៅហ្វាយស្រុកគេមានលេខារបស់គាត់ជូន កងការពារគេ ជិះម៉ូតូជូនគេទៅ។ សូមអស់យោបល់។

**ស៖** តើលោកចាំឈ្មោះលេខាស្រុកហ្នឹងទេ នៅពេលហ្នឹង?

**ឆ៖** អត់បានចាំទេ លេខាហ្នឹង។ គាត់ទើបតែមកបានមួយភ្លែតហ្នឹង ក៏ទៅហ្នឹង។ គាត់ជិះម៉ូតូ គាត់មិនដែលបាននិយាយគ្នាផង គាត់ជិះតែគាត់ យើងជិះតែយើង។ អ្នកណាទៅហ៊ានសួរគាត់នោះ គាត់ថ្នាក់ប៉ុនណាប៉ុនណី។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំអានជូនលោកស្ដាប់អម្បាញ់មិញនេះ គឺសៀវភៅរបស់លោក អ៊ីសា ឧស្មាន មានសរសេរថា ការធ្វើដំណើរទៅហ្នឹង គឺធ្វើដំណើរនៅចុងឆ្នាំ១៩៧៨។ តើខ្ញុំនិយាយអ៊ីចេះ ធ្វើឲ្យលោកនឹកឃើញដែរឬទេ ឬក៏លោកមិនចាំទេ ថាអង្កាល់ដែលលោកជូនគាត់ទៅប្រជុំហ្នឹង គឺនៅចុងឆ្នាំ ៧៨?

[១៥:៣៦:៥៣]

**ឆ៖** បាទ ត្រឹមត្រូវហើយ ចុងឆ្នាំ៧៨។

**ស៖** យើងបានស្ដាប់សាក្សីមួយចំនួននៅចំពោះមុខតុលាការយើងនេះ ដែលបាននិយាយអំពីឈ្មោះបដិវត្តន៍ ឈ្មោះ ហូ ដែលឈ្មោះ ហូ នោះជាឈ្មោះ<ហៅក្រៅរបស់>លេខាស្រុកនៅកាលនុ៎ង។ តើលោកនឹកឃើញទេ? តើឈ្មោះ ហូ ហ្នឹងគឺលេខាស្រុក ឬក៏យ៉ាងណា?

**ឆ៖** បាទ អត់ចាំទេ អត់ដឹងឮឈ្មោះហ្នឹងផង អត់ដែលឮថាឈ្មោះអីផង។ អត់ដែលស្គាល់ទេចៅហ្វាយស្រុក។

**ស៖** តើលោកស្គាល់ឈ្មោះ ប៉ង់ ទេ?

**ឆ៖** បាទ អត់ស្គាល់ទេឈ្មោះ ប៉ង់។

**ស៖** ដោយមិនចាំឈ្មោះគាត់ហ្នឹង <>ក៏ប៉ុន្តែ<>លោក<ចាំ>ថា មានរឿងអីកើតឡើងចំពោះគាត់ទេ?

**ឆ៖** មានពេលគាត់មករៀបចំប្រមូលកងកម្លាំងចល័តហ្នឹង ពេលហ្នឹងកងចល័តហ្នឹងវាយកម្ទេចគាត់ហើយ ស្លាប់ទាំងមេឃុំ ទាំងលេខាស្រុក ទាំងយោធាពីរនាក់ទៀត ពេលកំពុងនៅកៀរប្រជាពលរដ្ឋដាក់កាណូត។ អ៊ីចឹងកងចល័តហ្នឹងគេហៅថាចោរព្រៃ មកបាញ់កម្ទេចពួកហ្នឹង ដើម្បីបំបែកផែនការហ្នឹង។ មានតែឈ្មោះ អូន ហើយហ្នឹងឈ្មោះអីទេរត់រួច។ ខុសពីហ្នឹង ស្លាប់ហើយ។

[១៥:៣៩:៣៤]

**ស៖** ខ្ញុំអត់យល់ចម្លើយរបស់លោកច្បាស់លាស់ <តើលោកជឿ>ថា លេខាស្រុក<>ដែលលោក<និយាយថា មានវត្តមានក្នុងចលនានៅភូមិភាគកណ្ដាល> -- <>អ៊ីចឹងខ្ញុំសួរលោក<ថា តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកជឿ>ថាគាត់ហ្នឹង សព្វថ្ងៃនេះគាត់នៅរស់ ឬក៏ស្លាប់? <តើលោកអាចបញ្ជាក់បានទេ>?

**ឆ៖** គាត់ស្លាប់តាំងពី៧៨ម្ល៉េះ ពេលឡើងមកប្រមូលប្រជាពលរដ្ឋយកទៅសម្លាប់ហ្នឹង ពេលហ្នឹងបានតបតជាមួយកងចល័តហ្នឹង ក៏បាញ់ប្រហារគ្នា ហើយគាត់ស្លាប់ទាំងអស់ទៅ។ គាត់ងាកមកបញ្ជាឲ្យមេឃុំហ្នឹងរៀបចំកាណូតសម្រាប់យកទៅប្រជាជនជម្លៀសតទៀត។

**ស៖** តើលោកប្រាកដថា លេខាស្រុកហ្នឹងហើយដែលស្លាប់នៅពេលដែលគេបាញ់តទល់គ្នា <នោះ>?

**ឆ៖** បាទ ប្រាកដហើយ ព្រោះបានស្លាប់លោកហ្នឹងហើយ បានវាអស់កម្លាំងសម្រាប់មកកៀរប្រជាពលរដ្ឋថែមទៀត អស់មេដឹកនាំ ព្រោះមេដឹកនាំកំពូលគេនៅស្រុកក្រូចឆ្មារហ្នឹងហើយ សម្រាប់បញ្ជាទៅឃុំណា ឃុំណា មកយកប្រជាជន កៀរប្រជាជនយកទៅវាយចោល។ ដល់កម្ចាត់មេដឹកនាំវាបានហ្នឹងហើយ វាអស់ខ្សែរយៈវា។ សូមអស់យោបល់។

**ស៖** ខ្ញុំច្រឡំ នៅពេលដែលខ្ញុំឲ្យឈ្មោះ<ហៅក្រៅចៅហ្វាយស្រុកមុន>ហ្នឹង តាមពិតមិនមែនឈ្មោះ ប៉ង់ ទេ ក៏ប៉ុន្តែនៅសវនាការថ្ងៃទី០៦ តុលា ឆ្នាំ២០១៥ ប្រហែលជាម៉ោង១១:១៩ ទៅម៉ោង១១:២១ សាក្សីឈ្មោះ បាន សៀក បានឆ្លើយថា គាត់ធ្វើជា<ចៅហ្វាយ>ស្រុកក្នុងរយៈពេលមួយ នៅក្រូចឆ្មារ។ គាត់បាននិយាយថាឈ្មោះដែលគាត់ប្រើនៅកាលនោះនុ៎ង គឺឈ្មោះ ហង្ស <>។ អ៊ីចឹងលោកចាំទេ តើលោកនឹកឃើញឈ្មោះ ហង្ស នេះទេ?

[១៥:៤២:៥០]

**ឆ៖** អត់ទេ អត់ចាំទេ ឈ្មោះហ្នឹងអត់ដឹង អត់ដែលឮផង។

**ស៖** តើលោកប្រាកដហើយថា លោកមិនដែលធ្លាប់ឮឈ្មោះ<ហៅក្រៅ> ហូ នេះ? <>

**ឆ៖** បាទ ប្រាកដហើយ អត់ដែលឮ។

**ស៖** ពីព្រោះ<នេះជា>ឈ្មោះ<ហៅក្រៅ>ដែលសាក្សីនុ៎ងបាននិយាយដែរ<។ ចុះចំពោះ> ឈ្មោះ<ហៅក្រៅថា> ផុស <ភី-អេច-អូ-អេស តើលោកចាំ>ទេ?

**ឆ៖** បាទ អត់បានស្គាល់ទេឈ្មោះ ផុស។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំដែលលោកថាបានកើតឡើងនៅចុងឆ្នាំ៧៨ ហើយនៅក្នុងកិច្ចប្រជុំនោះ លោកបាននិយាយថា លោកបានជូនមេឃុំទៅប្រជុំនៅទីនោះ។ តើលោកយល់ស្របជាមួយនឹងខ្ញុំដែរឬទេ <តាមខ្ញុំយល់ពីក្នុងចម្លើយរបស់លោក> ប្រសិនជាខ្ញុំយល់ខុស សូមកែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្ញុំ គឺថាលោកមិនបានទៅចូលក្នុងសាលប្រជុំទេ គឺលោកនៅក្រៅសាលប្រជុំតែប៉ុណ្ណោះទេ។ លោកយល់ស្របនឹងខ្ញុំទេ?

[១៥:៤៤:៤៦]

**ឆ៖** បាទ យល់ស្រប។ អត់មានចូលក្នុងប្រជុំមែន នៅក្រៅ ព្រោះយើងអត់មានតួនាទី ក៏សិទ្ធិអីសម្រាប់ទៅស្ដាប់គេដែរ។ យើងអ្នកជូនគេ គេឲ្យនៅក្រៅ នៅក្រៅហើយ អត់បានចូលរួមប្រជុំនៅក្នុងអីទេ នៅខាងក្រៅសាលា។ សូមអស់យោបល់។

**ស៖** តើលោកមើលឃើញអ្នកដែលចូលរួមប្រជុំនៅក្នុងសាលប្រជុំហ្នឹងដែរឬទេ នៅក្នុងអំឡុងពេលប្រជុំហ្នឹង?

**ឆ៖** អត់បានឃើញទេ ឮតែសំឡេងតាមមីក្រូខាងក្រៅ។

**ស៖** លោកសាក្សី ខ្ញុំចោទសំណួរនេះទៅលោកនោះ ពីព្រោះថានៅក្នុងសម្រង់សៀវភៅរបស់លោក អ៊ីសា ឧស្មាន ដែលខ្ញុំអានជូនលោកអម្បាញ់មិញនេះ គឺឯកសារ E3/9323 លេខ ERN ដដែល។ អ្វីដែលមាននិយាយទាក់ទងនឹងរូបលោកនោះ គឺដូចតទៅនេះ៖ "គាត់បានប្រាប់ថា នៅពេលដែលគាត់កំពុងអង្គុយចាំ គាត់<អាច>ឃើញលេខាស្រុក<>មកពីភូមិភាគបូព៌ា <និងភូមិភាគកណ្ដាល>នៅក្នុងសាលប្រជុំនោះ។" ខ្ញុំសូមបញ្ចប់ការដកស្រង់។ <> តើលោកអាចបញ្ជាក់បានទេថា នៅក្នុងសៀវភៅរបស់លោក អ៊ីសា ឧស្មាន ហ្នឹងគឺថាមានកំហុសឆ្គង ថាដោយសារថា មានសរសេរថា លោក<មិនដែល>ឃើញលេខាស្រុក<>នៅក្នុងពេលប្រជុំ<នោះទេ>?

**ឆ៖** បាទ សួរម៉េច និយាយត្រឡប់ត្រឡិន ខ្ញុំស្ដាប់អត់បាន សូមទោសម្ដងទៀត។ សូមទោសសួរសំណួរម្ដងទៀត។

[១៥:៤៧:០៧]

**ស៖** អត់បញ្ហាអីទេ។ អម្បាញ់មិញនេះ ខ្ញុំសួរលោកថាតើលោកបានឃើញនៅក្នុងសាលប្រជុំនោះ ឃើញអ្នកដែលចូលរួមកិច្ចប្រជុំដែរឬទេ? លោកបានឆ្លើយថា <ទេ។ លោកថា> លោកគ្រាន់តែឮ<គេនិយាយ>។ អ៊ីចឹងក្រោយមក ខ្ញុំបានអានសម្រង់<>ដកស្រង់ចេញពីសៀវភៅ អ៊ីសា ឧស្មាន <ដែលផ្ទុយនឹងអ្វីដែលលោកទើបតែបាននិយាយនេះ> នោះគឺក្នុងសៀវភៅនេះមានសរសេរថា លោក<អាច>ឃើញអ្នកដែលចូលរួមប្រជុំនោះនៅក្នុងសាលប្រជុំ។ អ៊ីចឹងសំណួរខ្ញុំ <> តើលោកអាចបញ្ជាក់បានទេថាក្នុងសៀវភៅនេះ គឺមានកំហុសឆ្គង <ដូចជាកំហុសឆ្គងទាក់ទងទៅនឹងអ្នកដែលលោកបានដឹក

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមម៉ូតូលោកទៅចូលរួមកិច្ចប្រជុំនោះដែរ? ដូច្នេះតើលោកអាចបញ្ជាក់បានទេថា លោកមិនដែលឃើញខាងក្នុងបន្ទប់ប្រជុំនោះទេ ហើយក៏មិនដែលឃើញមនុស្សនៅក្នុងបន្ទប់ប្រជុំនោះដែរ>?

**ឆ៖** លេខាស្រុកនោះទៅជាមួយហើយ ទៅប្រជុំហើយ ប៉ុន្តែចង់ដឹងសួរថានៅក្នុងសាលាកំពុងប្រជុំហ្នឹង ឲ្យខ្ញុំឃើញ ខ្ញុំអត់បានឃើញទេ។ រួចទៅប្រជុំ ដឹងថាទៅប្រជុំហើយ ហើយយើងនៅក្រៅទៅឃើញអ្នកក្នុងនេះប៉ុន្មាននាក់ៗ ខ្ញុំអត់បានឃើញទេ។ ប៉ុន្តែដឹងថាទៅប្រជុំនៅទីនុ៎ង។ អារឿងទៅមើលក្នុងសាលប្រជុំគេ ថាមានមនុស្សប៉ុន្មាន អីប៉ុន្មាន ខ្ញុំអត់ដឹងទេ។ អត់បានឃើញទេ។ សូមអស់យោបល់។

**ស៖** អ៊ីចឹងដើម្បីឲ្យច្បាស់ទាំងអស់គ្នាថា យើងយល់ស្របទាំងអស់គ្នាថា លោកមិនបាន<មើលទៅក្នុងបន្ទប់នោះទេ>?

**ឆ៖** ខ្ញុំអត់បានឃើញ ដែលអ្នកចូលប្រជុំប៉ុន្មាននាក់អត់ដឹងទេ ប៉ុន្តែដឹងថាលេខាស្រុកហ្នឹងទៅប្រជុំនៅទីនុ៎ង។ រឿងប៉ុន្មាននាក់ទៅប្រជុំជាមួយហ្នឹង ខ្ញុំអត់បានដឹងឃើញទេ ប៉ុន្តែដឹងថាលេខាជាមួយមេឃុំហ្នឹង គេទៅចូលប្រជុំក្នុងហ្នឹង។ សូមអស់យោបល់។

[១៥:៤៩:២០]

**ស៖** លោកអាចឆ្លើយនឹងសំណួរខ្ញុំជាក់លាក់បានទេថា ក្រៅពីអ្នកដែលលោកបានជូនទៅប្រជុំនោះ ដូចឧទាហរណ៍ដូចជា មេឃុំ ហើយនិងលេខាស្រុក តើពីរនាក់ហ្នឹង ក្រៅពីអ្នកពីរនាក់ហ្នឹង លោកមានបានឃើញផ្ទាល់ភ្នែកអ្នកចូលរួមប្រជុំផ្សេងទៀតដែរឬទេ?

**ឆ៖** ឃើញពេលគេចេញមកវិញ យើងឃើញ ប៉ុន្តែយើងអត់ស្គាល់គេថាគេជាអ្នកណាផង។ ប៉ុន្តែចេញមកពីប្រជុំទាំងអស់គ្នា មានមនុស្សច្រើន។ ប៉ុន្តែយើងអត់ស្គាល់គេជាអ្នកណាទៅចូលរួមក្នុងថ្នាក់អីផង។ ស្គាល់តែអ្នកទៅជាមួយខ្ញុំពីរបីនាក់ហ្នឹង តែប៉ុណ្ណឹង។ សូមអស់យោបល់។

**ស៖** អ៊ីចឹងយើងយល់ស្របគ្នាថា ក្រៅពីមេឃុំ ហើយនិងលេខាស្រុកហ្នឹង លោកមិនស្គាល់អ្នកណាផ្សេងទៀតទេ នៅក្នុងអ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំហ្នឹង។ តើលោកយល់ស្របនឹងខ្ញុំទេ?

**ឆ៖** បាទ យល់ស្រប។

**ស៖** លោកបាននិយាយថា លោកបានឮឈ្មោះ ពក និយាយតាមមីក្រូ។ តើ<>លោកមានបានឃើញឈ្មោះ ពក ហ្នឹងទេ?

**ឆ៖** អត់បានឃើញទេ។

**ស៖** ទាក់ទងទៅនឹងឈ្មោះ ពក នេះដដែលនេះ ខ្ញុំសូមត្រឡប់មកនិយាយពីឯកសារមួយដែល

មេធាវីលោក នួន ជា បានលើកឡើងគឺជាប្រតិចារឹក -- ខ្សែអាត់នៃកិច្ចសម្ភាសន៍របស់លោក ធ្វើឡើងកាលពីឆ្នាំ២០០៨។ <>ព្រឹកមិញនេះ ខ្ញុំយល់ឃើញថាលោកបានឮនិយាយឈ្មោះ ប៉ុល ពក ហើយនិង កែ ពក។ ហើយ<ព្រឹកមិញ>នេះ <>លោក<បានប្រាប់ខ្ញុំថា> គឺជាមនុស្សតែមួយទេ<>។ តើ<ខ្ញុំយល់ត្រឹមត្រូវ>ទេ?

[១៥:៥១:១៨]

**ឆ៖** បាទ បាននិយាយអ៊ីចឹង ព្រោះអ្នកស្រុកគេហៅឈ្មោះពីរនេះតែមួយ។ ដឹង ប៉ុល ដឹងអាពក ដឹងអាកែ ពក ដឹងតែ ប៉ុល ពក ទេ។ គេថាមេភូមិភាគឈ្មោះពីរហ្នឹង គេហៅដឹងឈ្មោះដើមគេ ក៏ឈ្មោះគេទើបនេះថ្មី យើងអត់ដឹង។

**ស៖** នៅក្នុងឯកសារខ្សែអាត់ដដែលហ្នឹងគឺ E3/5209.1 លោក<>និយាយដូចតទៅនេះ អ្នកបកប្រែសួរលោកដូចតទៅនេះគឺថា៖ “លោកនិយាយថាលោកឮ<>គេនិយាយពី កែ ពក <យ៉ាងច្បាស់> នៅក្នុងកិច្ចប្រជុំហ្នឹង?” ចម្លើយរបស់លោក ៗឆ្លើយដូចតទៅនេះ៖ “ទេគឺឈ្មោះ ប៉ុល ពក ទេ ដែលជាសមាជិកគ្រួសាររបស់ ប៉ុល ពត ហើយមិនមែនឈ្មោះ កែ ពក ទេ។” ហើយលោកបញ្ជាក់ទៀតថា៖ “ពក ហើយនិង <ពត> នេះវាមនុស្សពីរនាក់ខុសគ្នា។ មានមនុស្សម្នាក់គេអន្តរាគមន៍ គេនិយាយសួរ គេធ្វើឆ្ងល់ គេថា៖ “ពក?” ហើយលោកឆ្លើយវិញថា៖ “ហ្នឹងហើយ គាត់ជាបងប្អូននឹងគ្នា។” នៅក្នុងខ្សែអាត់ហ្នឹង <>ខ្ញុំមើលទៅឃើញ<>លោកនិយាយ<ផ្ទុយគ្នានឹងអ្វីដែលលោកបាននិយាយនៅព្រឹកមិញនេះ រវាងប៉ុល ពក និង កែ ពក។ តើលោកអាចជម្រាបជូនតុលាការបានទេ ថាហេតុអ្វីបានជានៅក្នុង២០០៨ លោកនិយាយ>ថា ប៉ុល ពក ហ្នឹងជាបងប្អូនប៉ុល ពត ហើយ<>ថា<មនុស្សម្នាក់នេះមិនមែន> កែ ពក <>ទេ?

[១៥:៥៤:៣១]

**ឆ៖** ការពិត ប៉ុល ពត ហើយនិង ប៉ុល ពក ហ្នឹងបងប្អូនមែន ប៉ុន្តែមនុស្សដែលគេហៅនៅភូមិភាគកណ្តាលហ្នឹងមាន ប៉ុល ពក ហើយនិង កែ ពក ហ្នឹងថាមនុស្សតែមួយទេ។ មិនមែនមនុស្សផ្សេងគ្នាឯណា។

**ស៖** អាហ្នឹងអ្វីដែលលោកនិយាយថ្ងៃនេះទេ ក៏ប៉ុន្តែនៅក្នុងខ្សែអាត់ហ្នឹង លោកនិយាយថា ប៉ុល ពក ហើយនិង កែ ពក ហ្នឹង មនុស្សពីរនាក់ខុសគ្នា។ អ៊ីចឹង<តើ>លោកបានប្រភពមកពីណា <និងពេលណា>? <ព្រោះថ្ងៃនេះលោកប្រាប់យើងរឿងមួយខុសពីមុន។>

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ថាម៉េចនិយាយ? សុំសួរម្តងទៀតមើល៍ អត់ដឹង ស្តាប់អត់បាន។

**ស៖** បើតាមខ្សែអាត់ដែលខ្ញុំទើបនឹងដកស្រង់ឲ្យលោកស្តាប់អម្បាញ់មិញនេះ កាលពីឆ្នាំ២០០៨ លោកបែងចែកច្បាស់ណាស់ថា កែ ពក មិនមែន ប៉ុល ពក ទេ។ ថ្ងៃនេះលោកឆ្លើយថា បើតាមប្រជាជនតាមភូមិនោះ គឺមនុស្សពីរនាក់ហ្នឹងជាមនុស្សតែមួយទេ។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំចង់ដឹងថា ហេតុអីបានជាកាលពី២០០៨ លោកឆ្លើយថា ប៉ុល ពក ហើយនិង កែ ពក នេះជាមនុស្សពីរនាក់ខុសគ្នា។ តែដល់មកដល់កន្លែងនេះ លោកថា មនុស្សពីរនាក់ហ្នឹងជាមនុស្សតែមួយទេ ឈ្មោះពីរហ្នឹងមនុស្សតែមួយទេ?

**ឆ៖** ខ្លាចច្រឡំ ក្រែងលោថាអ៊ីចេះ ខ្ញុំថា ប៉ុល ពត អាមួយ -- ប៉ុលពត ជាមួយ ប៉ុលពក ហ្នឹងមិនមែនមនុស្សតែមួយទេ មនុស្សខុសគ្នា។ មួយប្អូន មួយបង កាលខ្ញុំដឹង។ មិនមែនថារឿង កែ ពក ហ្នឹងមនុស្សតែមួយណា អ់!មនុស្សខុសគ្នា អត់មានទេ។ ដឹងអ្នកសរសេរច្រឡំ ដឹងអ្នកនិយាយច្រឡំ។ ខ្ញុំមិនស្គាល់មុខ ស្គាល់ឈ្មោះគេច្បាស់ទេ ឮតែអ្នកស្រុកគេហៅ ថាមេភូមិភាគ ភូមិភាគកណ្តាល មេប៉ុល ពត ខ្លាំងក្លា សម្លាប់មនុស្សអត់ជ្រើសរើស។ អ៊ីចឹងយើងចេះតែចាប់អារម្មណ៍យកឈ្មោះគាត់មកនេះទៅ។

**ស៖** នៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ លោកបានបញ្ជាក់ថា--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន! សូមអញ្ជើញ!

ផ្អាកបន្តិចសិន គាត់ត្រូវការសម្រាក ចូលទៅបន្ទប់ទឹក។

*(សាក្សីចូលបន្ទប់ទឹក)*

[១៦:00:00]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតទៀត សហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ។ សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរជិតចប់ទៅហើយ។ លោកបាននិយាយថ្ងៃនេះនៅពេលលោកឆ្លើយទៅចៅក្រម ឡាវ៉ែន៍ លោកនិយាយអំពីការបោសសម្អាតនៅភូមិភាគបូព៌ា ហើយលោកបានឆ្លើយថា ការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ធ្វើការបោសសម្អាតនេះ គឺមិនប្រកាន់ចាម ខ្មែរអីទេ ឲ្យតែជាខ្មាំង។ លោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារ E3/8735 ចុះឆ្នាំ២០១១ ERN ជាភាសាបារាំងគឺ 00727597, ERN ជាភាសាខ្មែរគឺ 00716487, ERN ជាភាសាអង់គ្លេសគឺ 00722240។ លោកបានឆ្លើយដូចតទៅនេះ៖ "យើងសំដៅលើខ្មាំងទូទៅតែម្តង ដោយមិនបែងចែកថាចាម ចិន ខ្មែរអ្វីនោះទេ។" ហើយនៅចម្លើយបន្តមកទៀតលោកបានឆ្លើយផងដែរថា៖ "អ្នកដែលគេចោទថា ជាជនក្បត់ដោយមិនប្រកាន់ពូជសាសន៍អ្វីទេ គឺ<>ត្រូវកម្ទេចចោល។" អ៊ីចឹងសំណួរខ្ញុំចង់សួរដូចតទៅនេះ ថាតើលោកបានឆ្លើយដូចនេះទៅលោក អ៊ីសា ឧស្មាន ដែរឬទេ នៅពេលដែលគាត់សួរសំណួរមកលោក <លោក>ឆ្លើយប្រាប់គាត់ថា គេកម្ទេច បោសសម្អាតមិនប្រកាន់ពូជសាសន៍អ្វីទេ ខ្មែរ ចិន ចាមអីមិនប្រកាន់ទេ<>?

[១៦:០២:១៦]

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** ខ្ញុំអត់បានចាំរឿងឆ្លើយ អីមិនឆ្លើយទេ ប៉ុន្តែរឿងគោលការណ៍វាអ៊ីចឹងហើយ វាអត់មានទុកអ្នកណាថាអ្នកណាទេ ឲ្យតែក្បត់។ ដឹងគាត់សរសេរម៉េច គាត់សួរខ្ញុំ ខ្ញុំអត់ដឹងរឿងនេះផង។ ប៉ុន្តែគោលការណ៍ខ្ញុំឆ្លើយតាំងពីយូរមក ខ្ញុំឆ្លើយថា រឿងមិនប្រកាន់ថាចាម ខ្មែរអីទេ ព្រោះគោលការណ៍វាបោសសម្អាតខាងបូព៌ា ឲ្យតែអ្នកក្បត់ជាមួយអង្គការ ប៉ុណ្ណឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសហភាតារបស់ខ្ញុំលោក គង់ សំអុន គាត់សូមពេលនាទី ៥នាទីដើម្បីសួរបញ្ចប់លោកប្រធាន។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំចង់សួរបញ្ជាក់ លោកបានឆ្លើយរួចហើយថា លោកបានធ្វើការងារក្នុងកងចល័តក្នុងឆ្នាំ១៩៧៧។ ខ្ញុំចង់សួរថា តើលោកបានធ្វើការក្នុងកងចល័តមុនឆ្នាំ១៩៧៧ ដែរទេ? ឧទាហរណ៍ថាពីឆ្នាំ៧៥មក ឬក៏មុនឆ្នាំ៧៥ ជាដើម។

[១៦:០៣:៥៦]

**លោក វ៉ាន់ ម៉ាត់៖**

**ឆ៖** បាទ បានធ្វើតាំងពីឆ្នាំ៧៥មករហូត។ ប៉ុន្តែពេលមុនមកវាមានធូរស្រាលខ្លះ ដល់យូរទៅកាន់តែតឹងទៅ តឹងទៅ តាមនេះ។ ៧៥មកក៏មានចល័តលើកទំនប់លើកអី ប៉ុន្តែវាមិនសូវតឹងតែងដូច ៧៧, ៧៨ អ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ឈ្មោះបានទេនៅឆ្នាំ១៩៧៧ មករហូតមកហ្នឹងអ្នកណាជាមេកងចល័តរបស់លោក?

**ឆ៖** មេកងចល័តឈ្មោះ តូច ហើយនិងឈ្មោះ សយ – ប្រធាន, អនុប្រធាន។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់អំពីអំណាចរបស់គាត់បានទេ គាត់មានអំណាចធ្វើអ្វីខ្លះដែរទេ?

**ឆ៖** គាត់មានអំណាចប្រើប្រាស់យើងអីអ៊ីចឹង កងចល័តហ្នឹង ប្រើឲ្យធ្វើអីធ្វើអី គាត់មានសិទ្ធិ។ អ្នកណាមិនប្រើ អ្នកណាមិនទៅអី គាត់មានសិទ្ធិរាយការណ៍មកមេឃុំ មេអីអ៊ីចឹង។ សូមអស់យោបល់។

**ស៖** បាទសូមអរគុណ។ នៅពេលដែលលោកឆ្លើយបញ្ជាក់ថាឆ្នាំ៧៨ លោកលោតចុះពីកាណូតដើម្បីគេចខ្លួន ពេលដែលគេស្នើ -- ក្រុមខ្មែរក្រហមស្នើចងលោកនោះ លោកទៅជួបមេកងចល័តហ្នឹង មេកងចល័តរបស់លោកដែលលោកធ្វើការជាមួយហ្នឹង ឈ្មោះ ស៊ុយ ហើយនិងឈ្មោះម្នាក់ទៀត អំមិញហ្នឹង មែនទេ?

[១៦:០៥:៤៩]

**ឆ៖** ហ្នឹងហើយ ក្រោយពីមកដល់វិញ មកជួបជាមួយ សយ ហើយ តូច ហ្នឹងហើយ។

**ស៖** លោកមានទំនាក់ទំនងអីពិសេសជាមួយពួកគាត់ដែរ មេកងទាំងពីរនាក់ហ្នឹង?

**ឆ៖** មានទំនាក់ទំនងជាមិត្តភក្តិផង។ យើងក៏បានដឹងប្រាប់ពីការងារ ដែលគោលការណ៍របស់ខ្មែរក្រហម គេគោលបំណងត្រូវយកកងចល័តអីទៅវ៉ៃចោលវ៉ៃអីអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ តើលោកអត់ខ្លាចគាត់ទេ គាត់ជាមេកងដែលជាកន្លែងមួយដែលអាចថា មិនមែនជាកន្លែងដែលលោកត្រូវទៅរាយការណ៍នៅពេលនុ៎ង?

**ឆ៖** អត់ខ្លាច ព្រោះគាត់មិត្តភក្តិខ្ញុំ។ យើងដឹងសភាពការណ៍ ត្រូវរាយការណ៍ប្រាប់គ្នាហ្នឹងហើយ។ ដល់ខ្ញុំប្រាប់ គាត់រត់ចូលព្រៃមុនខ្ញុំទៀតនោះ។ រត់ទៅរកដៃគូអីណា មកជួយរំដោះនោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01216765



**សះ** បាទ សូមអរគុណ។ ខ្ញុំចង់សួរថា ហេតុអីបានជាគាត់ជឿលោក? លោកមានភ័ស្តុតាងអីបញ្ជាក់ ពេលនុ៎ង?

**ធះ** មូលហេតុដែលគាត់ជឿខ្ញុំ ដោយសារគាត់ប្រើខ្ញុំឱ្យទៅជាមួយមេឃុំហ្នឹងហើយ ប្រធានចល័តហ្នឹង។ ព្រោះខ្ញុំដឹងសភាពការណ៍ពីមេឃុំហ្នឹង ធ្វើអីៗហ្នឹង ក៏មករាយការណ៍ជូនគាត់វិញទៅ។

**សះ** បាទសូមអរគុណ។ ទាក់ទងទៅនឹងការបះបោរខាងបូព៌ា លោកអាចបញ្ជាក់ពីខែឆ្នាំបានទេ នៅពេលណាដែលមានការបះបោរវ៉ៃគ្នារវាងខាងបូព៌ាជាមួយនឹងកងទ័ពកណ្តាល ភូមិភាគកណ្តាល?

**ធះ** ភូមិភាគកណ្តាលដែលបះបោរហ្នឹង ១៩៧៧ហ្នឹងហើយ។

**សះ** បាទសូមអរគុណ។ លោកមានបានឃើញ ឬក៏ចូលរួម បានដឹងដោយផ្ទាល់អំពីការប្រយុទ្ធគ្នាក្នុងសមរភូមិណាមួយទេ ចាប់ពីឆ្នាំ១៩៧៧មកហ្នឹង រវាងកងទ័ពទាំងពីរ?

**ធះ** ធ្លាប់បានឃើញ ប៉ុន្តែយើងអត់បានចូលរួម។ ធ្លាប់បានរត់គេចគ្រាប់កាំភ្លើងគេបាញ់គ្នានៅក្នុងភូមិ ឆេះដល់ផ្ទះប្រជាពលរដ្ឋទៀត នៅឃុំព្រែកតាហុក ភូមិព្រែកតាហុក។ កងទ័ពអង្គការ គេមកពីខាងត្បូង ខាងបូព៌ា គេចាំទប់ស្កាត់នៅព្រំប្រទល់ក្រចេះ-កំពង់ចាម។

**សះ** បាទ ច្រើនដងទេ លោកបានឃើញអាការប្រយុទ្ធគ្នាហ្នឹង? ញឹកញាប់ប៉ុនណាដែរ?

**ធះ** ឃើញតែម្តងហ្នឹង។ អត់បានឃើញញឹកញាប់ទេ ឃើញតែម្តងហ្នឹង កងទ័ពហ្នឹងបាក់ទ័ពបាក់អីរត់អស់ទៅ បានអីប្រយុទ្ធទៀត។ បើខាងបូព៌ាគេរត់ចោលបោះកាំភ្លើងបោះអីចោលអស់ហើយ។

**សះ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីពេលវេលាដែលលោកគេចាប់ ហើយលោករត់លោតចូលក្នុងទន្លេ ដើម្បីគេចពីការចាប់ខ្លួនហ្នឹង។ លោកប្រាប់មកថា ឆ្លើយខាងដើមថាឆ្នាំ១៩៧៨ លោកចាំខែបានទេ ខែណាដែរ?

**ធះ** ប្រហែលជាខែ៩។ ខែ៩ ខែពេលទឹកកំពុងឡើង។

**សះ** បាទ សូមអរគុណ។ ហើយក្រោយមក ក្នុងចាប់ពីខែ៩ហ្នឹងមក មានការប្រយុទ្ធគ្នាច្រើនទៀតទេ តាមអ្វីដែលលោកចាំ?

**ធះ** ក្រោយពីខែ៩មាន។ មានប្រយុទ្ធគ្នាជាច្រើនកន្លែង ប៉ុន្តែអត់ប្រយុទ្ធធំទេ។ ប្រយុទ្ធជាមួយខ្មែរក្រហម ដោយសារកងទ័ពនោះ វាតិចតួចដែរទេ។ ព្រោះពួកខាងខ្មែរក្រហម វាអត់សូវមានកម្លាំងដែរ គ្រាន់តែរប៉េះរប៉ោះតាមភូមិអីមក របៀបមកកៀរប្រជាជនយកទៅនេះ ទៅនោះអីចឹង។ ក្រុមចល័តនោះចេះតែការពារប្រជាជន អូសប្រជាជនទៅរត់ចូលព្រៃចូលអីទៅ។ ខាងខ្មែរក្រហមអត់ហ៊ានចូលព្រៃ

ទេ ឃើញកម្លាំងហ្នឹងវាមានច្រើនដែរ។ ពេល ជួនកាលកងចល័តហ្នឹង ទៅព័ទ្ធនៅទីតាំងរបស់យោធាខ្មែរក្រហមហ្នឹង ខ្មែរក្រហមអត់ដឹងថាកងកម្លាំងច្រើនដែរ ប៉ុន្តែដល់សរុបទៅ វាជាប់ម្ភៃសាមសែសិបនាក់ដែរ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយបានបាទ។ សូមអរគុណ។

[១៦:១០:២៤]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះអរគុណលោក វ៉ាន់ ម៉ាត់។ សវនាការស្តាប់សក្ខីកម្មរបស់លោកដល់ពេលនេះ បានដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយនាពេលនេះ គឺវត្តមានរបស់លោក លែងមានភាពចាំបាច់ទៀតហើយនៅ អ.វ.ត.ក លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក វ៉ាន់ ម៉ាត់ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅ បានហើយ។

ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ទី១០ ខែមីនា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-921 ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់មន្ទីរសន្តិសុខភ្នំក្រោល សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១១ នាទី)*